# បែបរៀនភាសាបាលី

## ភាគទី ១

### វិធីទំនើបសម្រាប់រៀន និង បង្រៀនភាសាបាលី
### នៅកំរិតពុទ្ធិកបឋមសិក្សា



រៀបរៀងដោយ

ខ្ញុំព្រះករុណា អាត្មាភាព

**ធម្មបាលោ ប្រាក់ ឃុន**

កំណែលម្អជាថ្មី

គ.ស. ២០១៥

ព.ស. ២៥៥៩

បែបរៀនភាសាបាលី ភាគទី ១
ព.ស. ២៥៥៩
ប្រាក់ ឃុន



# ធម្មបាលោ ប្រាក់ ឃុន

## កិត្តិបណ្ឌិតភាសាបាលី សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ

# បែបរៀនភាសាបាលី

## ភាគទី ១

### វិធីធំនើបសម្រាប់រៀន និងបង្រៀនភាសាបាលី

### នៅកំរិតពុទ្ធិកបឋមសិក្សា


រៀបរៀងដោយ

ធម្មបាលោ ប្រាក់ ឃុន

កិត្តិបណ្ឌិតភាសាបាលី សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ



បានពិនិត្យផ្ទៀងផ្ទាត់សាជាថ្មី
នៅវត្តព្រះគន្ធកុដិ ខេត្តបាត់ដំបង

ព.ស. ២៥៥៩ គ.ស. ២០១៥

ឈ្មោះសៀវភៅ : បែបរៀនភាសាបាលី ភាគទី ១

រៀបរៀងដោយ : ធម្មបាលោ ប្រាក់ ឃុន

កិត្តិបណ្ឌិតភាសាបាលី សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ

ផ្នែកអក្ខរាវិរុទ្ធ

ភិក្ខុ ចូឡវរធម្មោ ហ៊ឹ ជីភៅ : វិនយាចារ្យ និងធម្មាចារ្យ

ភិក្ខុ ជោតបញ្ញោ ជឹម សុវណ្ណដា : វិនយាចារ្យ និងធម្មាចារ្យ

ភិក្ខុ យស្សបាលោ ជ៉ឹយ សុហុន : វិនយាចារ្យ និងធម្មាចារ្យ

ភិក្ខុ នាគទីបោ នាគ ទី : សមណសិស្ស

ផ្នែកកុំព្យូទ័រ

កោវិទោ ឡោះ សូវៀត

បោះពុម្ពលើកទី២ : ព.ស. ២៥៥៩ គ.ស. ២០១៥

# កំណែលម្អជាថ្មី

សៀវភៅ បែបរៀនភាសាបាលី ភាគទី ១ ដល់ភាគទី ៥ និងបាលីវេយ្យាករណ៍ ១ ក្បាល ដែលជាស្នាដៃរបស់ខ្ញុំព្រះករុណា អាត្មាភាព **ធម្មបាលោ ប្រាក់ យុន** កំពុងតែចរាចរ ទៅក្នុងប្រទេសនិងក្រៅប្រទេស អមដំណើរដោយសម្លេងបង្រៀនវេយ្យាករណ៍ និងប្រែធម្មបទ - មង្គល - វិសុទ្ធិមគ្គ - នៅក្នុងខ្សែអាត់ និង ឌិសផង ដើម្បីឲ្យសិក្ខាកាមជាប់ចិត្តជិតអារម្មណ៍ ខំសិក្សារៀនសូត្រភាសាបាលីតរៀងទៅ ។

ដើម្បីសម្រួលដល់ការចង់ចេះដឹងភាសាបាលី របស់ព្រះសង្ឃ គ្រហស្ថ និងដើម្បីរក្សាវប្បធម៌មរតអក្សរសាស្ត្រខ្មែរ ឲ្យគង់វង្សនិងរីកចំរើនតរៀងទៅ ។

ខ្ញុំព្រះករុណា អាត្មាភាព និងព្រះសង្ឃវត្តព្រះគន្ធកុដិ ខេត្តបាត់ដំបង ជួយឧបត្ថម្ភ ព្រមទាំងសមណនិស្សិត សិស្ស នៅខេត្ត ក្រុងដទៃទៀត ជួយឧបត្ថម្ភ **កំណែលម្អជាថ្មី** ធ្វើឲ្យ "បែបរៀនភាសាបាលី" ឲ្យមានភាពសុក្រឹត្យប្រសិទ្ធភាពពិត

ប្រាកដជាមូលដ្ឋាន នៃវប្បធម៌ព្រះពុទ្ធសាសនា និងអក្សរសាស្ត្រខ្មែរ រុងរឿង ស្ថិតស្ថេរចេរកាលយូរអង្វែងតរៀងទៅ ។

សូមថ្លែងអំណរគុណយ៉ាងប្រសើរបំផុត ចំពោះ សាស្ត្រាចារ្យ វិនយាចារ្យ ធម្មាចារ្យ និស្សិត សិស្ស ដែលបាន ជួយឧបត្ថម្ភតាមសមត្ថភាពគ្រប់ព្រះអង្គ ជួយផ្តល់យោបល់ និងជួយកែតម្រូវ ដើម្បីធ្វើឲ្យសៀវភៅនេះ រឹងរឹតតែល្អប្រសើរ ឡើងទៀត ។

សូមអនុមោទនាយកផលានិសង្សនៃមហាធម្មទាន បាន សម្រេចមគ្គ ផល ដល់ព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

វត្តព្រះគន្ធកុដិ ថ្ងៃ ១២ រោច ខែ ភទ្របទ ព.ស. ២៥៥៩ / គ.ស. ២០១៥

អ្នករៀបរៀង

**ធម្មបាលោ ប្រាក់ ឃុន**

# បុព្វកថា

នាងខ្ញុំមានសេចក្ដីរីករាយ ចំពោះការសរសេរបុព្វកថានេះ ។ គឺឯកឧត្ដម ឈន អៀម, អនុរដ្ឋលេខាធិការ ទទួលបន្ទុកពុទ្ធសាសនបណ្ឌិត្យ, ដែលបានប្រាប់អោយនាងខ្ញុំដឹងមុនគេ ចំពោះហេតុដែលថា ការរៀនភាសាបាលីនៅកម្ពុជា ត្រូវបានប្រព្រឹត្តទៅតាមការរៀនសូត្រចាំមាត់, ហើយដោយហេតុនេះ ត្រូវការយ៉ាងបន្ទាន់អោយមានការផ្លាស់ប្ដូរក្នុងវិធីបង្រៀន ។ ការនិយាយប្រាប់នេះ បានកន្លងទៅពីរឆ្នាំហើយ តាំងពីពេលដែលនាងខ្ញុំកំពុងធ្វើការជាមួយអង្គការសហប្រជាជាតិ នៅក្នុងប្រទេសកម្ពុជាម្ល៉េះ ។

ក្រោយពេលនាងខ្ញុំបានមកធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ នាដើមឆ្នាំ ១៩៩៦, ឯកឧត្ដម ដោក ណារិន, អនុរដ្ឋលេខាធិការ ទទួលបន្ទុកពុទ្ធិកសិក្សា បានធ្វើសំណូមពរអោយនាងខ្ញុំជួយឧបត្ថម្ភថវិកាដល់កម្មវិធីបណ្ដុះបណ្ដាលរយៈពេលខ្លីសម្រាប់គ្រូបង្រៀនភាសាបាលី ជិត ២៥០ នាក់ ដែលមិនធ្លាប់បានទទួលការបណ្ដុះបណ្ដាលដ៏សមស្រប ។ នាងខ្ញុំបានឆ្លៀតយកឱកាសនោះ ពិនិត្យមើលសៀវភៅវេយ្យាករណ៍បាលីដែលមានស្រាប់ ហើយសរសេរជាភាសាខ្មែរ ។ ឯកឧត្ដម ដោក ណារិន ក៏បានប្រាប់អោយនាងខ្ញុំដឹងផងដែរ អំពីសំណៅមេរៀនភាសាបាលីបែបថ្មីមួយ រៀបរៀងឡើងដោយលោក ប្រាក់ ឃុន ដែលមិនទាន់បានបោះពុម្ពផ្សាយនៅឡើយ ។ នៅក្នុងសំណៅនោះ នាងខ្ញុំបានមើលឃើញមានសក្ដានុពល ដែលអាចនាំទៅកាន់ការធ្វើអោយមេរៀនភាសាបាលីបានត្រឹមត្រូវ ប្រកបដោយវិធីបង្រៀនទំនើប ។ នាងខ្ញុំ បានអង្គុយប្រជុំជាមួយលោក ប្រាក់ ឃុន និងក្រុមគ្រូបង្រៀនបាលីមកពីក្រសួងធម្មការ និងសាសនា និងមកពីពុទ្ធសាសនបណ្ឌិត្យ, ហើយបានណែនាំ

អស់លោកទាំងនោះ អំពីវិធីទំនើបបង្រៀនភាសាដល់អ្នករៀនដំបូង តាមរយៈការការតែងជាឃ្លាប្រយោគ . ដ៏ជាទិដ្ឋភាពមួយដែលខ្វះនៅក្នុងមេរៀនភាសាបាលីបច្ចុប្បន្ន ក្នុងប្រទេសកម្ពុជា ។ នេះគឺជាវិធីដែលព្រះតេជព្រះគុណ សាស្ត្រាចារ្យ អ.ប. ពុទ្ធទត្តៈ មហានាយកត្ថេរ នៃប្រទេសស្រីលង្កា ធ្លាប់បានប្រើនៅក្នុងសៀវភៅ « The New Pali Course » ( វិជ្ជាសិក្សាភាសាបាលិ បែបថ្មី ) បោះពុម្ពផ្សាយជាភាសាអង់គ្លេស ក្នុងឆ្នាំ ១៩៣៧ ដែលនាងខ្ញុំធ្លាប់បានសិក្សា និងធ្លាប់បានបង្រៀននៅក្នុងប្រទេសស្រីលង្កា និងនៅក្នុងប្រទេសអង់គ្លេសផងដែរ ។

បាលី ឬ មាគធី, ដូចដែលគេធ្លាប់ហៅពីកាលនោះ, គឺជាភាសាដែលព្រះពុទ្ធតែងបានប្រើសម្រាប់ទេសនា នៅក្នុងសតវត្សទី ៦ មុនគ្រិស្តសករាជ នៅក្នុងប្រទេសស្រីលង្កា ។ ចាប់តាំងពីពេលនោះមក អដ្ឋកថាព្រះត្រៃបិដកជាច្រើន, អត្ថបទស្តីពីទស្សនវិជ្ជាពុទ្ធសាសនាជាច្រើន, ក៏ដូចជាអត្ថបទផ្លូវលោកទាំងឡាយផងដែរ ត្រូវបានគេសរសេរជាភាសាបាលី នៅក្នុងប្រទេសឥណ្ឌា និងនៅក្នុងប្រទេសកាន់ពុទ្ធសាសនាថេរវាទ ដូចជា ស្រីលង្កា, ភូមា, សៀម, និងកម្ពុជា ។ ជាងនេះទៀត កាលណាបព្វជិតទាំងឡាយមកពីប្រទេសកាន់ពុទ្ធសាសនាថេរវាទ បាននិមន្តទៅកាន់ប្រទេសកាន់ពុទ្ធសាសនាថេរវាទមួយទៀត កាលពីអតីតកាល, ភាសាបាលី គឺជាភាសាអន្តរជាតិ ដែលបព្វជិតទាំងនោះបានប្រើ សម្រាប់ប្រាស្រ័យឆ្លើយឆ្លងគ្នា ។ ថ្វីបើភាសាបាលិ មិនត្រូវបានប្រជាជននិយាយក៏ដោយ, ក៏ភាសានេះ នៅតែជាភាសារួមរហូតមកដល់សព្វថ្ងៃនៅឡើយ, ដែលតាមរយៈភាសានេះ បព្វជិតពុទ្ធ. សាសនិកពីប្រទេសកាន់ពុទ្ធសាសនាថេរវាទ តែងប្រាស្រ័យឆ្លើយឆ្លងគ្នា ។ ជាឧទាហរណ៍ បព្វជិតមកពីស្រីលង្កា, កាលណាលោកនិមន្តទៅកាន់ប្រទេសថៃ, តែងសន្ទនាជាមួយបព្វជិតថៃ ជាភាសាបាលិ ។ ដោយហេតុនេះ ការរៀនភាសាបាលី តាមរយៈការតែងជាឃ្លា . ប្រយោគ ជួយសម្រួលដល់ការសន្ទនា, បន្ថែមទៅលើការយល់

អត្ថបទជាភាសាបាលិ ពីបុរាណកាលទៀតផង ។

សៀវភៅ « វិជ្ជាសិក្សាភាសាបាលិ » នេះ គឺជាគម្រូយមួយ នៅក្នុងប្រទេសកម្ពុជា ពីព្រោះ នេះគឺជាការខិតខំមួយជាលើកដំបូង ដើម្បីបង្រៀនបាលិដល់អ្នករៀនដំបូង តាមរយៈការតែងជាឃ្លា-ប្រយោគ ។ នាងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោក ប្រាក់ ឃុន និងចំពោះក្រុមគ្រូបង្រៀនបាលិដែលបានធ្វើការយ៉ាងនឿយហត់ ដើម្បីបង្កើតឡើងនូវសៀវភៅនេះ, ព្រមទាំងអំណរគុណចំពោះសម្ដេចព្រះមង្គលទេពាចារ្យ អ៊ុម ស៊ុម, អគ្គាធិការនៃពុទ្ធិក-សិក្សា, ចំពោះព្រះពុទ្ធឃោសាចារ្យ ហេង លាងហោ , នាយកពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, និងចំពោះសម្ដេចព្រះធម្មលិខិត លាស់ ឡាយ ព្រះចៅអធិការវត្តសន្សំកុសល, ទីក្រុងភ្នំពេញ, ដែលបានពិនិត្យយ៉ាងល្អិតល្អន់នូវសំណៅចុងក្រោយ ។ នៅទីអវសាន, នាងខ្ញុំ សូមថ្លែងអំណរគុណ លោក ឱម ខែម, នាយកពុទ្ធសាសន-បណ្ឌិត្យ ដែលបានយកចិត្តទុកដាក់យ៉ាងខ្លាំង ធ្វើអោយសៀវភៅនេះ សម្រេចបោះពុម្ពបាន ។

បណ្ឌិត *ហេម៉ា គុណតិលកេ*

ពុទ្ធសាសនបណ្ឌិត្យ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ : 672 / 96 ក.ធ.ស

# លិខិតបង្គាប់ការ

មន្ត្រីរាជការ នៃក្រសួងធម្មការ និង សាសនា ដូចមានរាយនាមខាងក្រោមនេះ ត្រូវបានចាត់តាំងឱ្យទៅពិនិត្យ និងសម្រេចបោះពុម្ពសៀវភៅសិក្សា « បាលីវេយ្យាករណ៍ » ជាមួយលោកស្រីបណ្ឌិត ហេម៉ា នៅសាលប្រជុំពុទ្ធសាសនបណ្ឌិត្យ ចាប់ពីថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៩៦ វេលាម៉ោង ៨ ព្រឹក តទៅ រហូតដល់ចប់ជាស្ថាពរ ។

១. លោក រស់ សាវេន

២. លោក នួច ជឹម

៣. លោក ប្រាក់ ឃុន

៤. លោក ម៉ែន ប្រាង

៥. លោក អាំ ឆន

៦. លោក អ៊ុង សុវណ្ណ

៧. លោក ជិត ជន

មន្ត្រីរាជការ ដូចមានរាយនាមខាងលើ ត្រូវអនុវត្តភារកិច្ចរៀងៗខ្លួន ឱ្យបានសម្រេចលទ្ធផលល្អប្រសើរ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ១៩៩៦

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

[illegible]កៀន - វណ្ណៈរឿ

# និវេទនកថា

គណៈកម្មការឯកទេសភាសាបាលិ បានត្រួតពិនិត្យសំណៅ « បាលិវេយ្យាករណ៍ ភាគទី ១ » របស់លោក ប្រាក់ ឃុន គ្រូពុទ្ធិកបឋមសិក្សា វត្តពោធិវាល ខេត្តបាត់ដំបង ជាពីរលើក នៅសាលប្រជុំពុទ្ធសាសនបណ្ឌិត្យ ៖

. លើកទី ១ នៅខែកញ្ញា ឆ្នាំ ១៩៩៦ ។ គណៈកម្មការបានពិនិត្យ និងសម្រេចឱ្យកាត់បន្ថយត្រង់អន្លើខ្លះ ខាងផ្នែកមេរៀនវេយ្យាករណ៍ ទុកសម្រាប់សៀវភៅ ភាគទី ២ ហើយបានសុំឱ្យលោក ប្រាក់ ឃុន រៀបរៀង កែសម្រួល និងបំពេញបន្ថែមផ្នែកលំហាត់មួយចំនួនទៀត ។ បន្ទាប់មក អង្គប្រជុំបានសម្រេចដូរឈ្មោះ « បាលិវេយ្យាករណ៍ ភាគទី ១ » នេះទៅជា « បែបរៀនភាសាបាលិ » វិញ ដើម្បីឱ្យស្របទៅនឹងមេរៀន និងលំហាត់ ក្នុងសៀវភៅនេះ ។

. លើកទី ២ នៅដើមឆ្នាំ ១៩៩៧ ។ គណៈកម្មការបានពិនិត្យឃើញថា សៀវភៅ «បែបរៀនភាសាបាលិ ភាគទី ១ » ដែលបានរៀបរៀង កែសម្រួលឡើងវិញនេះ មានលក្ខណៈសមស្របតាមវិធីទំនើបសម្រាប់រៀន និងបង្រៀនភាសាបាលិ នៅពុទ្ធិកបឋមសិក្សា នាពេលបច្ចុប្បន្ននេះ ។

គណៈកម្មការឯកទេសភាសាបាលិ បានធ្វើសំណូមពរឱ្យគណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា ដាក់បញ្ចូលសៀវភៅ បែបរៀនភាសាបាលិនេះ ក្នុងពួកសៀវភៅ « សម្រាប់ការសិក្សាភាសាបាលី » ក្នុងព្រះរាជាណាចក្រកម្ពុជា តទៅ ។

ភ្នំពេញ, ថ្ងៃ ១៣ ខែមករា ឆ្នាំ ១៩៩៧

ជ. គណៈកម្មការឯកទេសភាសាបាលី

ម៉ែន ប្រាជ

# សេចក្ដីជក្រស់ស់កំណត់ហេតុ
# របស់គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា

បន្ទាប់ពីគណៈកម្មការឯកទេសភាសាបាលី បានពិនិត្យសំណៅ « *បែបរៀនភាសាបាលី ភាគទី ១* » ដែលរៀបរៀងឡើងដោយលោក ប្រាក់ ឃុន រួចមក គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សានៃក្រសួងធម្មការ និងសាសនា បានប្រជុំគ្នាត្រួតពិនិត្យយ៉ាងម៉ត់ចត់នូវសំណៅ បែបរៀនភាសាបាលី ភាគទី ១ នេះ នៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ១៩៩៧ ។ គណៈកម្មការយល់ឃើញថា ៖

. មេរៀនសង្ខេប លំហាត់តែង និងបំពេញពាក្យជាឃ្លា . ប្រយោគ ក្នុងសៀវភៅនេះ មានលក្ខណៈឆ្លើយតបតាមសំណូមពរ របស់សិស្សនិងគ្រូនៃសាលាពុទ្ធិកបឋមសិក្សា ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួចចង់បានជាយូរមកហើយ ។

. សៀវភៅនេះ ជាជំហានដំបូង ស្របតាមទិសដៅនៃការអភិវឌ្ឍន៍ពុទ្ធិក-សិក្សា នៅក្នុងប្រទេសកម្ពុជា នាបច្ចុប្បន្ន ។

. សៀវភៅនេះ ស្របតាមសង្វាក់នៃការសិក្សាផ្នែកភាសាអន្តរជាតិផងដែរ ។

គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា បានសម្រេចបញ្ចូលសៀវភៅ *បែបរៀនភាសាបាលី* នេះ ក្នុងពពួកសៀវភៅ « សម្រាប់ការសិក្សាភាសាបាលី កម្រិតពុទ្ធិកបឋមសិក្សា ឆ្នាំទី ១ » តទៅ ។

ភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ជ. គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា



ជោភ ណារិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និងសាសនា

លេខ ៣៧ / ៩៧ ក.ធ.ស

ភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

# សេចក្តីសម្រេច

## ស្តីពីការបោះពុម្ពសៀវភៅបែបរៀនភាសាបាលីភាគ ।

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣,
- បានឃើញព្រះរាជក្រម លេខ នស.រកម. ០១៩៦.១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា,
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ១៩៩៧,

## សម្រេច

ប្រការ ១ : អនុញ្ញាតឱ្យបោះពុម្ពសៀវភៅ បែបរៀនភាសាបាលីភាគ । ។

ប្រការ ២ : សៀវភៅបែបរៀនភាសាបាលីភាគ । ត្រូវបោះពុម្ពខ្នាត ទំហំ ១៤ x ២០,៥ ។

ប្រការ ៣ : អនុអញ្ញាតឱ្យបោះពុម្ពលើកទី । ចំនួន ៣.៥០០ ក្បាល ។

ប្រការ ៤ : វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ [illegible] មានភារកិច្ចអនុវត្តឱ្យបាន សម្រេចលទ្ធផលល្អ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចម្លងជូន :

- ក្រសួងសម្តេចព្រះសង្ឃរាជទាំងពីរគណៈ
- ឯកសារ

[illegible]

# អារម្ភកថា

ដោយយល់ឃើញថា ការសិក្សាភាសាបាលីដំបូង នៅសាលាពុទ្ធិកបឋមសិក្សា សមណសិស្សច្រើនត្អូញត្អែរថា ភាសាបាលី គេរៀនចេះបានដោយលំបាកត្រូវរៀនបាលីវេយ្យាករណ៍ ឱ្យចប់ទាំង ៧ និទ្ទេស ក្នុងឆ្នាំទី ១ ដោយមិនមានលំហាត់ប្រែលោតប្រយោគ ។ លុះឆ្នាំទី ២ ទី ៣ រៀនប្រែលោតប្រយោគ ក្នុងគម្ពីរធម្មបទដ្ឋកថា ទាំង ៨ ភាគ ហើយបោះបង់ក្បួនវេយ្យាករណ៍ ជាហេតុឱ្យភ្លេចភ្លាំង ។

សៀវភៅបែបរៀនភាសាបាលី សម្រាប់សិស្សថ្នាក់ទី ១ នេះ មានមេរៀនសង្ខេបអំពី អក្ខរៈ, នាម, អាខ្យាត និងកិតកៈ ហើយមានលំហាត់តែងប្រយោគខ្លីៗ គឺលំហាត់រៀនប្រែពីភាសាបាលីទៅជាភាសាខ្មែរ ប្រែពីភាសាខ្មែរ ទៅជាភាសាបាលី និងលំហាត់បំពេញពាក្យបាលីត្រង់ចន្លោះ ដែលជាជំហានឆ្ពោះទៅរៀនប្រែគម្ពីរធម្មបទដ្ឋកថា និងបន្តការសិក្សា បាលីវេយ្យាករណ៍ ដែលនៅសេសសល់ ក្នុងឆ្នាំទី ២ ឆ្នាំទី ៣ តទៅទៀត ។

សៀវភៅបែបរៀនភាសាបាលី ភាគទី ១ នេះខ្ញុំបានដកស្រង់ពី :

១. សៀវភៅបាលីវេយ្យាករណ៍របស់ព្រះពុទ្ធវង្ស សេខ នាង សាស្ត្រាចារ្យ នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ក្រុងភ្នំពេញ ។

២. កច្ចាយនទ្វបត្ថម្ភកៈ ភាគទី ១ ភាគទី ២ របស់ព្រះគ្រូសាស-នសោភ័ណ ជួន ណាត បោះពុម្ពគ្រាទី ១០ ក្នុង ព. ស. ២៥១៣ គ. ស. ១៩៦៩ ។

៣. ប្រស្នាកច្ចាយនទ្វបត្ថម្ភកៈ របស់ព្រះគ្រូមុនីសោភ័ណ សេខ នាង បោះពុម្ពផ្សាយដោយ ឃុន សុវត្ថិវេទី យូ អ៊ុន ក្នុង ព.ស. ២៥១៦ , គ.ស. ១៩៧២ ។

៤. បែបរៀនថ្មីភាសាបាលីជាន់ដំបូង របស់លោកសាស្ត្រាចារ្យ ញ៉ុក ថែម បោះពុម្ពផ្សាយចេញពីមហាវិទ្យាល័យអក្សរសាស្ត្រ និង មនុស្សសាស្ត្រ ឆ្នាំ ១៩៦២ ។

លុះរៀបរៀងរួចហើយ ខ្ញុំបានប្រគល់សំណៅបែបរៀនភាសាបាលីភាគទី ១ សម្រាប់សិស្សថ្នាក់ទី ១ នេះ ទៅក្រសួងធម្មការ និង សាសនា ។

ព.ស. ២៥៤០

បាត់ដំបង, ខែ តុលា

គ.ស. ១៩៩៦

**ច្រាក់ ឃុន** ហៅ ( **មាស ហម** )

គ្រូពុទ្ធិកបឋមសិក្សា វត្តពោធិ៍វាល

ខេត្តបាត់ដំបង

# មាតិកា

ឈ្មោះអត្ថបទ ទំព័រ

១.អក្សរសង្ខេប ........................................ ១

២.អក្ខរៈ ................................................ ២

៣.ព្យញ្ជនៈ ............................................. ៣

៤. ឃោសាឃោសៈ ..................................... ៦

៥. អក្ខរប្បភេទ ......................................... ៦

៦.នាម ...................................................... ៩

៧.នាមសព្ទ ................................................ ៩

៨.នាមនាម ................................................ ៩

៩.គុណនាម ............................................... ៩

១០.សព្វនាម ............................................. ១០

១១.លិង្គ .................................................... ១១

១២.នាមសព្ទមានលិង្គផ្សេងគ្នា ........................ ១២

១៣.វចនៈ .................................................. ១២

១៤.វិភត្តិ .................................................. ១៣

១៥.វិភត្តិ និង ពាក្យប្រែ ................................ ១៣

១៦.ការន្ត ................................................... ១៥

១៧.វិធីបំបែកនាមសព្ទ ........................................ ១៥

១៨.អ ការន្តបុំលិង្គ ................................................ ១៥

១៩.របៀបរៀងភាសាបាលី ..................................... ១៩

២០.របៀបប្រែ ........................................................ ២០

២១.ឥ ការន្តបុំលិង្គ ................................................ ២៩

២២.ឦ ការន្តបុំលិង្គ ............................................... ៣៣

២៣.ឧ ការន្តបុំលិង្គ ................................................ ៣៧

២៤.ឩ ការន្តបុំលិង្គ ................................................ ៣៩

២៥.អា ការន្តឥត្ថីលិង្គ ............................................ ៤៤

២៦.ឥ ការន្តឥត្ថីលិង្គ .............................................. ៥០

២៧.ឦ ការន្តឥត្ថីលិង្គ ............................................. ៥២

២៨.ឧ ការន្តឥត្ថីលិង្គ .............................................. ៥៦

២៩.ឩ ការន្តឥត្ថីលិង្គ .............................................. ៥៧

៣០.អ ការន្តនបុំសកលិង្គ ........................................ ៦០

៣១.ឥ ការន្តនបុំសកលិង្គ ........................................ ៦២

៣២.ឧ ការន្តនបុំសកលិង្គ ........................................ ៦៣

៣៣.បកិណ្ណកសព្ទ ................................................. ៦៦

៣៤.ព្រហ្ម ........................................ ៦៧

៣៥.អត្ត ........................................ ៦៧

៣៦.សខ ........................................ ៦៨

៣៧.រាជ ........................................ ៦៩

៣៨.ភគវន្តុ ........................................ ៧០

៣៩.អរហន្ត ........................................ ៧០

៤០.ភវន្ត ........................................ ៧៣

៤១.សត្ថុ ........................................ ៧៤

៤២.បិតុ ........................................ ៧៥

៤៣.មាតុ ........................................ ៧៥

៤៤.មន ........................................ ៧៦

៤៥.កម្ម ........................................ ៧៦

៤៦.គោ ........................................ ៧៧

៤៧.សព្វនាម ........................................ ៨០

៤៨.បុរិសសព្វនាម ........................................ ៨១

៤៩.ត សព្ព ........................................ ៨១

៥០.តុម្ហ សព្ព ........................................ ៨៣

៥១.អម្ហ សព្ព ........................................ ៨៣

៥២.វិសេសនសព្វនាម .................................... ៨៧

៥៣.និយម .................................................. ៨៧

៥៤.អនិយម ................................................ ៨៧

៥៥.យ សព្ទ ................................................ ៨៨

៥៦.ត៑ម សព្ទ .............................................. ៩០

៥៧.អមុ សព្ទ ............................................ ៩១

៥៨.សំខ្យាសព្ទ ......................................... ៩៥

៥៩.វិធីរាប់បកតិសំខ្យា ................................ ៩៦

៦០.វិធីប្រើ ឧត្តរ និង អធិក ..........................១០៤

៦១.វិធីបំបែក បកតិសំខ្យា ...........................១០៥

៦២.បូរណសំខ្យា .........................................១០៨

៦៣.អព្យយសព្ទ .........................................១១១

៦៤.ឧបសគ្គ ..............................................១១១

៦៥.និបាត ................................................១១២

៦៦.បច្ច័យ ................................................១១២

៦៧.អាខ្យាត .............................................១១៧

៦៨.វិភត្តិ ..................................................១១៨

៦៩.កាល ..................................................១៣៧

៧០.បទ ..................................................១៤១

៧១.វចនៈ ..............................................១៤២

៧២.បុរិស ................................................១៤២

៧៣.ធាតុ .................................................១៤៣

៧៤.វាចកៈ ..............................................១៤៥

៧៥.បច្ច័យ ...............................................១៤៦

៧៦.វិធីតែងវាចកៈអាខ្យាត..................................១៥២

៧៧.កិរិយាកិតកៈ ..........................................១៥៥

៧៨.វិភត្តិ និង វចនៈ ......................................១៥៥

៧៩.កាល .................................................១៥៥

៨០.ធាតុ និង វាចកៈ ......................................១៥៨

៨១.វាចកៈ ៥ យ៉ាង .......................................១៥៨

៨២.បច្ច័យនៃកិរិយាកិតកៈ ....................................១៥៩

៨៣.ការតែងវាចកៈ ៤ ......................................១៧៤

៨៤.សន្ត សព្ទ ២ យ៉ាង ....................................១៧៤

# អក្សរសង្ខេប

## ប្រើក្នុងសៀវភៅបែបរៀនភាសាបាលីនេះ

| | | | | | |
|---|---|---|---|---|---|
| អា. | គឺ | អាលបន | ត. | គឺ | តតិយា |
| ឥ. | - | ឥត្ថីលិង្គ | ទ. | - | ទាំងឡាយ |
| ឯក. | - | ឯកវចន | ទុ. | - | ទុតិយា |
| ឧ. | - | ឧទាហរណ៍ | នបុំ. | - | នបុំសកលិង្គ |
| ឧ. | - | ឧត្តមបុរិស | ប. | - | បឋមា |
| កត្តុ. | - | កត្តុវាចក | បញ្ច. | - | បញ្ចមី |
| កម្ម. | - | កម្មវាចក | បុំ. | - | បុំលិង្គ |
| កម្ម. កម្ម. | - | កម្មរូបកម្មសាធន | បុំ. ឥ. | - | បុំលិង្គនិងឥត្ថីលិង្គ |
| ច. | - | ចតុត្ថី | ពហុ. | - | ពហុវចន |
| ឆ. | - | ឆដ្ឋី | ភ.ភ. | - | ភាវរូបភាវសាធន |
| | | | ស. | - | សត្តមី |

## គ្រឿងសំគាល់

+ សំគាល់ថា « និង » ឬថា « ហើយនិង »,

> សំគាល់ថា « ជា » ឬថា « ទៅជា » ដូចជា អ + ឥ > ឯ ឱ្យថា អ និង ឥ ជា ឯ ឬថា អ ហើយនិង ឥ ទៅជា ឯ ។

< សំគាល់ថា « មកពី » ដូចជា **ឯ** < **អ** + **ឥ** ឱ្យថា **ឯ** មកពី **អ** និង **ឥ** ។

ឯគ្រឿងសំគាល់ឯទៀតក្រៅពីនេះ មិនបាននាំមកពន្យល់ក្នុងទីនេះទេ ពីព្រោះអ្នករៀនធ្លាប់បានប្រើរៀងមកហើយ ។

**នមោ ពុទ្ធាយ សិទ្ធំ**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះពុទ្ធ

ការសិក្សានេះ សូមឱ្យជាការសម្រេច ។

---

## អក្ខរៈ

**អក្ខរៈ** សម្រាប់ប្រើក្នុងភាសាបាលីមាន ៤១ តួ គឺ : សរៈ ( ស្រៈ ) ៨ តួ ព្យញ្ជនៈ ៣៣ តួ ។

ស្រៈ ៨ តួ :

- ស្រៈនិស្ស័យ ǀ -ា -ិ -ី -ុ -ូ េ- េ-ា
- ស្រៈពេញតួ អ អា ឥ ឦ ឧ ឩ ឯ ឱ

អ អា ឥ ឦ ឧ ឩ ឯ ឱ

# ព្យញ្ជនៈ ៣៣ តួ

ក ខ គ ឃ ង　　　　ច ឆ ជ ឈ ញ

ក ខ គ ឃ ង　　　　ច ឆ ជ ឈ ញ

ដ ឋ ឌ ឍ ណ　　　　ត ថ ទ ធ ន

ដ ឋ ឌ ឍ ណ　　　　ត ថ ទ ធ ន

ប ផ ព ភ ម

ប ផ ព ភ ម

យ រ ល វ ស ហ ឡ ំ ។

យ រ ល វ ស ហ ឡ ំ ។

## ១-អក្ខរៈ

**អក្ខរៈ** ឬ **អក្សរ** លោកអ្នកប្រាជ្ញសំដៅយកហេតុពីរយ៉ាង គឺ : សូរសំឡេងដែលលាន់ឮប្រាកដឡើង ១, ស្នាមគំនូសជាតួរាង លម្អកំណត់ចំណាំបានស្រួល ១ មករួមគ្នា ហៅថា **អក្ខរៈ ឬ អក្សរ** ។

អក្ខរៈក្នុងភាសាបាលី មាន ៤១ តួ គឺ អ អា ឥ ឦ ឧ ឩ ឯ ឱ ៨ តួនេះ ហៅថា **សរៈ** ( ស្រះ ) **កខគឃង ចឆជឈញ ដឋឌឍណ តថទធន បផពភម យរលវសហឡ** ំ ៣៣ តួនេះ ហៅថា ព្យញ្ជនៈ ។

ស្រះអាចចេញសំឡេងតាមទំនើងខ្លួនឯងផង ហើយអាចញុំាងព្យញ្ជនៈ ឱ្យចេញសំឡេងបានផង ។ ស្រះទាំង ៨ តួនេះ ហៅថា **និស្ស័យ** ប្រែថា អក្សរជាទីអាស្រ័យនៃព្យញ្ជនៈ ។

ស្រះមានសូរសំឡេងខ្លី ហៅថា **រស្សៈ** មាន ៣ តួ គឺៈ អ ឥ ឧ ដូចជា **អភិរមតុ, ឧមតិ** ។

ស្រះដែលមានសូរវែង ហៅថា **ទីឃៈ** មាន ៥ តួ គឺៈ **អា ឦ ឩ ឯ ឱ** ដូចជា **ភាគី ថូបោ ថេរោ** ។

ស្រះទីឃៈ ៣ តួ គឺៈ **អា ឯ ឱ** បើមានព្យញ្ជនៈតម្រួតគ្នាពីរតួនៅខាងចុងក៏មានសូរខ្លី ដូចជាស្រះរស្សៈ ទៅវិញ ដូចជា **អាត្តំ ឯត្តកំ ឱដ្ឋោ** ។

ស្រះបើចែកជាគូមាន ៣ គូ គឺ **អ អា** ហៅថា **អ~វណ្ណៈ** ជាគូ ១, **ឥ ឦ** ហៅថា **ឥ~វណ្ណៈ** ជាគូ ១, **ឧ ឩ** ហៅថា **ឧ~វណ្ណៈ** ជាគូ ១, ។

ស្រះពីរតួគឺ **ឯ ឱ** នេះជាស្រះឥតគូ ហៅថា **សំយុត្តសរៈ** "ស្រះផ្សំ" គឺ **អ** + **ឥ** > **ឯ**, **អ** + **ឧ** > **ឱ** ។

# ព្យញ្ជនៈ

អក្សរ ៣៣ តួ ក្រៅពីស្រះ ហៅថា **ព្យញ្ជនៈ** "អក្សរធ្វើសេចក្តីឱ្យប្រាកដ" ។ ព្យញ្ជនៈ ៣៣ តួនោះ ឈ្មោះថា **និស្សិត** ព្រោះត្រូវអាស្រ័យស្រះផង ទើបចេញសូរសំឡេងច្បាស់ប្រាកដបាន ដូចពាក្យ **កេសា**, ទៅណា, បើមានតែស្រះ េ, ោ, ៅ ា ឬ **ក**, **ស**, **ន**, **ណ**, ស្តាប់ពុំបានឡើយ ។

ព្យញ្ជនៈ ៣៣ តួនោះចែកជា ២ ពួកគឺៈ វគ្គៈ ១ ពួក, អវគ្គៈ ១ ពួក ។ វគ្គៈចែកទៅទៀតមាន ៥ ពួក គឺៈ

**ក ខ គ ឃ ង** ៥ តួនេះ ហៅថា **ក-វគ្គៈ**,

**ច ឆ ជ ឈ ញ** ៥ តួនេះ ហៅថា **ច-វគ្គៈ**,

**ដ ឋ ឌ ឍ ណ** ៥ តួនេះ ហៅថា **ដ-វគ្គៈ**,

**ត ថ ទ ធ ន** ៥ តួនេះ ហៅថា **ត-វគ្គៈ**,

**ប ផ ព ភ ម** ៥ តួនេះ ហៅថា **ប-វគ្គៈ**,

ព្យញ្ជនៈ ៨ តួ គឺ **យ រ ល វ ស ហ ឡ ំ** នេះ ហៅថា **អ-វគ្គៈ** ព្រោះមិនមានពួក ឬហៅថា **សេសវគ្គៈ** ព្រោះមានតួដ៏សេស គឺ សល់ក្រៅពីពួក ។ ព្យញ្ជនៈ គឺ ំ នេះ ហៅថា **និគ្គហិត** ក្នុងភាសាបាលី អាស្រ័យបានតែនឹងស្រះ ៣ តួ គឺ **អ ឥ ឧ**

ដូចជា **អរហំ អកាសិ សេតុំ** ។

## ឃោសាឃោសៈ

ព្យញ្ជនៈទី១ ទី២ ក្នុងវគ្គៈទាំង ៥ គឺ **កខ ចឆ ដឋ តថ** និង **អវគ្គៈ** ១ តួ គឺ **ស**, ១១ តួនេះ ហៅថាៈ **អឃោសៈ** “មានសំឡេង មិនគឹកកង” ។ ព្យញ្ជនៈទី៣ ទី៤ ទី៥ ក្នុងវគ្គទាំង ៥ គឺ **គឃង ជឈញ ឌឍណ ទធន ពភម** និង អវគ្គៈ ៦ តួ គឺ **យ រ ល វ ហ ឡ** ២១ តួនេះ ហៅថា **ឃោសៈ** “មានសំឡេងគឹកកង” ។

ព្យញ្ជនៈ គឺ ំ នេះ ជា **ឃោសាឃោសវិមុត្តិ** រួចផុតចាក **ឃោសៈ** និង **អឃោសៈ** ។

## អក្ខរប្បភេទ

គូនៃអក្ខរៈដែលមានសូរជាទំទាស់នឹងគ្នា ហៅថា **អក្ខរប្បភេទ**, បើរាប់ ជាគូ មាន ៥ គូ បើរាប់រាយមាន ១០ គឺ **សិថិល**, **ធនិត**, **ទីឃៈ**, **រស្សៈ**, **គរុ**, **លហុ**, **និគ្គហិត**, **វិមុត្ត**, **សម្ពន្ធៈ** និង **ववត្ថិតៈ** ។

ព្យញ្ជនៈទី ១ ទី ៣ ក្នុងវគ្គៈទាំង ៥ គឺ **កគ ចជ ដឌ តទ បព** ១០ តួនេះ ហៅថា **សិថិល** “មានសំឡេងធូរស្រាល” ។

ព្យញ្ជនៈទី២ ទី៤ ក្នុងវគ្គៈទាំង ៥ គឺ **ខឃ ឆឈ ឋឍ ថធ**

**ផត** ១០ តួនេះ ហៅថា **ធនិត** "មានសំឡេង តឹងខ្លាំង" ព្រោះមានតួ **ហ** ផ្សំចូល ដូចជា **ក** + **ហ** > **ក្ហ** = **ខ**, **គ** + **ហ** > **គ្ហ** = **ឃ**, **ច** + **ហ** > **ច្ហ** = **ឆ**, **ជ** + **ហ** > **ជ្ហ** = **ឈ ។ល។ ព** + **ហ** > **ព្ហ** = **ភ** ។

ស្រះទីឃៈ និងស្រះរស្សៈ ដែលមានព្យញ្ជនៈតម្រួតគ្នានៅខាងចុង ឬ ដែលមាននិគ្គហិតអាស្រ័យផង ដូចជា **អាការោ សម្មាសម្ពុទ្ធោ តស្សា** យ៉ាងនេះហៅថា **គរុ** "ធ្ងន់" ត្រូវពោល បង្អង់ឱ្យយូរ ។

ស្រះរស្សៈដែលមិនមានព្យញ្ជនៈតម្រួតនៅខាងចុង ឬដែលមិនមាន និគ្គហិតអាស្រ័យផងទេ ដូចជា **ឥតិបិ បរិវិសុទ្ធ** យ៉ាងនេះហៅថា **លហុ** "ស្រាល" ត្រូវពោលឱ្យឆាប់រហ័ស ។

អក្ខរៈដែលវេលានឹងពោល មានសំឡេងដូចជាប្រកបនឹងតួ **ង** ឬ **ម** នៅខាងចុង ដូចជា **ពុទ្ធំ ធម្មំ សង្ឃំ, ពុទ្ធ័ម, ធម្ម័ម, សង្ឃ័ម**, យ៉ាងនេះ ហៅថា **និគ្គហិត** ។

អក្ខរៈដែលវេលាពោល ត្រូវបង្ហើបមាត់ឱ្យហើបលើសជាងប្រក្រតីបន្តិច ដូចជា **ធាណា ថេរោ ឱវាទោ ឯសា ញត្តិ** យ៉ាងនេះ ហៅថា **វិមុត្ត** ។

បទសន្ធិ ដូចជា **តត្រាយមាទិ** យ៉ាងនេះ ហៅថា **សម្ពន្ធៈ** ត្រូវពោល ឱ្យជាប់គ្នាជាបទ ១ កុំឱ្យពោលដាច់ពីគ្នា ។ បទដែលកាត់ញែកចេញពីបទ **សន្ធិ** ដូចជា **តត្រ អយំ អាទិ** យ៉ាងនេះ ហៅថា **ឧទត្តិតៈ** ព្រោះត្រូវកាត់បទដើម្បីនឹងប្រែឱ្យដឹងសេចក្តី ។

## ចប់អក្ខរវិធី

## ២-នាម

**នាម** អ្វីៗ ទាំងពួងដែលមានឈ្មោះហៅបាន ដូចពាក្យថា **មនុស្ស សត្វ ដី ទឹក** ជាដើម ហៅថា **នាម** ប្រែថា ឈ្មោះ ។

## នាមសព្ទ

សំឡេងដែលលាន់ចេញចំពោះនាម ដូចពាក្យថា **ប្រុស ស្រី** ជាដើម ហៅថា **នាមសព្ទ** ប្រែថា សំឡេងគឺសំដីសម្តែងនូវឈ្មោះ មាន ៣ យ៉ាងគឺ : **នាមនាម ១ គុណនាម ១ សព្វនាម ១** ។

## នាមនាម

នាមដែលជាឈ្មោះអ្វីទាំងពួង ដូចពាក្យថា **មនុស្ស សត្វ ស្រែ ស្រុក** ជាដើម ហៅថា **នាមនាម** មានពីរយ៉ាងគឺ :

**១-សាធារណនាម** នាមដែលគ្រាន់តែសម្តែងឈ្មោះ នៅទូទៅទៀតបាន ដូចពាក្យថា **មនុស្ស ដែន ក្រុង** ជាដើម ។

**២-អសាធារណនាម** នាមដែលសម្តែងឈ្មោះប្រាកដ មិនទូទៅទៀតបាន ដូចពាក្យថា **ភិក្ខុធម្មរក្ខិត ដែនកម្ពុជៈ ក្រុងសាវត្ថី** ជាដើម ។

## គុណនាម

នាមដែលសម្តែងលក្ខណៈរបស់នាមនាមណាមួយ ឱ្យដឹងថា

ល្អ អាក្រក់ ដូចពាក្យថា **ខ្មៅ ស វែង ខ្លី** ជាដើម ហៅថា **គុណនាម** មាន ៣ គឺ :

**១_បកតិគុណនាម** គុណនាមដែលសម្តែងលក្ខណៈមិនមានវិសេសប្លែកជាងប្រក្រតី ដូចពាក្យថា **កាឡ** ខ្មៅ, **ឱទាត** ស ជាដើម ។

**២_វិសេសគុណនាម** គុណនាមដែលសម្តែងលក្ខណៈវិសេសប្លែកជាងប្រក្រតី ដូចពាក្យថា **កាឡតរ** ខ្មៅប្លែក ខ្មៅជាង **ឱទាតតរ** សប្លែក សជាង ជាដើម ។

**៣_អតិវិសេសគុណនាម** គុណនាមដែលសម្តែងលក្ខណៈវិសេសប្លែកបំផុត ដូចពាក្យថា **អតិកាឡ** ឬ **អតិវិយកាឡ** ខ្មៅណាស់, ខ្មៅពេកណាស់, **អច្ចោទាត** ឬ **ឱទាតតម** សណាស់, សពេកណាស់, សក្បុស, សស្គុស, ជាដើម ។

## សព្វនាម

នាមសម្រាប់ប្រើជំនួស ឬ ជំនួយនាមនាម ហៅថា **សព្វនាម** មាន ២ យ៉ាងគឺ : **បុរិសសព្វនាម ១ វិសេសនសព្វនាម ១** ។




# លិង្គ

ភេទសម្រាប់សំគាល់នាមសព្ទ ដែលមានអាការប្លែកៗ គ្នា ហៅថា **លិង្គ** មាន ៣ យ៉ាងគឺ : **បុំលិង្គ** “ភេទប្រុស” ១, **ឥត្ថីលិង្គ** “ភេទស្រី” ១, **នបុំសកលិង្គ** “មិនមែនភេទប្រុស ឬ ស្រី” ១, ។

បើកំណត់តាមកំណើត និងសន្មត មាន ២ យ៉ាងគឺ :

**១-ជាតិលិង្គ** លិង្គដែលកំណត់តាមកំណើត ដូចពាក្យថា **បុរិសោ** “ប្រុស” នេះជាបុំលិង្គ, **ឥត្ថី** “ស្រី” នេះជាឥត្ថីលិង្គ, **វត្ថំ** “សំពត់” នេះជានបុំសកលិង្គ ។

**២-សម្មតិលិង្គ** លិង្គដែលកំណត់ដោយសន្មត ខុសទំនងអំពី

កំណើត ដូចពាក្យថា **ទារោ** "ប្រពន្ធ" ជាស្រី តែសន្មតថា **បុំលិង្គ** ទៅវិញ ជាដើម ។

## នាមសព្ទមានលិង្គផ្សេងគ្នា

នាមនាមក្នុងរូបសព្ទមួយៗ ប្រព្រឹត្តទៅបានតែលិង្គ ១ ដែលហៅថា **ឯកលិង្គិកៈ** ក៏មាន ដូច **អមរោ** "ទេវតា", **អច្ឆរា** "ស្រីអប្សរ", **អង្គំ** "អង្គ, អវយវៈ, ហេតុ" ជាដើម, ប្រព្រឹត្តទៅបានលិង្គ ២ ហៅថា **ទ្វិលិង្គិកៈ** ក៏មាន ក្នុងបុំលិង្គ និងនបុំសកលិង្គ ដូច **អក្ខរោ**, **អក្ខរំ**, "អក្សរ, និព្វាន" ជាដើម, ឬគ្រាន់ តែផ្លាស់ស្រះទីបំផុតឱ្យខុសគ្នាទៅជា **ទ្វិលិង្គិកៈ** ក៏មាន ក្នុងបុំលិង្គ និង ឥត្ថីលិង្គ ដូច **អាជីវកោ**, **អាជីវិកា** "អាជីវក, អាជីវិកា" ជាដើម ។ ឯគុណនាម និងសព្វនាមប្រព្រឹត្តទៅបានទាំង ៣ លិង្គ ហៅថា **តិលិង្គិកៈ** ដូចជា **កម្មការោ**, **កម្មការិនី**, **កម្មការំ** "អ្នកធ្វើការ" **យោ**, **យា**, **យំ** "ឯណា" ជាដើម ។

## វចនៈ

ពាក្យសម្រាប់ប្រាប់ចំនួនឱ្យដឹងថា តិច ឬច្រើន ហៅថា **វចនៈ** មាន ២ យ៉ាងគឺ :

**១_ឯកវចនៈ** ប្រាប់ចំនួនតិច ដូចពាក្យថា **បុរិសោ** "ប្រុស"

( ម្នាក់ ) ។

**២-ពហុវចនៈ** ប្រាប់ចំនួនច្រើន ដូចពាក្យថា **បុរិសា** "ប្រុស" ( ច្រើននាក់ ) តែត្រូវថា "ទាំងឡាយ" ជំនួសពាក្យថា ច្រើន ។

## វិភត្តិ

ការចែកនាមសព្ទមួយៗ ឱ្យមានទីបំផុតខាងចុងផ្សេងៗ គ្នា ដើម្បីនឹងប្រើអាយតនិបាត គឺសព្ទសម្រាប់តពាក្យឱ្យកើតជាសេចក្ដីស្ដាប់បាន ហៅថា **វិភត្តិ** ។ វិភត្តិនោះ បើរាប់រៀងតួ មាន ១៤ តួ, បើរាប់តាមឈ្មោះមាន ៧ ។

## វិភត្តិ និង ពាក្យប្រែ

| **ឯកវចនៈ** | **ពហុវចនៈ** |
|---|---|
| .ទី១ **បឋមា សិ** ប្រែថា "វី..." | **យោ** ប្រែថា "វី...ទ., " |
| .ទី២ **ទុតិយា ំ** ប្រែថា " នូវ..., កាន់..., ញុំាង..., អស់.., នឹង..., ចំពោះ...," | **យោ** ប្រែថា " នូវ...ទ., កាន់..ទ., ញុំាង..ទ., អស់...ទ, នឹង...ទ., ចំពោះ...ទ.," |
| .ទី៣ **តតិយា នា** ប្រែថា "ដោយ.., ដោយនូវ..., តាម..., ខាង..., គឺ..., ដែល..., ត្រូវ..., ហេតុ..., | **ហិ** ប្រែថា "ដោយ...ទ, ដោយនូវ...ទ., តាម...ទ., ខាង...ទ., គឺ...ទ., ដែល..ទ., |

ព្រោះ..., ព្រោះតែ..., មាន..."

.ទី៤ **ចតុត្ថី ស** ប្រែថា "ដល់..., ដើម្បី..., បំរុង..., នឹង..., ចំពោះ...,"

.ទី៥ **បញ្ចមី ស្មា** ប្រែថា "អំពី..., ចាក..., ជាង..., ហេតុ..., ព្រោះ..., ព្រោះតែ...,"

.ទី៦ **ឆដ្ឋី ស** ប្រែថា "នៃ..., របស់..., កាល..., កាលបើ..., កាលដែល..., ជំនុំ..., បណ្តា...,"

.ទី៧ **សត្តមី ស្មឹ** ប្រែថា "ក្នុង..., ឰដ៏..., ត្រង់..., នា..., នាកាល..., កាលបើ..., កាលដែល..., និមិត្ត..., ជំនុំ..., បណ្តា..., លើ..., ទៀប..., ជិត...,"

.ទី៨ **អាលបនៈ សិ** ប្រែថា "បពិត្រ.., ម្នាល..., នៃ..., ហៃ...," ។

ត្រូវ..ទ., ហេតុ..ទ., ព្រោះ..ទ., ព្រោះតែ...ទ., មាន...ទ.,"

**នំ** ប្រែថា "ដល់...ទ., ដើម្បី..ទ., បំរុង..ទ., នឹង..ទ., ចំពោះ..ទ.,"

**ហិ** ប្រែថា " អំពី..ទ., ចាក..ទ., ជាង..ទ., ហេតុ..ទ., ព្រោះ..ទ., ព្រោះតែ...ទ.,"

**នំ** ប្រែថា " នៃ..ទ., របស់..ទ., កាល...ទ., កាលបើ...ទ., កាលដែល...ទ., ជំនុំ...ទ., បណ្តា...ទ.,"

**សុ** ប្រែថា "ក្នុង...ទ., ឰដ៏...ទ., ត្រង់...ទ., នា...ទ., នាកាល...ទ., កាលបើ...ទ., កាលដែល...ទ., និមិត្ត...ទ., ជំនុំ...ទ., បណ្តា...ទ., លើ...ទ., ទៀប...ទ., ជិត...ទ.,"

**យោ** ប្រែថា "បពិត្រ...ទ., ម្នាល..ទ., នៃ..ទ., ហៃ..ទ.,"។

## ការន្ត

ស្រះទីបំផុតនៃនាមសព្ទដែលប្រព្រឹត្តទៅក្នុងលិង្គទាំងបី ហៅថា **ការន្ត** ។ ការន្តនោះ ក្នុងបុំលិង្គមាន ៥ គឺ : **អ ឥ ឦ ឧ ឩ** ក្នុងឥត្ថីលិង្គមាន ៥ គឺ: **អា ឥ ឦ ឧ ឩ** ក្នុងនបុំសកលិង្គ មាន ៣ គឺ : **អ ឥ ឧ** រួមជា ១៣ បើរាប់ **ឱ** ការន្ត បញ្ចូលផងជា ១៤ ។

## វិធីបំបែកនាមសព្ទ

**នាមសព្ទ** សុទ្ធតែមានការន្តជាគ្រឿងសំគាល់ មានវិធីបំបែកផ្សំនឹងវិភត្តិត្រូវគ្នាខ្លះ ផ្សេងគ្នាខ្លះ ។ **នាមនាម** និង **គុណនាម** បើមានការន្តដូចគ្នាជាលិង្គណា ក៏មានវិធីបំបែកត្រូវគ្នាជាលិង្គនោះ វៀរលែងតែសព្ទដែលមានវិធីបំបែកផ្សេងដោយឡែកនោះចេញ ឯសព្វនាមមានវិធីបំបែកប្លែកពីនាមនាម និងគុណនាមដោយច្រើន ។

### អ ការន្ត បុំលិង្គ បំបែកយ៉ាង បុរិស "ប្រុស" ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| បឋមា | **បុរិសោ** | **បុរិសា** |
| ទុតិយា | **បុរិសំ** | **បុរិសេ** |
| តតិយា | **បុរិសេន** | **បុរិសេហិ, បុរិសេភិ** |
| ចតុត្ថី | **បុរិសស្ស, បុរិសាយ, បុរិសត្ថំ** | **បុរិសានំ** |

| | | |
|---|---|---|
| បញ្ចមី | បុរិសស្មា, បុរិសម្ហា, បុរិសា | បុរិសេហិ, បុរិសេភិ |
| ឆដ្ឋី | បុរិសស្ស | បុរិសានំ |
| សត្តមី | បុរិសស្មឹ, បុរិសម្ហិ, បុរិសេ | បុរិសេសុ |
| អាលបន | បុរិស | បុរិសា |

## អ ការន្ត បុំលិង្គ បំបែកតែស្រះ ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ោ | ា |
| ទុ. | ំ | េ |
| ត. | េន | េហិ, េភិ, |
| ច. | ស្ស, ាយ, ត្ថំ | ានំ |
| បញ្ច. | ស្មា, ម្ហា, ា | េហិ, េភិ, |
| ឆ. | ស្ស, | ានំ, |
| ស. | ស្មឹ, ម្ហិ, េ | េសុ, |
| អា. | | ា |

## ឆេក បុរិស "ប្រុសឈ្លាស" បំបែកដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ឆេកោ បុរិសោ | ឆេកា បុរិសា |
| ទុ. | ឆេកំ បុរិសំ | ឆេកេ បុរិសេ |

| | | |
|---|---|---|
| ត. | ឆេកេន បុរិសេន | ឆេកេហិ បុរិសេហិ, ឆេកេភិ បុរិសេភិ |
| ច. | ឆេកស្ស បុរិសស្ស, ឆេកាយ បុរិសាយ, ឆេកត្ថំ, បុរិសត្ថំ, | ឆេកានំ បុរិសានំ |
| បញ្ច. | ឆេកស្មា, បុរិសស្មា, ឆេកម្ហា បុរិសម្ហា, ឆេកា បុរិសា, | ឆេកេហិ បុរិសេហិ, ឆេកេភិ បុរិសេភិ |
| ឆ. | ឆេកស្ស បុរិសស្ស | ឆេកានំ បុរិសានំ |
| ស. | ឆេកស្មឹ បុរិសស្មឹ, ឆេកម្ហិ បុរិសម្ហិ, ឆេកេ បុរិសេ, | ឆេកេសុ បុរិសេសុ |
| អា. | ឆេក បុរិស | ឆេកា បុរិសា |

## វាក្យសព្ទជា អ ការន្ត បុំលិង្គ

| នាមនាម | | គុណនាម | |
|---|---|---|---|
| ពុទ្ធ | ព្រះពុទ្ធ | អគ្គ | ប្រសើរ |
| ធម្ម | ព្រះធម៌ | បវរ | បវរ, ប្រសើរ |
| សង្ឃ | ព្រះសង្ឃ | ឆេក | ប៉ិនប្រសប់, ឈ្លាស |
| អាចរិយ | អាចារ្យ | ពាល | ល្ងង់ |
| សិស្ស | សិស្ស | មហន្ត | ធំ |

| | |
|---|---|
| **សាវក** | សាវ័ក |
| **បសាទ** | សេចក្ដីជ្រះថ្លា |
| **គារវ** | សេចក្ដីគោរព |
| **អាវាស** | អាវាស, ឬវត្ត |
| **កាយ** | រាងកាយ |
| **ហត្ថ** | ដៃ |
| **បាទ** | ជើង |
| **កេស** | សក់ |
| **លោម** | រោម |
| **នខ** | ក្រចក |
| **ទន្ត** | ធ្មេញ, ភ្លុក |
| **តច** | ស្បែក |
| **កុក្កុដ** | មាន់ |
| **សូករ** | ជ្រូក |
| **សុនខ** | ឆ្កែ |
| **អាហារ** | អាហារ |
| **មញ្ច** | គ្រែ |

| | |
|---|---|
| **ខុទ្ទក** | តូច |
| **ទីឃ** | វែង |
| **រស្ស** | ខ្លី |
| **ឧណ្ហ** | ក្ដៅ |
| **សីត** | ត្រជាក់ |
| **ឧច្ច** | ខ្ពស់ |
| **នីច** | ទាប |
| **ជិណ្ណ** | ចាស់ |
| **នវ** | ថ្មី |
| **កាឡ** | ខ្មៅ |
| **សេត** | ស |
| **មហល្លក** | ចាស់ |
| **ទហរ** | ក្មេង |
| **អប្ប** | តិច |
| **ពហុក** | ច្រើន |
| **កិស** | ស្គម |
| **ថុល្ល** | ធាត់ |

| | |
|---|---|
| រុក្ខ ឈើ | នីល ខៀវ |
| គាម ស្រុក | រត្ត ក្រហម |

## របៀបរៀនភាសាបាលី

បទគុណនាម មិនប្រែចេញពាក្យអាយតនិបាតទេ តែត្រូវមានលិង្គ វចនៈ វិភត្តិ ស្មើគ្នានឹងនាមនាមជាម្ចាស់ ហើយត្រូវរៀងទុកខាងដើមនាមនាម ជាដរាប ។ ខ្មែរថា "បុរស ឈ្លាស" បាលីថា "ឈ្លាស បុរស" **ឆេកោ បុរិសោ** ។ ខ្មែរថា "របស់បុរស ឈ្លាស" បាលីថា "ឈ្លាស របស់បុរស" **ឆេកស្ស បុរិសស្ស** ។ ម្យ៉ាងទៀត ការរៀបរៀងភាសាបាលី ត្រូវរៀងផ្ទុយពី ភាសាខ្មែរ ដូចពាក្យថា "សាវកទ. របស់ព្រះពុទ្ធ" ត្រូវរៀងបាលី ថា **ពុទ្ធស្ស សាវកា**, "ទារកទ. ក្នុងស្រុក" ត្រូវរៀងបាលីថា **គាមេ ទារកា** ដូច្នេះជាដើម ។

## សំហាត់ប្រែជាភាសាខ្មែរ

| | |
|---|---|
| ១. អគ្គោ ពុទ្ធោ | ៦. ពុទ្ធស្ស ធម្មោ |
| ២. ឋបវរេ ធម្មេ | ៧. ធម្មេ បសាទោ |
| ៣. ឆេកា សិស្សា | ៨. អាចរិយានំ សិស្សា |
| ៤. ខុទ្ទោ រុក្ខោ | ៩. សង្ឃស្មឹ គារវោ |
| ៥. កាឡា កេសា | ១០. សង្ឃស្ស មហន្តោ អាវាសោ ។ |

## លំហាត់ប្រែជាភាសាបាលី

១. អាចារ្យ ឈ្លាស
២. សិស្សទ. ល្ងង់
៣. ព្រះធម៌ ដ៏បវរ
៤. អាវាស ធំ
៥. ក្នុងស្រុក តូច
៦. សាវ័កទ. របស់ព្រះពុទ្ធ
៧. សេចក្តីគោរព ក្នុងព្រះធម៌
៨. អាវាស របស់ព្រះសង្ឃ
៩. សេចក្តីជ្រះថ្លា ក្នុងព្រះពុទ្ធ
១០. សិស្សទ. ឈ្លាស របស់អាចារ្យ ។

## របៀបប្រែ

.ការប្រែពីបាលីមកជាខ្មែរ សូមពិនិត្យមើលថា : សព្ទទាំងនោះប្រកបដោយវិភត្តិអ្វី ? វចនៈណា ? អាយតនិបាតប្រែដូចម្តេចខ្លះ ? បើប្រយោគមិនមាន អាលបនៈ និងនិបាតទេ ត្រូវប្រែបឋមាវិភត្តិ " វី..." មុន ទើបប្រែបទដទៃតាមលំដាប់ ប៉ុន្តែសំដៅសេចក្តី ជាប្រមាណ ដូចជា "**ពុទ្ធស្ស ធម្មោ**" សូមពិចារណាថា **ពុទ្ធស្ស** ជាចតុត្ថីផង ជាឆដ្ឋីផង គួរប្រែតាមវិភត្តិណា ទើបស្តាប់សេចក្តីបានល្អ ។

.ការប្រែពីខ្មែរមកជាបាលី ត្រូវចាំសព្ទ ការន្ត លិង្គ វិភត្តិ វចនៈ និងអាយតនិបាត ឲ្យបានស្ទាត់ ដូចពាក្យខ្មែរថា : "សាវ័កទ. របស់ព្រះ-ពុទ្ធ" ។ សាវ័កបំបែកដូចអ្វី ? ជាវិភត្តិ វចនៈអ្វី ? ពាក្យ "ទាំងឡាយ" ប្រាប់ឲ្យដឹងថា ពហុវចនៈ , ពាក្យថា " វី..." ខ្មែរមិនដែលនិយាយទេ ប៉ុន្តែអាចដឹងថា ពាក្យប្រែមុនគេ ពាក្យនោះជាបទប្រធាន គឺ បឋមា-

វិភត្តិ, ឯពាក្យថា "នៃ- របស់-" ជាឆដ្ឋីវិភត្តិ ឯកវចនៈ គឺ **ពុទ្ធស្ស** ។ ខ្មែរថា សាវ័កទ., បាលីថា **សាវកោ** ។ ខ្មែរថា របស់ព្រះពុទ្ធ, បាលីថា **ពុទ្ធស្ស** ។ ប៉ុន្តែ របៀបរៀនបាលី ឱ្យរៀបរៀងថា **ពុទ្ធស្ស សាវកោ** ។ល។

## កិរិយាសព្ទប្រាប់បច្ចុប្បន្នកាល

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| បឋម | **តិ** | **អន្តិ** |
| មជ្ឈិម | **សិ** | **ថ** |
| ឧត្តម | **មិ** | **ម** |

### បច " ចំអិន "

| បុរិសៈ ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ( **សោ, សា, តំ**[១] ) **បចតិ** | ( **តេ, តា, តានិ** ) **បចន្តិ** |
| ម. ( **ត្វំ** ) **បចសិ** | ( **តុម្ហេ** ) **បចថ** |
| ឧ. ( **អហំ** ) **បចាមិ** | ( **មយំ** ) **បចាម** |

---

(១) **តំ** សព្ទ បុរិសសព្វនាម នបុំ, ត្រង់បឋមាវិភត្តិ មិនសូវមានច្រើនទេ ។

## កិរិយាសព្ទ តទៅនេះបំបែកដូច " បច "

| | | | |
|---|---|---|---|
| គច្ឆតិ | ទៅ, ដល់ | អាគច្ឆតិ | មក |
| តិដ្ឋតិ | ឋិតនៅ, ឈរនៅ | អាវសតិ | អាស្រ័យនៅ |
| និសីទតិ | អង្គុយ | អាហរតិ | នាំមក |
| សយតិ | ដេក | កីឡតិ | លេង |
| ចរតិ | ត្រាច់ទៅ | វសតិ | នៅ |

## វាក្យសព្ទជា អ ការន្ត បុំលិង្គ

| នាមនាម | | គុណនាម | |
|---|---|---|---|
| មនុស្ស | មនុស្ស | រត្ត | ក្រហម |
| នរ | ជន | លោហិត | ក្រហម |
| ទាស | ខ្ញុំប្រុស | បីត | លឿង |
| មិត្ត | មិត្ត, សំឡាញ់ | នីល | ខៀវ |
| បុត្ត | កូនប្រុស | សម | ស្មើ |
| កុមារ | ក្មេងប្រុស | វិសម | មិនស្មើ |
| កសក | អ្នកស្រែ | សោភណ | ល្អ |
| វាណិជ | ឈ្មួញ | បាប | អាក្រក់ |
| វេជ្ជ | ពេទ្យ | អប្ប | តិច |

| | |
|---|---|
| ចោរ | ចោរ |
| សុរិយ | ព្រះអាទិត្យ |
| ចន្ទ | ព្រះចន្ទ |
| ទេវ | ទេវតា |
| លោក | លោក |
| អាកាស | អាកាស |
| អស្ស | សេះ |
| គោណ | គោ |
| សកុណ | សត្វស្លាប |
| កាក | ក្អែក |
| សស | ទន្សាយ |

| | |
|---|---|
| ពហុក | ច្រើន |
| ឧជុក | ត្រង់ |
| វង្ក | វៀច |
| មុទុក | ទន់ភ្លន់ |
| កក្ខល | រឹងរូស |
| ចណ្ឌ | កាច |
| ឧត្តម | ឧត្តម |
| អនេក | ច្រើន |
| បវរ | បវរ, ប្រសើរ |
| លាមក | អាក្រក់ |
| កល្យាណ | ល្អ |

## លំហាត់ប្រែជាភាសាខ្មែរ

១-បុរិសោ គាមំ គច្ឆតិ ។

២-មនុស្សា សង្ឃំ បស្សន្តិ ។

៣-ពុទ្ធោ ធម្មំ ភាសតិ ។

៤-ត្វំ គាមេ វសសិ ។

៥-មយំ អាវាសេ វសាម ។

៦-ទារកា គាមេ កីឡន្តិ ។

៧-សុនខោ អាវាសេ ធាវតិ ។

៨-អហំ អាហារំ ភុញ្ជាមិ ។

៩-តុម្ហេ មញ្ចេ និសីទថ ។

១០-សូករា គាមេ តិដ្ឋន្តិ ។

# លំហាត់ប្រែជាភាសាបាលី

១. ខ្ញុំ ទៅ វត្ត ។

២. លោកអាចារ្យ សម្តែង ធម៌ ។

៣. យើងទ. បរិភោគ អាហារ ។

៤. អ្នកទ. នៅ ក្នុងស្រុក ។

៥. សិស្សទ. ទៅ វត្ត ។

៦. រាងកាយ របស់បុរស ខ្ពស់ ។

៧. រោមវែង របស់ជ្រូក ។

៨. ខ្ញុំ អង្គុយ លើគ្រែ ។

៩. ព្រះសង្ឃ នៅ ក្នុងវត្ត ។

១០. យើងទ. លេង ក្នុងស្រុក ។

**កំណត់ចំណាំ :**

កិរិយាសព្ទ ច្រើនរៀងទុកនៅខាងចុងប្រយោគ ដូចជា **សោ គច្ឆតិ , តេ គច្ឆន្តិ , ត្វំ គច្ឆសិ , តុម្ហេ គច្ឆថ , អហំ គច្ឆាមិ , មយំ គច្ឆាម ,** ។

ក្នុងប្រយោគសួរ ប្រយោគអង្វរករ ប្រយោគបង្គាប់ លោករៀងកិរិយាសព្ទនៅខាងដើមវិញ ដូចជា **បស្សសិ អាវុសោ ឬ សុណាតុ មេ ភន្តេ សង្ឃោ ឬ ភវតុ សព្វមង្គលំ** ជាដើម ។

ធាតុ ៤ គឺ : **ភូ, ហុ, អស, ជន,** ប្រែថា "កើត, មាន, ជា" ។

# អស_ធាតុ វត្តមានាវិភត្តិ

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. (សោ, សា) | អត្ថិ | (តេ, តា) អត្ថិ, សន្តិ |
| ម. (ត្វំ) | អសិ | (តុម្ហេ) អត្ថ |
| ឧ. (អហំ) | អម្ហិ | (មយំ) អម្ហ |

## លំហាត់ប្រែជាភាសាខ្មែរ

| | |
|---|---|
| ១_អហំ ឆេកោម្ហិ (ឆេកោ អម្ហិ)។ | ៦_សុនខា ចណ្ឌា ហោន្តិ ។ |
| ២_ត្វំ មនុស្សោសិ (មនុស្សោ អសិ)។ | ៧_ ចោរោ លាមកោ ហោតិ ។ |
| ៣_មយំ កសកម្ហ (កសកា អម្ហ)។ | ៨_អាហារោ គេហេ អត្ថិ។ |
| ៤_តុម្ហេ វេជ្ជត្ថ (វេជ្ជា អត្ថ) ។ | ៩_វេជ្ជា គាមេ អត្ថិ ។ |
| ៥_មិត្តោ កល្យាណោ ហោតិ ។ | ១០_សកុណា អាកាសេន គច្ឆន្តិ។ |

## បំពេញពាក្យបាលី ត្រង់ចន្លោះ

| | |
|---|---|
| ១_ ...... ឆេកោម្ហិ ។ | (ខ្ញុំ) ជាអ្នកឈ្លាស ។ |
| ២_សុនខា ...... ហោន្តិ ។ | សុនខទ. ជាសត្វ (កាច) ។ |
| ៣_អហំ ..... គច្ឆាមិ ។ | ខ្ញុំទៅ (តាមផ្លូវ) ។ |
| ៤_សោ គោណំ ..... ។ | គាត់ (រក្សា) នូវគោ ។ |
| ៥_.... ឆេកោ ឧបជ្ឈាយោ ។ | ឧបជ្ឈាយ៍ ឈ្លាស (របស់សិស្សទ.)។ |

| | |
|---|---|
| ៦. ....... បសាទោ ។ | សេចក្តីជ្រះថ្លា (ក្នុងធម៌) ។ |
| ៧. សង្ឃេ ....... ។ | (សេចក្តីគោរព) ក្នុងព្រះសង្ឃ។ |
| ៨. ..... អាវាសេ វសាម ។ | (យើងទ.) នៅ ក្នុងអាវាស ។ |
| ៩. ជនា ខុទ្ទកេ ..... និសីទន្តិ ។ | ជនទ. អង្គុយ (លើគ្រែ) តូច ។ |
| ១០. ឧច្ចេ រុក្ខេ ........ ។ | (សត្វស្លាប) លើដើមឈើ ខ្ពស់។ |

## លំហាត់ប្រែជាភាសាបាលី

| | |
|---|---|
| ១. ខ្ញុំ ជាអ្នកស្រែ ។ | ៦. គ្រែទ. មាន ក្នុងផ្ទះ ។ |
| ២. ឯង ជាពេទ្យ ។ | ៧. សេះទ. បោល តាមផ្លូវ ។ |
| ៣. យើងទ. ជាអ្នកល្អ ។ | ៨. ឆ្កែកាច ដេក ជិតផ្លូវ ។ |
| ៤. ចោរទ. ជាអ្នកកាច ។ | ៩. គោទ. ជាសត្វល្អ ។ |
| ៥. ពេទ្យ ជាអ្នកល្អ ។ | ១០. អ្នកទ. ជាអ្នកស្រែ ។ |

## បាល " រក្សា " បំបែកជួច្នេះ

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | (សោ, សា, តំ) បាលេតិ | (តេ, តា, តានិ) បាលេន្តិ |
| ម. | (ត្វំ) បាលេសិ | (តុម្ហេ) បាលេថ |
| ឧ. | (អហំ) បាលេមិ | (មយំ) បាលេម |

## កិរិយាសព្ទ ខាងក្រោមនេះ បំបែកដូច "បាល"

| | | | |
|---|---|---|---|
| ជាលេតិ | បំភ្លឺ | បូជេតិ | បូជា |
| មារេតិ | សម្លាប់ | ឧឌ្ឌេតិ | ហើរឡើង |
| ឱលោកេតិ | រមិលមើល | បិឡេតិ | បៀតបៀន |
| ទេសេតិ | សម្តែង | ចោរេតិ | លួច |
| ចិន្តេតិ | គិត | ឧទេតិ | រះឡើង |
| ឃាតេតិ | ទម្លាក់ | ឋបេតិ | ដាក់, តម្កល់ |

## លំហាត់ប្រែជាភាសាខ្មែរ

| | |
|---|---|
| ១_គោណា មគ្គេ តិដ្ឋន្តិ ។ | ៦_កុមារោ សូករេ ឃាលេតិ ។ |
| ២_មនុស្សា ចន្ទំ បស្សន្តិ ។ | ៧_ចោរា អស្សេ ចោរេន្តិ ។ |
| ៣_កាកា រុក្ខេ និសីទន្តិ ។ | ៨_តុម្ហេ ធម្មំ បូជេថ ។ |
| ៤_មយំ គោណេ ហរាម ។ | ៩_មនុស្សា អាកាសេ សុរិយំ ឱលោកេន្តិ។ |
| ៥_សុនខា គេហំ ធាវន្តិ។ | ១០_អាចរិយោ សិស្សានំ ធម្មំ ទេសេតិ។ |

## បំពេញពាក្យបាលី ត្រង់ចន្លោះ

| | |
|---|---|
| ១_ ..... គោណេ ឃាលេន្តិ ។ | (កុមារទ.) រក្សា នូវគោទ. ។ |
| ២_មនុស្សា ...... បូជេន្តិ ។ | មនុស្សទ. បូជា (នូវធម៌) ។ |
| ៣_កុមារោ សុរិយំ ...... ។ | កុមារ (មើល) នូវព្រះអាទិត្យ ។ |

| | |
|---|---|
| ៤_ចោរោ ...... ចោរេតិ ។ | ចោរ លួច (នូវជ្រូកទ.) ។ |
| ៥_វេជ្ជោ កុមារេ ...... ។ | គ្រូពេទ្យ (រក្សា) នូវកុមារទ. ។ |
| ៦_ ......គោណេ ហរាម ។ | (យើងទ.) នាំទៅ នូវគោទ. ។ |
| ៧_......មហន្តេ ......តិដ្ឋាមិ ។ | (ខ្ញុំ) ស្ថិតនៅ (ក្នុងផ្លូវ) ធំ ។ |
| ៨_សិស្សានំ .... មញ្ចេ ....។ | (អាចារ្យ) របស់សិស្សទ. (អង្គុយ) លើគ្រែ ។ |
| ៩_សុនខោ ខុទ្ទកំ សូករំ ....។ | សុនខ (បៀតបៀន) នូវជ្រូកតូច។ |
| ១០_មនុស្សា គារវេន ....បូជេន្តិ។ | មនុស្សទ. បូជា (ចំពោះព្រះ-ពុទ្ធ) ដោយសេចក្តីគោរព ។ |

## លំហាត់ប្រែជាភាសាបាលី

១_ អ្នកស្រែ ថែរក្សា គោទ. ។

២_ សត្វស្លាបទ. ទំ លើដើមឈើ ។

៣_ ចោរ សម្លាប់ ឆ្កែ ។

៤_ កុមារទ. តែងលេង ជិតផ្ទះ ។

៥_ គ្រែទ. មាន ក្នុងផ្ទះ ។

៦_ យើងទ. បូជា ព្រះធម៌ ។

៧_ ចោរ លួច មាន់ទ. ។

៨_ ក្អែកទ. លួច អាហារ ។

៩_ អ្នកទ. រមិលមើល ព្រះចន្ទ ឰដ៏អាកាស ។

១០_ ទេវតាទ. ថែរក្សា មនុស្សទ. ក្នុងលោក ។

## ឥ ការន្ត បុំលិង្គ បំបែកយ៉ាង មុនិ "អ្នកប្រាជ្ញ" ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | មុនិ | មុនយោ, មុនី |
| ទុ. | មុនឹ | មុនយោ, មុនី |
| ត. | មុនិនា | មុនីហិ, មុនីភិ |
| ច. | មុនិស្ស, មុនិនោ | មុនីនំ |
| បញ្ច. | មុនិស្មា, មុនិម្ហា, មុនិនា | មុនីហិ, មុនីភិ |
| ឆ. | មុនិស្ស, មុនិនោ | មុនីនំ |
| ស. | មុនិស្មឹ, មុនិម្ហិ | មុនីសុ |
| អា. | មុនិ | មុនយោ, មុនី |

## ឥ ការន្ត បុំលិង្គ បំបែកតែស្រះ ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ិ | । យោ, ី |
| ទុ. | ឹ | ।យោ, ី |
| ត. | ិ នា | ី ហិ, ី ភិ, |
| ច. | ិ ស្ស, ិ នោ | ី នំ |

| | | |
|---|---|---|
| បញ្ច. | ~ិ ស្មា, ~ិ ម្ហា, ~ិ នា | ~ី ហិ, ~ី ភិ, |
| ឆ. | ~ិ ស្ស, ~ិ នោ | ~ី នំ, |
| ស. | ~ិ ស្មឹ, ~ិ ម្ហិ, | ~ី សុ |
| អា. | ~ិ | । យោ, ~ី |

## សព្ទជា ឥ ការន្ត បុំលិង្គ បំបែកដូច " មុនិ "

| | | | |
|---|---|---|---|
| អគ្គិ | ភ្លើង | ព្យាធិ | ជម្ងឺ |
| កវិ | កវី | ឧទធិ | សមុទ្រ |
| ទីបិ | ខ្លាដំបង | គិរិ | ភ្នំ |
| ឥសិ | ឥសី | វីហិ | ស្រូវ |
| អរិ | សត្រូវ | កបិ | ស្វា |
| បតិ | ប្ដី, ម្ចាស់ | អហិ | ពស់ |
| គហបតិ | គហបតី | ញាតិ | ញាតិ |
| អតិថិ | ភ្ញៀវ | អសិ | ដាវ |
| មណិ | កែវមណី | អទ្ទិ | ភ្នំ |
| រាសិ | គំនរ | បាណិ | បាតដៃ |
| ចក្កវត្តិ | ស្ដេចចក្រពត្តិ | និធិ | កំណប់ទ្រព្យ |

## កី "ធាតុ" បំបែកដូច្នេះ

| បុរិស: | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ( សោ, សា ) កីនាតិ | (តេ, តា ) កីនន្តិ |
| ម. | (ត្វំ ) កីនាសិ | ( តុម្ហេ ) កីនាថ |
| ឧ. | (អហំ ) កីនាមិ | (មយំ ) កីនាម |

## កិរិយាសព្ទ ខាងក្រោមនេះបំបែកដូច " កី "

| | | | |
|---|---|---|---|
| វិក្កិណាតិ | លក់, ដូរ | ជានាតិ | ចេះ, ដឹង, ស្គាល់ |
| ឱចិនាតិ | រើស, ប្រមូល | គណ្ហាតិ | កាន់, ចាប់, យក |
| បាបុណាតិ | ដល់, ទាន់ | ធុនាតិ | កំចាត់បង់ |
| ជិនាតិ | ឈ្នះ | ឧគ្គណ្ហាតិ | រៀនយក |
| លុនាតិ | ច្រូត, កាត់ | ចិនាតិ | សន្សំ, បេះ |
| សុណាតិ | ស្តាប់, ឮ | មិនាតិ | ថ្លឹង, វាល់, វាប់ |

## លំហាត់ប្រែជាភាសាខ្មែរ

១_កសកា វីហយោ វិក្កិណន្តិ ។

២_វាណិជោ វីហី កីនាតិ ។

៣_ឆេកា មុនយោ ធម្មំ ជានន្តិ ។

៤_មហល្លកោ ឥសិ មណី គណ្ហាតិ ។

៥_ភាឡា កបយោ គិរិស្មឹ វសន្តិ ៕

៦_កុមារា ភាឡេ កបយោ ឱលោកេន្តិ ៕

៧_អហំ ឆេកស្ស មុនិនោ ធម្មំ សុណាមិ ៕

៨_ទីបយោ មហន្តេ គិរិស្មឹ វសន្តិ ៕

៩_ត្វំ មហន្តេន អសិនា អហឹ មារេសិ ៕

១០_រោគោ កាយេ អត្ថិ ៕

### បំពេញពាក្យបាលី ត្រង់ចន្លោះ

១_ឥសយោ ...... វសន្តិ ៕ _ឥសីទ. នៅ ( លើភ្នំ ) ។

២_មហល្លកោ មនុស្សោ ធម្មំ ....៕ _មនុស្ស ចាស់ (ស្តាប់) នូវធម៌ ។

៣_ញាតយោ .... គណ្ហន្តិ ៕ _ញាតិទ. កាន់យក (នូវកំណប់ទ្រព្យ )។

៤_កុមារា រុក្ខេ .... បស្សន្តិ ៕

_កុមារទ. មើល (ស្វាទ.) លើដើមឈើ ។

៥_កសកោ ..... លុនាតិ ៕ _អ្នកស្រែ ច្រូត (នូវស្រូវទ.) ។

៦_គហបតិនោ បុត្តា ..... ជិនន្តិ ៕

_កូនទ. នៃគហបតី ឈ្នះ ( នូវសត្រូវ )។

៧. ..... ឥសិនោ សិស្សោម្ហិ ៗ .(ខ្ញុំ) ជាសិស្ស របស់ឥសី ។

៨.រោគោ ចាណិម្ហិ ..... ៗ .រោគ (មាន) ក្នុងបាតដៃ ។

៩. ..... គហបតិនោ អគារេ វសន្តិ ៗ

.(ភ្ញៀវទ.) នៅក្នុងផ្ទះ នៃគហបតី ។

១០.គហបតិ វាណិជស្ស .....កីនាតិ ៗ

.គហបតី ទិញ (ស្រូវ) របស់ពាណិជ ។

## លំហាត់ប្រែជាភាសាបាលី

១. អ្នកស្រែ ទិញ ស្វាទ. ។

២. គហបតីទ. រៀនយក ព្រះធម៌ ។

៣. មនុស្សចាស់ ស្តាប់ នូវធម៌ ។

៤. ស្វាទ. នៅ លើដើមឈើ ។

៥. ឥសីទ. តែងចេះ ធម៌ ។

៦.កែវមណី ស្ថិតនៅ ជិតដើមឈើ។

៧. អ្នកស្រែ រក្សា នូវស្វា ។

៨. ពាណិជ ថ្លឹង នូវស្រូវ ។

៩. ភ្ញៀវទ. ទៅ ផ្ទះ គហបតី ។

១០.គហបតី កំចាត់បង់ នូវសត្រូវ។

## ៧) ការន្ត បុំលិង្គ បំបែកយ៉ាង សេដ្ឋី "សេដ្ឋី" ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | សេដ្ឋី | សេដ្ឋិនោ, សេដ្ឋី |
| ទុ. | សេដ្ឋឹ (សេដ្ឋិនំ ) | សេដ្ឋិនោ, សេដ្ឋី |
| ត. | សេដ្ឋិនា | សេដ្ឋីហិ, សេដ្ឋីភិ |
| ច. | សេដ្ឋិស្ស, សេដ្ឋិនោ | សេដ្ឋីនំ |

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| បញ្ច. | សេដ្ឋិស្មា, សេដ្ឋិម្ហា, សេដ្ឋិនា | សេដ្ឋីហិ, សេដ្ឋីភិ |
| ឆ. | សេដ្ឋិស្ស, សេដ្ឋិនោ | សេដ្ឋីនំ |
| ស. | សេដ្ឋិស្មឹ, សេដ្ឋិម្ហិ | សេដ្ឋីសុ |
| អា. | សេដ្ឋិ | សេដ្ឋិនោ, សេដ្ឋី |

## ឦ ការន្ត បុំលិង្គ បំបែកតែស្រះ ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ◌ី | ◌ិ នោ, ◌ី |
| ទុ. | ◌ឹ, ( ◌ិ នំ ) | ◌ិ នោ, ◌ី |
| ត. | ◌ិ នា | ◌ី ហិ, ◌ី ភិ |
| ច. | ◌ិ ស្ស, ◌ិ នោ | ◌ី នំ |
| បញ្ច. | ◌ិ ស្មា, ◌ិ ម្ហា, ◌ិ នា | ◌ី ហិ, ◌ី ភិ |
| ឆ. | ◌ិ ស្ស, ◌ិ នោ | ◌ី នំ |
| ស. | ◌ិ ស្មឹ, ◌ិ ម្ហិ | ◌ី សុ |
| អា. | ◌ិ | ◌ិ នោ, ◌ី |

## សព្ទជា ឦ ការន្ត បុំលិង្គបំបែកដូច "សេដ្ឋី"

| | | | |
|---|---|---|---|
| បក្ខី | សត្វស្លាប | ភោគី | អ្នកមានភោគ |
| ហត្ថី | ដំរីឈ្មោល | បាបការី | អ្នកធ្វើបាប |

| | | | |
|---|---|---|---|
| ករី | ដំរីឈ្មោល | មន្តី | មន្ត្រី |
| សាមី | ប្ដី, ម្ចាស់ | សិខី | ក្ងោក |
| កុដ្ឋី | អ្នកកើតឃ្លង់ | ពលី | អ្នកមានកម្លាំង |
| ទាឋី | សត្វមានចង្កូម | សសី | ព្រះចន្ទ |
| ឆត្តី | អ្នកកាន់ឆត្រ | មាលី | អ្នកមានកម្រងផ្កា |
| សារថី | អ្នកបររថ | គណី | អ្នកមានគណៈ |
| សុខី | អ្នកមានសេចក្ដីសុខ | ទីឃជីវី | អ្នកមានអាយុវែង |

## កិរិយាសព្ទ

| | | | |
|---|---|---|---|
| អាហរតិ | នាំមក | ខាទតិ | ស៊ី, ទំពាស៊ី |
| បហរតិ | ប្រហារ | ទេតិ | ឱ្យ |
| សេតិ | ដេក | អាគច្ឆតិ | មក |

## លំហាត់ប្រែជាភាសាខ្មែរ

១-ហត្ថី រុក្ខេ តិដ្ឋតិ ។

២-បក្ខី រុក្ខេ និសីទតិ ។

៣-សារថិនោ អស្សេ អាហរន្តិ។

៤-មហន្តេ សិខិនោ បស្សាមិ។

៥-ភោគី ទានំ ទេន្តិ។

៦-បាបការី ចុល្លេ ហត្ថី ចោរេតិ។

៧-មន្តិនោ ធម្មំ ចិន្តេន្តិ ។

៨-មហល្លកោ សេដ្ឋី ធម្មំ សុណាតិ។

៩-សេដ្ឋិនោ ហត្ថី វីហយោ ខាទតិ។

១០-សុខិនោ មគ្គេន អារាមំ គច្ឆន្តិ។

# បំពេញពាក្យបាលី ត្រង់ចន្លោះ

១~ ..... រុក្ខេ តិដ្ឋតិ ។ -(ដំរី) ឈរ ជិតដើមឈើ ។

២~មនុស្សា មគ្គេន .... ។ -មនុស្សទ. (មក) តាមផ្លូវ ។

៣~ ...... អារាមំ គច្ឆតិ ។ -(អ្នកកាន់ឆត្រ) ទៅ កាន់អារាម។

៤~សេដ្ឋី ..... អាហារំ អាហរតិ។ -សេដ្ឋី នាំមក នូវអាហារ (ដោយដៃ)។

៥~ភោគី មណឹ .... ទេតិ ។

-អ្នកមានភោគ ឱ្យ នូវកែវមណី (ដល់បុត្តទ.)។

៦~សេដ្ឋិនោ ហត្ថី វីហយោ ....។ -ដំរី នៃសេដ្ឋី (កំពុងស៊ី) នូវស្រូវទ.។

៧~បាបការី ......ហត្ថី មារេតិ។ -អ្នកធ្វើបាប សម្លាប់ នូវដំរី (ស្គម)។

៨~ ..... មន្តី អាវាសេ វសតិ។ -មន្ត្រី (ក្មេង) នៅជិតអាវាស ។

៩~..... បុត្តស្ស សេតា ទន្តា ។ -ធ្មេញទ. ស របស់កូន (នៃសេដ្ឋី)។

១០~រថិកោ ... កាឡេ អស្សេ ....។

-(អ្នកបររថ) ដ៏ឈ្លាស (ចាប់) នូវសេះទ. ខ្មៅ។

# សំហាត់ប្រែជាភាសាបាលី

១-សេដ្ឋី ទិញ ក្អែកទ. ។

២-ដំរីទ. ខ្មៅ ឈរ ។

៣-អ្នកបររថ ប្រហារ សេះទ.។

៦-សេះទ. របស់សេដ្ឋី កំពុងដេក។

៧-ដំរី ស៊ី ស្រូវទ. ។

៨-អ្នកកាន់ឆត្រ ដើរ តាមផ្លូវ ។

| | |
|---|---|
| ៤_ខ្ញុំ ឃើញ សត្វស្លាបទ. ។ | ៩_អ្នកទ. កំពុងមើល ក្អែក ។ |
| ៥_ក្អែកទ. ទំ លើដើមឈើ ។ | ១០_សត្វស្លាបទ. ច្រើន នៅលើ_ដើមឈើ ។ |

## ឧ ការន្ត បុំលិង្គ បំបែកយ៉ាង គរុ " គ្រូ " ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | គរុ | គរវោ, គរូ |
| ទុ. | គរុំ | គរវោ, គរូ |
| ត. | គរុនា | គរូហិ, គរូភិ |
| ច. | គរុស្ស, គរុនោ | គរូនំ |
| បញ្ច. | គរុស្មា, គរុម្ហា, គរុនា | គរូហិ, គរូភិ |
| ឆ. | គរុស្ស, គរុនោ | គរូនំ |
| ស. | គរុស្មឹ, គរុម្ហិ | គរូសុ |
| អា. | គរុ | គរវេ, គរវោ |

## ឧ ការន្ត បុំលិង្គ បំបែកតែស្រះ ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ុ | \| វោ, ូ |
| ទុ. | ុំ | \| វោ, ូ |

| | | |
|---|---|---|
| ក. | ុ នា | ូ ហិ, ូ ភិ |
| ច. | ុ ស្ស, ុ នោ | ូ នំ |
| បញ្ច. | ុ ស្មា, ុ ម្ហា, ុ នា | ូ ហិ, ូ ភិ |
| ឆ. | ុ ស្ស, ុ នោ | ូ នំ |
| ស. | ុ ស្មឹ, ុ ម្ហិ | ូ សុ |
| អា. | ុ | | វេ, | វោ |

## សព្ទជា ឧ ការន្ត បំបែកដូច " គរុ "

| | | | |
|---|---|---|---|
| ភិក្ខុ | ភិក្ខុ | ផរសុ | ពូថៅ |
| ពន្ធុ | ផៅពង្ស | កដច្ឆុ | វែក |
| បសុ | សត្វចិញ្ចឹម | សត្តុ | សត្រូវ |
| អាខុ | កណ្ដុរ | សេតុ | ស្ពាន |
| ឧច្ឆុ | អំពៅ | កេតុ | ទង់ |
| វេឡុ | ឫស្សី | កម្ពុ | មាស, ស័ង្ខ |
| សុសុ | ក្មេងតូច | ការុ | អ្នកមានសិល្បៈ, ជាង |
| ពាហុ | ដើមដៃ | អសុ | ជីវិត |
| សិន្ធុ | ទន្លេ, ស្ទឹង | ឥន្ទុ | ព្រះចន្ទ |

## ឧការន្ត បុំលិង្គ បំបែកយ៉ាង វិញ្ញូ “ អ្នកប្រាជ្ញ ” ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | វិញ្ញូ | វិញ្ញូនោ, វិញ្ញូ |
| ទុ. | វិញ្ញុំ | វិញ្ញូនោ, វិញ្ញូ |
| ត. | វិញ្ញូនា | វិញ្ញូហិ, វិញ្ញូភិ |
| ច. | វិញ្ញុស្ស, វិញ្ញុនោ | វិញ្ញូនំ |
| បញ្ច. | វិញ្ញុស្មា, វិញ្ញុម្ហា, វិញ្ញុនា | វិញ្ញូហិ, វិញ្ញូភិ |
| ឆ. | វិញ្ញុស្ស, វិញ្ញុនោ | វិញ្ញូនំ |
| ស. | វិញ្ញុស្មឹ, វិញ្ញុម្ហិ | វិញ្ញូសុ |
| អា. | វិញ្ញូ | វិញ្ញូនោ, វិញ្ញូ |

## ឧការន្ត បុំលិង្គ បំបែកតែស្រៈ ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ូ | ុ នោ, ូ |
| ទុ. | ុំ | ុ នោ, ូ |
| ត. | ុ នា | ូ ហិ, ូ ភិ |
| ច. | ុ ស្ស, ុ នោ | ូ នំ |
| បញ្ច. | ុ ស្មា, ុ ម្ហា, ុ នា | ូ ហិ, ូ ភិ |

| | | |
|---|---|---|
| ឆ. | ◌ុ ស្ស, ◌ុ នោ | ◌ូ នំ |
| ស. | ◌ុ ស្មឹ, ◌ុ ម្ហិ | ◌ូ សុ |
| អា. | ◌ុ | ◌ុ នោ, ◌ូ |

## សព្ទជា ឩ ការន្ត បុំលិង្គ បំបែកដូច វិញ្ញូ

| | | | |
|---|---|---|---|
| វេទគូ | អ្នកដល់នូវវេទ | សព្វញ្ញូ | អ្នកចេះដឹងសព្វ |
| បភូ | អ្នកជាធំ | អភិភូ | អ្នកគ្របសង្កត់ |
| វិទូ | អ្នកចេះដឹង | កតញ្ញូ | អ្នកដឹងនូវឧបការគុណ |
| សយម្ភូ | អ្នកត្រាស់ដឹងឯង | វទញ្ញូ | អ្នកចេះសំដី |
| កាលញ្ញូ | អ្នកដឹងនូវកាល | មត្តញ្ញូ | អ្នកដឹងនូវប្រមាណ |
| បារគូ | អ្នកដល់នូវត្រើយ | | |

## កិរិយាសព្ទ ប្រាប់អតីតកាល បំបែកដូច្នេះ

| បុរិស | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ◌ី | ◌ុំ , ◌ឹ សុ |
| ម. | ◌ោ | ◌ិ ត្ថ |
| ឧ. | ◌ឹ | ◌ិ ម្ហ , ◌ិ ម្ហា |

| បុរិស | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | បចិ, អបចិ | បចុំ, អបចឹសុ |
| ម. | បចោ, អបចោ | បចិត្ថ, អបចិត្ថ |
| ឧ. | បចឹ, អបចឹ | បចិម្ហ, អបចិម្ហា |

## កិរិយាសព្ទ តទៅនេះ ជាអតីតកាល

| | | | |
|---|---|---|---|
| គច្ឆិ | ទៅហើយ | កីណិ | ទិញហើយ |
| គណ្ហិ | កាន់យកហើយ | វិក្កីណិ | លក់ហើយ |
| ករិ | ធ្វើហើយ | អាហរិ | នាំមកហើយ |
| និសីទិ | អង្គុយហើយ | សយិ | ដេកហើយ |
| ធាវិ | រត់ហើយ | ភុញ្ជិ | បរិភោគហើយ |
| អាគច្ឆិ | មកហើយ | ខាទិ | ទំពាស៊ីហើយ |
| ហរិ | នាំទៅហើយ | អារុហិ | ឡើងហើយ |
| ចរិ | ត្រាច់ទៅហើយ | | |

## កិរិយាសព្ទ ប្រាប់អនាគត " នឹង "

| បុរិស | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ~ិ ស្សតិ | ~ិ ស្សន្តិ |

| | | |
|---|---|---|
| ម. | ិ ស្សសិ | ិ ស្សថ |
| ឧ. | ិ ស្សាមិ | ិ ស្សាម |

| បុរិស | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | បចិស្សតិ | បចិស្សន្តិ |
| ម. | បចិស្សសិ | បចិស្សថ |
| ឧ. | បចិស្សាមិ | បចិស្សាម |

## កិរិយាសព្ទ ខាងក្រោមនេះ បំបែកដូច " បច "

| | | | |
|---|---|---|---|
| គមិស្សតិ | នឹងទៅ | វសិស្សតិ | នឹងនៅ |
| ភុញ្ជិស្សតិ | នឹងបរិភោគ | ទទិស្សតិ | នឹងឱ្យ |
| ហរិស្សតិ | នឹងនាំទៅ | ករិស្សតិ | នឹងធ្វើ |
| បស្សិស្សតិ | នឹងឃើញ | កិណិស្សតិ | នឹងទិញ |
| ភាយិស្សតិ | នឹងខ្លាច | យាចិស្សតិ | នឹងសុំ |
| ទេសិស្សតិ | នឹងសំដែង | សំវរិស្សតិ | នឹងសង្រួម |

## លំហាត់ប្រែជាភាសាខ្មែរ

| | |
|---|---|
| ១.វិញ្ញូនោ មញ្ចេសុ សយិស្សុ។ | ៦.ភិក្ខុ មនុស្សានំ ធម្មំ អភាសិ។ |
| ២.វិទូ អាហារំ អបចិ។ | ៧.កសកា មហន្តេ គោណេ វិក្កិណិំសុ។ |
| ៣.សព្វញ្ញូ ធម្មំ ជានិំសុ។ | ៨.ទារកា ពហុកេ បូវេ ខាទិំសុ។ |

៤-មត្តញ្ញូ កាលេន អាហារំ ភុញ្ជិ ។
៥-សេតា កបយោ រុក្ខំ អារុហឹសុ ។

៩-អស្សោ ទីឃេន សេតុនា ធាវិ ។
១០-វាណិជា មហន្តេ បសវោ កីណឹសុ ។

## សំហាត់ប្រែជាភាសាបាលី

១-ភិក្ខុ កំពុងសម្តែង ធម៌ ។
២-អ្នកប្រាជ្ញទ. បានស្តាប់ហើយ នូវធម៌ ។
៣-អ្នកចេះ ដឹងហើយ នូវធម៌ ។
៤-កុមារទ. លេងហើយ ក្នុងស្រុក ។
៥-ឈ្មួញទ. ទិញហើយ នូវដំរី ធំ ។

៦-សេដ្ឋី ពិសារហើយ នូវអាហារ ។
៧-ភិក្ខុ ឆាន់ហើយ នូវនំ ។
៨-ដំរី ទំពាស៊ី ... អំពៅ វែង ។
៩-ឆ្កែទ. បោលទៅហើយ តាមស្ពាន ខ្ពស់។
១០-ពស់ ខ្មៅ ចឹកហើយ នូវស្វា ស ។

## បំពេញពាក្យបាលី ត្រង់ចន្លោះ

១-ព្រះសយម្ភូ ( សំដែងហើយ ) នូវធម៌ ដល់មនុស្សទ. ។

- **សយម្ភូ ធម្មំ មនុស្សានំ** ( ............ ) ។

២-អ្នកប្រាជ្ញទ. ( ដឹងហើយ ) នូវកាល ។

- **មុនយោ កាលំ** ( ............. ) ។

៣-ទាសៈ របស់សេដ្ឋី នាំទៅហើយ នូវអាហារ ( ដើម្បីសត្វចិញ្ចឹម )។

- **សេដ្ឋិនោ ទាសោ អាហារំ .......... ហរិ** ។

៤-សេះ ស ទៅហើយ ( តាមស្ពាន ) វែង ។

- **សេតោ អស្សោ ទីឃេន ........ គច្ឆិ** ។

៥_បុរសទ. ( កាត់ហើយ ) នូវឈើដោយពូថៅ ។

~ **បុរិសោ ផរសុនា រុក្ខំ .............. ។**

៦_កូន របស់អ្នកប្រាជ្ញ ជាអ្នក ( អកតញ្ញូ ) ។

~ **មុនិនោ បុត្តោ ............. ហោតិ ។**

៧_ភិក្ខុ គង់ហើយ ( លើគ្រែ ) ធំ ។

~ **ភិក្ខុ មហន្តេ ....... និសីទិ ។**

៨_ជនទ. បូជាហើយ ( នូវភិក្ខុសង្ឃ ) ដោយអាហារ ។

~ **ជនា អាហារេន ................ បូជេសុំ ។**

៩_បព្វជិត ដឹងហើយ ( នូវវិន័យ ) ។

~ **បព្វជិតោ .......... ជានិ ។**

១០_ព្រះសព្វញ្ញូ យាងទៅហើយ កាន់អាស្រម ( ជិតភ្នំ ) ។

~ **សព្វញ្ញូ .............. អស្សមំ គច្ឆិ ។**

**អា ការន្ត ឥត្ថីលិង្គ បំបែកយ៉ាង កញ្ញា " ស្រីក្រមុំ " ដូច្នេះ**

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | **កញ្ញា** | **កញ្ញាយោ, កញ្ញា** |
| ទុ. | **កញ្ញំ** | **កញ្ញាយោ, កញ្ញា** |
| ត. | **កញ្ញាយ** | **កញ្ញាហិ, កញ្ញាភិ** |

| | | |
|---|---|---|
| ច. | កញ្ញាយ | កញ្ញានំ |
| បញ្ច. | កញ្ញាយ | កញ្ញាហិ, កញ្ញាភិ |
| ឆ. | កញ្ញាយ | កញ្ញានំ |
| ស. | កញ្ញាយ, កញ្ញាយំ | កញ្ញាសុ |
| អា. | កញ្ញេ | កញ្ញាយោ, កញ្ញា |

ចាប់ពី អា ការន្តនេះតទៅ ពុំបំបែកស្រះសុទ្ធ ដូចការន្តមុនៗទៀតទេ ។

**សព្ទជា អា ការន្ត ឥត្ថីលិង្គ បំបែកដូច " កញ្ញា "**

| | | | |
|---|---|---|---|
| គង្គា | ទន្លេ | សាលា | សាលា |
| ជង្ឃា | ស្មង | ភរិយា | ប្រពន្ធ |
| នាវា | ទូក, សំពៅ | វសុធា | ផែនដី |
| ទិសា | ទិស | សភា | ទីប្រជុំ |
| សេនា | កងទ័ព | សិលា | ថ្ម |
| បរិសា | បរិស័ទ | លតា | វល្លិ៍ |
| គីវា | ក | កថា | សំដី |
| ជីវ្ហា | អណ្តាត | វាចា | វាចា, សំដី |
| នាសា | ច្រមុះ | តុលា | ជញ្ជីង |

| | | | |
|---|---|---|---|
| បញ្ញា | ប្រាជ្ញា | ទារិកា | ក្មេងស្រី |
| សាខា | មែកឈើ | មញ្ជូសា | ហិប |
| មាលា | កម្រងផ្កា | បិបាសា | ការស្រេក |
| ទេវតា | ទេព្ដា | បជា | ពួកសត្វ |
| គុហា | រូងភ្នំ | សម្បទា | សម្បទា |
| និទ្រា | ការដេកលក់ | ចេតនា | ចេតនា |
| វិបស្សនា | វិបស្សនា | សិវិកា | អង្រឹងស្នែង |
| ភាវនា | ភាវនា | បព្វជ្ជា | បព្វជ្ជា |
| មេត្តា | មេត្តា | វេទនា | វេទនា |
| ករុណា | ករុណា | ឧបេក្ខា | ឧបេក្ខា |
| សទ្ធា | ជំនឿ | អភិជ្ឈា | ការសម្លឹងរំពៃ |

**កិរិយាសព្ទ ប្រាប់សេចក្ដីបង្គាប់បញ្ជា អង្វរករ "ចូរ..., សូម...,"**

| បុរិស: | ឯកវចន: | ពហុវចន: |
|---|---|---|
| ប. | ត្វំ | អន្តុ |
| ម. | ហិ | ថ |
| ឧ. | មិ | ម |

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
| --- | --- | --- |
| ប. | បចតុ | បចន្តុ |
| ម. | បចាហិ, បច | បចថ |
| ឧ. | បចាមិ | បចាម |

**កិរិយាសព្ទ ខាងក្រោមនេះ បំបែកដូច " បច "**

| | | | |
| --- | --- | --- | --- |
| **ហោតុ** | ចូរមាន | **ភវតុ** | ចូរមាន |
| **បិវតុ** | ចូរផឹក | **ភាសតុ** | ចូរនិយាយ |
| **រក្ខតុ** | ចូររក្សា | **ឋបេតុ** | ចូរតម្កល់ទុក |
| **គច្ឆតុ** | ចូរទៅ | **បក្ខិបតុ** | ចូរដាក់ចុះ |
| **សុណាតុ** | ចូរស្ដាប់ | | |

**កិរិយាសព្ទ ប្រាប់សេចក្ដីប្រាថ្នា, យល់ឃើញ, សញ្ជឹង,**
**ត្រិះរិះ " គប្បី..., គួរ...,"**

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
| --- | --- | --- |
| ប. | ៤ ~ យ្យ | ៤ ~ យ្យុំ |
| ម. | ៤ ~ យ្យាសិ | ៤ ~ យ្យាថ |
| ឧ. | ៤ ~ យ្យាមិ | ៤ ~ យ្យាម |

| | | |
|---|---|---|
| ប. | បចេយ្យ | បចេយ្យុំ |
| ម. | បចេយ្យាសិ | បចេយ្យាថ |
| ឧ. | បចេយ្យាមិ | បចេយ្យាម |

## កិរិយាសព្ទ ខាងក្រោមនេះ បំបែកដូច "បច"

| | | | |
|---|---|---|---|
| រក្ខេយ្យ | គប្បីរក្សា | ភាសេយ្យ | គប្បីពោល |
| លភេយ្យ | គប្បីបាន | សុណេយ្យ | គប្បីស្តាប់ |
| វទេយ្យ | គប្បីពោល | បស្សេយ្យ | គប្បីឃើញ |

## លំហាត់ប្រែជាភាសាខ្មែរ

១-កញ្ញាយោ នាវាយ គង្គាយំ គច្ឆន្តុ។

២-គរូនំ បូវេ បចាហិ។

៣-ទេវតា លោកេ មនុស្សេ រក្ខន្តុ។

៤-សេដ្ឋិនោ ភរិយា សាលាយំ និសីទតុ។

៥-ទារិកាយោ គីវាយំ សប្បំ គណ្ហន្តុ។

៦-អាវាសំ គច្ឆាហិ។

៧-ធម្មំ ភណាហិ។

៨-បិយំ វាចំ វទេយ្យាថ។

៩-ឆេកា កុមារិកាយោ ធម្មំ សុណេយ្យុំ។

១០-ចន្ទស្ស សីតា បភា បស្សេយ្យាម។

## បំពេញពាក្យបាលី ត្រង់ចន្លោះ

១-កញ្ញាយោ ...... គង្គាយំ គច្ឆន្តុ ។

- កញ្ញាទ. ចូរទៅ ក្នុងស្ទឹង ( ដោយនាវា ) ។

**២-ទារិកាយោ ........ អហី គណ្ហន្តុ។**

- ទារិកាទ. ចូរចាប់ នូវពស់ ( ត្រង់ក ) ។

**៣-ត្វម្ពេ សាលាយំ អាហារំ ....... ។**

- អ្នកទ. ( ចូរបរិភោគ ) នូវអាហារ ក្នុងសាលា ។

**៤-សិស្សា អាចរិយស្ស វាចំ .......។**

- សិស្សទ. ( ត្រូវស្តាប់ ) សំដី របស់អាចារ្យ ។

**៥-ត្វម្ពេ .......... ហត្ថីនំ ទេថ ។**

- អ្នកទ. ចូរឱ្យ ( នូវអំពៅ ) ដល់ដំរីទ. ។

**៦-អហិ ......... គីវំ ឌំសតិ ។**

- ពស់ ចឹក នូវក ( នៃគោ )។

**៧-ទេវតា លោកេ មនុស្សេ .......។**

- ទេវតាទ. ( ចូររក្សា ) នូវមនុស្សទ. ក្នុងលោក ។

**៨-ត្វម្ពេ ........ ពុទ្ធំ បូជេថ ។**

- នាងទ. ចូរបូជា នូវព្រះពុទ្ធ ( ដោយផ្កាកម្រង ) ។

**៩-ត្វំ មហតិយំ ........ វសាហិ ។**

- អ្នក ចូរនៅ ( ក្នុងរូងភ្នំ ) ធំ ។

**១០-មាលា កញ្ញាយ ....... អត្ថិ ។**

- កម្រងផ្កា មាន ( ឮដ៏ក ) នៃកញ្ញា ។

# លំហាត់ប្រែជាភាសាបាលី

១,កញ្ញាទ. ចូរអង្គុយ ក្នុងសាលា។
២,ស្វា គប្បីអង្គុយ លើមែកឈើ។
៣,អ្នកទ. ចូរបរិភោគ អាហារ ក្នុងសាលា ។
៤,ដំរីទ. គប្បីទំពាស៊ី អំពៅទ. ។
៥,យើងទ. គប្បីចាប់ ពស់ ត្រង់ក។

៦,ទេវតា សូមរក្សា មនុស្សទ.។
៧,សិស្សទ. ត្រូវស្តាប់ សំដី របស់គ្រូ
៨,យើងទ. ត្រូវរៀន វិជ្ជាទ. ។
៩,ប្រាជ្ញា ចូរមាន ដល់សិស្សទ.។
១០, នាងទ. ចូរបូជា ព្រះពុទ្ធ ដោយផ្កាកម្រង ។

## ឥ ការន្ត ឥត្ថីលិង្គ បំបែកយ៉ាង រត្តិ " រាត្រី " ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | រត្តិ | រត្តិយោ, រត្តី |
| ទុ. | រត្តឹ | រត្តិយោ, រត្តី |
| ត. | រត្តិយា | រត្តីហិ, រត្តីភិ |
| ច. | រត្តិយា | រត្តីនំ |
| បញ្ច. | រត្តិយា, រត្យា | រត្តីហិ, រត្តីភិ |
| ឆ. | រត្តិយា | រត្តីនំ |
| ស. | រត្តិយា, រត្តិយំ, រត្យំ, (រត្តោ) | រត្តីសុ |
| អា. | រត្តិ | រត្តិយោ, រត្តី |

# សព្ទជា ៩ ការន្ត ឥត្ថីលិង្គ បំបែកដូច " រត្តិ "

| | | | |
|---|---|---|---|
| ភូមិ | ផែនដី | យដ្ឋិ | ឈើច្រត់ |
| កុដិ | កុដិ | នាឡិ | នាឡិ |
| ទោណិ | នាឡិ | ទុន្ទុភិ | ស្គរ |
| អសនិ | រន្ទះ | សតិ | សតិ, ស្មារតី |
| កិត្តិ | កេរ្តិ៍ឈ្មោះ | ខន្តិ | សេចក្តីអត់ធន់ |
| អង្គុលិ | ម្រាមដៃ | មតិ | គំនិត, យោបល់ |
| ភតិ | ថ្លៃឈ្នួល | តន្តិ | អំបោះ, ខ្សែពិណ |
| ថុតិ | សេចក្តីសរសើរ | បញ្ញត្តិ | សេចក្តីហាមប្រាម |
| នាភិ | ផ្ចិត, ដុំរទេះ | រំសិ | រស្មី |
| ភិត្តិ | ជញ្ជាំង | អនុសិដ្ឋិ | ពាក្យប្រៀបប្រដៅ |
| អាជិ | សង្គ្រាម | ឦតិ | ចង្រៃ |
| ឧក្ខលិ | ឆ្នាំង | ឩមិ | ( ទឹក ) រលក |
| គណ្ឋិ | រគាំង | ឆវិ | សម្បុរថ្ងៃ |
| ឆាតិ | មេទំ, ភីលៀង | ពុទ្ធិ | ប្រាជ្ញា |
| វិញ្ញត្តិ | កិរិយាសូម | សុទ្ធិ | សេចក្តីបរិសុទ្ធ |

## ឦ ការន្ត ឥត្ថីលិង្គ បំបែកយ៉ាង នារី " ស្រី, នាង " ដូច្នេះ

| ឯកវចនៈ | | ពហុវចនៈ |
|---|---|---|
| ប. | នារី | នារិយោ, នារី |
| ទុ. | នារឹ | នារិយោ, នារី |
| ត. | នារិយា | នារីហិ, នារីភិ |
| ច. | នារិយា | នារីនំ |
| បញ្ច. | នារិយា | នារីហិ, នារីភិ |
| ឆ. | នារិយា | នារីនំ |
| ស. | នារិយា, នារិយំ | នារីសុ |
| អា. | នារិ | នារិយោ, នារី |

សព្ទជា ឦ ការន្ត ឥត្ថីលិង្គ បំបែកដូច " នារី "

| | | | |
|---|---|---|---|
| កុមារី | ក្មេងស្រី | សខី | ស្ត្រីជាសម្លាញ់ |
| តរុណី | ស្រីក្រមុំ, ស្រីជំទង់ | ព្រាហ្មណី | នាងព្រាហ្មណ៍ |
| ឥត្ថី | ស្ត្រី | ភគិនី | បងប្អូនស្រី |
| មិគី | ម្រឹគញី | ទាសី | ខ្ញុំស្រី |
| កុក្កុដី | មាន់ញី | ទេវី | ព្រះទេពី |
| ភាកី | ក្អែកញី | សកុណី | សត្វស្លាបញី |

| | | | |
|---|---|---|---|
| ហត្ថីនី | មេដំរី | នទី | ស្ទឹង |
| វាបី | បឹង | ធានី | ទីក្រុង |
| គាវី | មេគោ | មហី | ផែនដី |

## កិរិយាសព្ទ ប្រាប់អនាគតកាល " នឹង...,"

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ិ ស្សតិ | ិ ស្សន្តិ |
| ម. | ិ ស្សសិ | ិ ស្សថ |
| ឧ. | ិ ស្សាមិ | ិ ស្សាម |

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | បចិស្សតិ | បចិស្សន្តិ |
| ម. | បចិស្សសិ | បចិស្សថ |
| ឧ. | បចិស្សាមិ | បចិស្សាម |

## កិរិយាសព្ទ ខាងក្រោមនេះ បំបែកដូច " បច "

| | | | |
|---|---|---|---|
| គមិស្សតិ | នឹងទៅ | ទទិស្សតិ | នឹងឱ្យ |
| ភុញ្ជិស្សតិ | នឹងបរិភោគ | ករិស្សតិ | នឹងធ្វើ |
| ហរិស្សតិ | នឹងនាំទៅ | បស្សិស្សតិ | នឹងឃើញ |
| វសិស្សតិ | នឹងនៅ | ភាយិស្សតិ | នឹងខ្លាច |

| | |
|---|---|
| ភាសិស្សតិ នឹងសំដែង | ភីណិស្សតិ នឹងទិញ |
| យាចិស្សតិ នឹងសុំ | សំចរិស្សតិ នឹងសង្រួម |

## សំហាត់ប្រែជាភាសាខ្មែរ

១_ភិក្ខុ ធម្មំ ទេសេតិ។

២_ភិក្ខុនោ ធម្មំ សុណិស្សាម។

៣_កសកោ ពហុកេ ឧច្ឆុវេ ឆិន្ទិស្សតិ។

៤_តុម្ហេ រស្មេ ឧច្ឆុវេ ខាទិស្សថ។

៥_ចោរា ភាណ្ឌេ ហត្ថី ហរិស្សន្តិ។

៦_អមច្ចា ចោរេ គណ្ហិស្សន្តិ។

៧_គហបតិយោ គាមេ វិហារំ ករិស្សន្តិ។

៨_វិហារេ សង្ឃំ វន្ទិស្សថ។

៩_មិត្តស្ស បូវេ ភុញ្ជិស្សាមិ។

១០_ពុទ្ធោ លោកេ មនុស្សានំ ធម្មំ ភាសិស្សតិ។

## បំពេញពាក្យបាលី ត្រង់ចន្លោះ

១_ភិក្ខុនី ........ ធម្មំ ទេសេសិ ។

_ ភិក្ខុនី សំដែងហើយ នូវធម៌ ( ដល់សាមណេរីទ. ) ។

២_នារី ........ សាលំ ករិស្សតិ ។

_ នារី នឹងធ្វើ នូវសាលា ( ដើម្បីថ្ងៃឈ្នួល ) ។

៣_ធានី មហតិយំ ......... តិដ្ឋតិ។

_ ទីក្រុង ស្ថិតនៅ ( ជិតគង្គា ) ធំ ។

៤_ព្រាហ្មណិយា .......... រត្តិយំ អារាមំ គមិស្សតិ ។

_( បងប្អូនស្រី ) របស់នាងព្រាហ្មណី នឹងទៅ វត្ត ក្នុងរាត្រី។

៥_ខុទ្ទកា វាបី ....... តិដ្ឋតិ ។

_ បឹងតូច ស្ថិតនៅ ( ជិតស្ទឹង )។

៦_តុម្ហេ វិញ្ញូនោ មតឹ ........ ។

_ អ្នកទាំងឡាយ ( គប្បីកាន់យក ) នូវមតិ របស់អ្នកប្រាជ្ញ ។

៧_ ហត្ថិនី ឧច្ចំ គិរឹ ......... ។

_ មេដំរី ( ឡើងហើយ ) កាន់ភ្នំ ខ្ពស់ ។

៨_សេដ្ឋិនោ ទាសី ......សាលំ គមិស្សតិ ។

_ ទាសី របស់សេដ្ឋី នឹងទៅកាន់ សាលា ( នៃឥសី )។

៩_ធាតិ ........ បូវំ អទាសិ ។

_ មេនំ បានឱ្យហើយ នូវនំ ( ដល់ស្ត្រីទ. ) ។

១០_ពុទ្ធស្ស បញ្ញត្តិ លោកេ ....... ។

_ បញ្ញត្តិ របស់ព្រះពុទ្ធ ( គប្បីស្ថិតនៅ ) ក្នុងលោក ។

## សំហាត់ប្រែជាភាសាបាលី

១_ អ្នកស្រែ នឹងទិញ គោទ. ។

២_ ចោរទ, នឹងលួច ។

៣_ ឆ្កែទ. នឹងខាំ ចោរ ។

៦_ ភិក្ខុ នឹងរៀនយក ធម៌ ។

៧_ អ្នកទ. នឹងស្តាប់ ធម៌ ។

៨_ខ្ញុំ នឹងរៀន ធម៌ របស់ព្រះពុទ្ធ។

| | |
|---|---|
| ៤_យើងទ. នឹងចាប់ ចោរ ។ | ៩_ ភិក្ខុ នឹងសង្រួម ដោយកាយ។ |
| ៥_សេដ្ឋី នឹងធ្វើ វត្ត ដើម្បី- ព្រះសង្ឃ ។ | ១០_មនុស្សទ. នឹងឃើញ ព្រះចន្ទ ឰដ៏អាកាស ។ |

**ខ្ញ ការន្ត ឥត្ថីលិង្គ បំបែកយ៉ាង រជ្ជុ " ខ្សែ " ដូច្នេះ**

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | រជ្ជុ | រជ្ជុយោ, រជ្ជូ |
| ទុ. | រជ្ជុំ | រជ្ជុយោ, រជ្ជូ |
| ត. | រជ្ជុយា | រជ្ជូហិ, រជ្ជូភិ |
| ច. | រជ្ជុយា | រជ្ជូនំ |
| បញ្ច. | រជ្ជុយា | រជ្ជូហិ, រជ្ជូភិ |
| ឆ. | រជ្ជុយា | រជ្ជូនំ |
| ស. | រជ្ជុយា, រជ្ជុយំ | រជ្ជូសុ |
| អា. | រជ្ជុ | រជ្ជុយោ, រជ្ជូ |

**សព្ទជា ខ្ញ ការន្ត ឥត្ថីលិង្គ បំបែកដូច " រជ្ជុ "**

| | | | |
|---|---|---|---|
| អលាពុ | ឃ្លោក | ធេនុ | មេគោ |
| ឧរុ | ខ្សាច់ | នត្តុ | ច្រមុះ |
| កាសុ | រណ្ដៅ, អណ្ដូង | យាគុ | បបរ |

| | | | |
|---|---|---|---|
| **ខជ្ជុ** | រោគស្រែង | **វិជ្ជុ** | ផ្លេកបន្ទោរ |
| **សានុ** | ញកភ្នំ | **អំសុ** | រស្មី |
| **តនុ** | ខ្លួន, កាយ | **សស្សុ** | ម្តាយក្មេក |

**ឩ ការន្ត ឥត្ថីលិង្គ បំបែកយ៉ាង វធូ " ស្រីមានគូស្រករ,**

**ប្រពន្ធក្រមុំ " ដូច្នេះ**

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | **វធូ** | **វធុយោ, វធូ** |
| ទុ. | **វធុំ** | **វធុយោ, វធូ** |
| ត. | **វធុយា** | **វធូហិ, វធូភិ** |
| ច. | **វធុយា** | **វធូនំ** |
| បញ្ច. | **វធុយា** | **វធូហិ, វធូភិ** |
| ឆ. | **វធុយា** | **វធូនំ** |
| ស. | **វធុយា, វធុយំ** | **វធូសុ** |
| អា. | **វធុ** | **វធុយោ, វធូ** |

**សព្ទជា ឩ ការន្ត ឥត្ថីលិង្គ បំបែកដូច " វធូ "**

| | | | |
|---|---|---|---|
| **ចមូ** | សេនា, កងទ័ពជើងគោក | **ភូ** | ផែនដី |
| **ជម្ពូ** | ជម្ពូ, ព្រីង | **សរពូ** | តុកកែ |

## លំហាត់ប្រែជាភាសាខ្មែរ

១-នារិយោ យាគុំ បុត្តានំ ទេន្តិ ៕
២-ធេនុយោ អជវិយំ កទលឹ ខាទិស្សន្តិ ៕
៣-ឆេកា សស្សំ បុត្តំ ឱវទតិ ៕
៤-នារី ទីឃាយ រជ្ជុយា ចណ្ឌំ សុនខំ ពន្ធតិ ៕
៥-តុម្ហេ ពហូ អលាពុយោ កីណិត្ថ ៕
៦-យុវតិយោ បាទេហិ នទឹ គមិស្សន្តិ ៕
៧-អហំ សាលាយំ មញ្ចេ សយិស្សាមិ ៕
៨-ភារិយោ មហតិយា នទិយំ ឱតរឹសុ ៕
៩-ឧបាសិកាយោ មាលាហិ ពុទ្ធំ បូជេស្សន្តិ ៕
១០-តុម្ហេ អនាថបិណ្ឌិកស្ស អារាមំ គមិស្សថ ៕

## បំពេញពាក្យបាលី ត្រង់ចន្លោះ

១-មនុស្សា គាមេ ចោរេ ........ ។

- មនុស្សទ.( សម្លាប់ ) នូវចោរទ. ក្នុងស្រុក ។

២-ភិក្ខូ គាមេ .......... ចរន្តិ ។

- ភិក្ខុទ. ត្រាច់ទៅ ក្នុងស្រុក( ដើម្បីបិណ្ឌបាត ) ។

៣-ភិក្ខុនិយោ ភិក្ខុនោ ធម្មំ .......។

- ភិក្ខុនីទ.( នឹងស្តាប់ ) នូវធម៌ របស់ភិក្ខុ ។

៤_ហត្ថិនិយោ .......... នទីំ គមិស្សន្តិ ។

_ មេដំរីទ. នឹងទៅ កាន់ស្ទឹង ( ជិតញកភ្នំ ) ។

៥_សរពូ ជម្ពូយា ......... វសតិ ។

_ តុកកែ នៅ ( លើមែក ) នៃព្រីង ។

៦_វធូ អារាមេ .......... ភូមឹ គច្ឆិ ។

_ ស្រីមានគូស្រករ ទៅហើយ កាន់ភូមិ ( ធំ ) ជិតវត្ត ។

៧_ខជ្ជុ សត្តានំ .......... អត្ថិ ។

_ រោគស្រែង មាន ( ត្រង់រាងកាយ ) នៃសត្វទ. ។

៨_វធុយា សស្សុ ធានិយំ ......... បស្សិ ។

_ ម្ដាយក្មេក នៃស្រីមានគូស្រករ ឃើញហើយ ( នូវកងទ័ពទ. ) ជិតក្រុង ។

៩_សេនា បទេសេ .......... ជិនិស្សន្តិ ។

_ សេនាទ. នឹងឈ្នះ ( នូវសត្រូវទ. ) ក្នុងប្រទេស ។

១០_សិស្សា អារាមស្ស .......... បាលឹ ឧគ្គណ្ហន្តិ ។

_ សិស្សទ. រៀននូវបាលី ( ក្នុងសាលា ) នៃវត្ត ។

## លំហាត់ប្រែជាភាសាបាលី

១_ នារី ចងហើយ នូវគោញី ដោយខ្សែ វែង ។

២_ កញ្ញាទ. នឹងទិញ នូវមាន់ញីទ. ធំ ។

៣. នាងទ. នឹងថ្វាយបង្គំ នូវព្រះសង្ឃ ក្នុងវត្ត ។

៤. កុមារីទ. នឹងទៅ កាន់សាលា ក្នុងស្រុក ។

៥. ស្ត្រីទ. ចំអិនហើយ នូវបបរ ដើម្បីភិក្ខុទ. ។

៦. អ្នកទ. នឹងនាំ គោញី ខ្មៅ ។

៧. ឯង បរិភោគហើយ នូវអាហារ ក្នុងកុដិ ។

៨. ខ្ញុំ នឹងហុត នូវបបរ របស់នារី ។

៩. អ្នកទ. គប្បីទៅ កាន់ភូមិ ក្នុងរាត្រី ។

១០. ស្ត្រីក្រមុំទ. នឹងទៅ វត្ត ជិតភ្នំ ។

អ ការន្ត នបុំសកលិង្គ បំបែកយ៉ាង កុល "ត្រកូល" ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | កុលំ | កុលានិ, កុលា |
| ទុ. | កុលំ | កុលានិ, កុលេ |
| ត. | កុលេន | កុលេហិ, កុលេភិ |
| ច. | កុលស្ស, កុលាយ, កុលត្ថំ | កុលានំ |
| បញ្ច. | កុលស្មា, កុលម្ហា, កុលា | កុលេហិ, កុលេភិ |
| ឆ. | កុលស្ស | កុលានំ |
| ស. | កុលស្មឹ, កុលម្ហិ, កុលេ | កុលេសុ |
| អា. | កុល | កុលានិ, កុលា |

# សព្ទជា អ ការន្ត នបុំសកលិង្គ បំបែកដូច "កុល"

| | | | |
|---|---|---|---|
| នយន | ភ្នែក | បណ្ណ | ស្លឹកឈើ |
| ធន | ទ្រព្យ | សុសាន | ព្រៃផ្សា, ស្មសាន |
| ផល | ផ្លែ | ខល | លាន |
| ទាន | ទាន | កដ្ឋ | កំណាត់ឈើ |
| បទុម | ផ្កាឈូក | សីល | សីល |
| បីឋ | តាំង, ជើងម៉ា | វន | ព្រៃ |
| មរណ | សេចក្តីស្លាប់ | អរញ្ញ | ព្រៃ |
| ចេតិយ | ចេតិយ | តិណ | ស្មៅ |
| សុខ | សុខ | ឧទក | ទឹក |
| ចីវរ | ចីវរ | និសីទន | និសីទនៈ |
| ផាណិត | ស្ករអំពៅ | ភោជន | ភោជន |
| គេហ | ផ្ទះ | សុវណ្ណ | មាស |
| បុញ្ញ | បុណ្យ | បាប | បាប |
| រូប | រូប | សោត | ត្រចៀក |
| យាន | ច្រមុះ | វត្ថ | សំពត់ |
| ហិរញ្ញ | ប្រាក់ | បុប្ផ | ផ្កា |

| | | | |
|---|---|---|---|
| **ចិត្ត** | ចិត្ត | **ភេសជ្ជ** | ភេសជ្ជៈ |
| **សេនាសន** | សេនាសនៈ | **ជល** | ទឹក |
| **ទុស្ស** | សំពត់ | **បុលិន** | ខ្សាច់ |
| **ទុក្ខ** | ទុក្ខ | **សោបាណ** | ជណ្តើរ |
| **មូល** | ឫស, តម្លៃ | **ហទយ** | បេះដូង |
| **កូល** | ច្រាំង, ត្រើយ | **អណ្ឌ** | ស៊ុត |
| **ពល** | កម្លាំង | **ខីរ** | ទឹកដោះស្រស់ |
| **ឆត្ត** | ឆត្រ | **ការណ** | ហេតុ |

## ឥ ការន្ត នបុំសកលិង្គ បំបែកយ៉ាង អក្ខិ " ភ្នែក " ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | **អក្ខិ** | **អក្ខីនិ, អក្ខី** |
| ទុ. | **អក្ខិ** | **អក្ខីនិ, អក្ខី** |
| ត. | **អក្ខិនា** | **អក្ខីហិ, អក្ខីភិ** |
| ច. | **អក្ខិស្ស, អក្ខិនោ,** | **អក្ខីនំ** |
| បញ្ច. | **អក្ខិស្មា, អក្ខិម្ហា, អក្ខិនា** | **អក្ខីហិ, អក្ខីភិ** |
| ឆ. | **អក្ខិស្ស, អក្ខិនោ** | **អក្ខីនំ** |
| ស. | **អក្ខិស្មឹ, អក្ខិម្ហិ** | **អក្ខីសុ** |
| អា. | **អក្ខិ** | **អក្ខីនិ, អក្ខី** |

## សព្ទជា ៩ ការន្ត នបុំសកលិង្គ បំបែកដូច " អគ្គិ "

| | | | |
|---|---|---|---|
| អដ្ឋិ | ឆ្អឹង | ទធិ | ទឹកដោះជូ |
| វារិ | ទឹក | អច្ចិ | អណ្តាតភ្លើង |
| សប្បិ | ទឹកដោះថ្លា | ហវិ | បាយទេវតា, តង្វាយទេពតា |

## ខ្ ការន្ត នបុំសកលិង្គ បំបែកយ៉ាង វត្ថុ "វត្ថុ" ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | វត្ថុ | វត្ថូនិ, វត្ថូ |
| ទុ. | វត្ថុំ | វត្ថូនិ, វត្ថូ |
| ត. | វត្ថុនា | វត្ថូហិ, វត្ថូភិ |
| ច. | វត្ថុស្ស, វត្ថុនោ, | វត្ថូនំ |
| បញ្ច. | វត្ថុស្មា, វត្ថុម្ហា, វត្ថុនា | វត្ថូហិ, វត្ថូភិ |
| ឆ. | វត្ថុស្ស, វត្ថុនោ | វត្ថូនំ |
| ស. | វត្ថុស្មឹ, វត្ថុម្ហិ | វត្ថូសុ |
| អា. | វត្ថុ | វត្ថូនិ, វត្ថូ |

## សព្ទជា ខ្ ការន្ត នបុំសកលិង្គ បំបែកដូច "វត្ថុ"

| | | | |
|---|---|---|---|
| អម្ពុ | ទឹក | ជតុ | ជ័រ, ល័ក្ត, អាចម៍ល័ក្ត |
| អស្សុ | ទឹកភ្នែក | តិបុ | សំណ |

| | | | |
|---|---|---|---|
| អាយុ | អាយុ | ទារុ | ឈើ, ឧស |
| ចក្ខុ | ភ្នែក | ធនុ | ធ្នូ |
| មស្សុ | ពុកចង្កា, ពុកមាត់ | វបុ | អត្តភាព, រាងកាយ |
| សជ្ឈុ | ប្រាក់ | អារុ | ដំបៅ |

## សំហាត់ប្រែជាភាសាខ្មែរ

១-មច្ឆរី ទានំ ន ទេតិ ។

២-បាបការី សីលានិ ន រក្ខតិ ។

៣-ពាលោ ចិត្តំ ន ភាវេតិ ។

៤-ជនា សទ្ធាយ ទានំ ទេន្តិ ។

៥-កុមារា បព្វជ្ជាយ គេហា និក្ខមិស្សន្តិ ។

៦-អហំ បុត្តានំ ឱទនំ ទេមិ ។

៧-ឥត្ថិយោ ទារកានំ យាគុំ ទេន្តិ ។

៨-ភិក្ខូ ពហូនំ ជនានំ ធម្មំ ភាសិស្សន្តិ ។

៩-ឧបាសកា ឆេកស្ស ភិក្ខុនោ ធម្មំ សុណិស្សន្តិ ។

១០-មយំ បត្តមេហិ រតនំ បូជេម ។

## បំពេញពាក្យបាលី ត្រង់ចន្លោះ

១-មច្ឆរី សមណស្ស .............. ន ទេតិ ។

- អ្នកមានសេចក្តីកំណាញ់ មិនឱ្យ ( នូវទាន ) ដល់សមណៈ ។

**២-បាបការី សីលានិ .............. ។**

- អ្នកធ្វើបាប ( មិនរក្សា ) នូវសីលទ. ។

**៣-ពាលា ........... ន ភាវេន្តិ ។**

- ជនពាលទ. មិនអប់រំ ( នូវចិត្ត ) ។

**៤-ជនា ......... ទានំ ទេន្តិ ។**

- ជនទ. តែងឱ្យ នូវទាន ( ដោយសទ្ធា ) ។

**៥-កុមារា ......... គេហា និក្ខមិស្សន្តិ ។**

- កុមារទ. នឹងចេញ ចាកផ្ទះ ( ដើម្បីផ្នួស ) ។

**៦-......... ទារកានំ ឧទកំ ទេមិ ។**

- ( ខ្ញុំ ) ឱ្យ នូវទឹក ដល់ទារកទ.។

**៧-ឥត្ថិយោ យាគុំ ......... បចន្តិ ។**

- ស្ត្រីទ. ចំអិន នូវបបរ ( ដើម្បីកុមារទ. ) ។

**៨-ភិក្ខុ ........... ធម្មំ ទេសិស្សតិ ។**

- ភិក្ខុ នឹងសំដែង នូវធម៌ ( ដល់បរិស័ទទ. ) ។

**៩-ឧបាសកា ភិក្ខុនោ ........... សុណិស្សន្តិ ។**

- ឧបាសកទ. នឹងស្តាប់ ( នូវកថា ) នៃភិក្ខុ ។

**១០-មយំ បទុមេហិ ......... បូជិម្ហា ។**

- យើងទ. បូជាហើយ ( នូវរតនៈទ. ) ដោយផ្កាឈូកទ. ។

## លំហាត់ប្រែជាភាសាបាលី

១_មនុស្សទ. ប្រគេន នូវទាន ចំពោះសមណៈទ. ។

២_អ្នកប្រមាទ រមែងដល់ នូវសេចក្ដីវិនាស ដ៏ធំ ។

៣_អ្នកធ្វើបុណ្យ រមែងទៅ កាន់ស្ថានសួគ៌ ។

៤_អ្នកធ្វើបាបទ. តែងទៅ កាន់អបាយ ។

៥_យើងទ. ឱ្យ នូវសំពត់ទ. ដល់កុមារីទ. ។

៦_កុមារទ. លេង នូវទឹក ក្នុងស្ទឹង ជ្រៅ ។

៧_ព្រះសង្ឃ តែងសំដែង នូវធម៌ ដល់បរិស័ទទ. ។

៨_យើងទ. នឹងស្ដាប់ នូវធម៌ របស់ធម្មកថិក ក្នុងវិហារ ។

៩_អ្នកទ. ចូរបូជា ព្រះរតនត្រ័យ ដោយផ្កាឈូកទ. ស ។

១០_យើងទ. គប្បីថ្វាយបង្គំ នូវព្រះសង្ឃ ដោយគោរព ។

## បកិណ្ណកសព្ទ

សព្ទរាត់រាយ ហៅថា បកិណ្ណកសព្ទ គឺសព្ទដែលមានវិធីបំបែកផ្សំនឹងវិភត្តិ ផ្សេងដោយឡែក មិនសូវសាធារណៈទូទៅដល់ សព្ទឯទៀតៗ ច្រើនឡើយ ។ បកិណ្ណកសព្ទនោះ យ៉ាងសង្ខេបមាន ១៣ គឺ **ព្រហ្ម, អត្ត, សខ, រាជ, ភគវន្តុ, អរហន្ត, ភវន្ត, សត្ថុ, បិតុ, មាតុ, មន, កម្ម, គោ** ។

## ព្រហ្ម "ព្រហ្ម" អ ការន្ត បុំលិង្គ បំបែកដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ព្រហ្មា | ព្រហ្មានោ |
| ទុ. | ព្រហ្មានំ, ព្រហ្មំ | ព្រហ្មានោ |
| ត. | ព្រហ្មុនា | ព្រហ្មេហិ, ព្រហ្មេភិ |
| ច. | ព្រហ្មុនោ, (ព្រហ្មស្ស) | ព្រហ្មានំ |
| បញ្ច. | ព្រហ្មុនា | ព្រហ្មេហិ, ព្រហ្មេភិ |
| ឆ. | ព្រហ្មុនោ, (ព្រហ្មស្ស) | ព្រហ្មានំ |
| ស. | ព្រហ្មនិ | ព្រហ្មេសុ |
| អា. | ព្រហ្មេ | ព្រហ្មានោ |

## អត្ត "ខ្លួន, អាត្មា, ចិត្ត" ជាឯកវចនៈ បំបែកដូច្នេះ

| | ឯកវចនៈ | | ឯកវចនៈ |
|---|---|---|---|
| ប. | អត្តា | បញ្ច. | អត្តនា |
| ទុ. | អត្តានំ, (អត្តំ) | ឆ. | អត្តនោ |
| ត. | អត្តនា | ស. | អត្តនិ |
| ច. | អត្តនោ | អា. | អត្ត |

**សខ " សម្លាញ់ " ជាទ្វិលិង្គិកៈ គឺ បុំលិង្គ និងឥត្ថីលិង្គ ៖**

**បុំលិង្គបំបែកដូច្នេះ**

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | **សខា** | **សខានោ (សខាយោ, សខិនោ)** |
| ទុ. | **សខានំ, សខារំ, (សខំ)** | **សខានោ (សខាយោ, សខិនោ)** |
| ត. | **សខិនា** | **សខារេហិ, (សខេហិ)** |
| ច. | **សខិស្ស, សខិនោ,** | **សខារានំ, (សខីនំ)** |
| បញ្ច. | **សខិនា** | **សខារេហិ, (សខេហិ)** |
| ឆ. | **សខិស្ស, សខិនោ** | **សខារានំ, (សខីនំ)** |
| ស. | **សខេ** | **សខារេសុ, (សខេសុ)** |
| អា. | **សខ, (សខា, សខិ, សខី, សខេ)** | **សខានោ (សខាយោ, សខិនោ)** |

ឥត្ថីលិង្គ ចុះ **ណី**-បច្ច័យ ជា **សខី** "ស្ត្រីជាសម្លាញ់" បំបែកផ្សំនឹងវិភត្តិ ដូច " **នារី** " ។

## រាជ "ស្តេច" ជាទ្វិលិង្គិកៈ គឺ បុំលិង្គនិងឥត្ថីលិង្គ ២

## បុំលិង្គ បំបែកដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | **រាជា** | **រាជានោ** |
| ទុ. | **រាជានំ** | **រាជានោ** |
| ត. | **រញ្ញា** | **រាជូហិ, រាជូភិ** |
| ច. | **រញ្ញោ, (រាជិនោ, រាជស្ស)** | **(រញ្ញំ) រាជូនំ** |
| បញ្ច. | **រញ្ញា** | **រាជូហិ, រាជូភិ** |
| ឆ. | **រញ្ញោ, (រាជិនោ, រាជស្ស)** | **(រញ្ញំ) រាជូនំ** |
| ស. | **រញ្ញេ, រាជិនិ** | **រាជូសុ** |
| អា. | **រាជ** | **រាជានោ** |

ឥត្ថីលិង្គ ចុះ **ឥនី**-បច្ច័យជា **រាជិនី** " ស្តេចស្រី " បំបែកផ្សំនឹងវិភត្តិ ដូច " **នារី** "។ សព្ទជាបទសមាស ដែលមាន **រាជ** សព្ទនៅខាងចុង ដូច **មហារាជ** " ស្តេចធំ, ស្តេចប្រសើរ " ជាដើម បំបែកដូច **បុរិស** ( អ ការន្ត បុំលិង្គ ) ប្លែកតែ ប. ឯក. **មហារាជា** ពហុ. **មហារាជានោ** នឹង អា. ពហុ. **មហារាជានោ** ។

ឥត្ថីលិង្គ ជា **មហារាជិនី** បំបែកដូច " **នារី** " ។

## ភគវន្តុ "ព្រះមានព្រះភាគ, ព្រះមានជោគ"

## ខ្ញុំ ការន្ត បុំលិង្គបំបែកដូច្នេះ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ភគវា | ភគវន្តា, ភគវន្តោ |
| ទុ. ភគវន្តំ | ភគវន្តេ, ភគវន្តោ |
| ត. ភគវតា (ភគវន្តេន) | ភគវន្តេហិ, ភគវន្តេភិ |
| ច. ភគវតោ, (ភគវន្តស្ស) | ភគវតំ, ភគវន្តានំ |
| បញ្ច. ភគវតា | ភគវន្តេហិ, ភគវន្តេភិ |
| ឆ. ភគវតោ, (ភគវន្តស្ស) | ភគវតំ, ភគវន្តានំ |
| ស. ភគវតិ, ភគវន្តេ (ភគវន្តស្មឹ, ភគវន្តម្ហិ) | ភគវន្តេសុ |
| អា. ភគវ, ភគវា | ភគវន្តា, ភគវន្តោ |

**អរហន្ត** "ព្រះអរហន្ត" ជាទ្វិលិង្គិកៈ គឺ បុំ. និង ឥត្ថី. ។ បុំ. ត្រង់ ប. ឯក. ជា **អរហា, អរហំ** ក្រៅពីនេះ ដូច **ភគវន្តុ**, ឥត្ថី. ចុះ **ឦ**-បច្ច័យ ជា **អរហន្តី** បំបែកដូច " **នារី** " ។

## លំហាត់ប្រែជាភាសាខ្មែរ

១-ភគវា សត្តានំ អត្ថាយ ហិតាយ សុខាយ ធម្មំ ទេសេតុ ។

២-តុម្ហេ ព្រាហ្មេ ធម្មំ សុណាថ, ធម្មំ ទេសិស្សាមិ ។

៣-ភិក្ខូ អត្តនោ អត្តនោ អាសនេសុ និសីទឹសុ ។

៤-សខាយោ មហាតិយំ នទិយំ នហាយឹសុំ ។

៥-រាជា អត្តនោ មហាជនំ ឩលេតិ ។

៦-អត្តា អត្តនោ នាថោ ហោតិ ។

៧-ពហូ សាមណេរា អត្តនោ អត្តនោ ចីវរានិ ធារុបន្តិ ។

៨-រញ្ញោ អស្សា អរញ្ញំ ធាវិស្សន្តិ ។

៩-មារោ លោកេ សត្តេ មារេតិ ។

១០-ត្វំ សខេ ភត្តំ សព្វស្ស អាហរ ។

## បំពេញពាក្យបាលី ត្រង់ចន្លោះ

១-ព្រាហ្មណោ ......... ភគវន្តំ ឧបសង្កមឹសុ ។

-ព្រាហ្មណ៍ទ. ចូលទៅរកហើយ នូវព្រះមានព្រះភាគ (ក្នុងវត្តវេឡុវ័ន) ។

២-កុមារា ........ ....... សាលាយោ គមិស្សន្តិ ។

- កុមារទ. នឹងទៅ កាន់សាលាទ. (របស់ខ្លួនៗ) ។

៣-រាជិនី អត្តនោ ........... រក្ខតិ ។

- ព្រះរាជិនី ទ្រង់រក្សា (នូវសម្លាញ់ស្រីទ.) របស់ព្រះអង្គ ។

**៤_អរហា ......... ធម្មំ ទេសេតិ ។**

_ ព្រះអរហន្ត សំដែង នូវធម៌ ( ដល់ព្រះរាជា ) ។

**៥_ភគវា ......... សាវកានំ វិនយំ បញ្ញាបេតិ ។**

_ព្រះមានព្រះភាគ ទ្រង់បញ្ញត្ត នូវវិន័យ ដល់សាវ័កទ. (របស់ព្រះអង្គ) ។

**៦_អានន្ទោ .......... បញ្ហំ បុច្ឆិ ។**

_ ព្រះអានន្ទ សួរហើយ នូវបញ្ហា ( នឹងព្រះមានព្រះភាគ ) ។

**៧_ភគវា .......... អាទីនវំ ទេសេសិ ។**

_ ព្រះមានព្រះភាគ ទ្រង់សំដែងហើយ នូវទោស ( នៃកាមទ. ) ។

**៨_រាជា ទុគ្គតានំ .......... ទេតិ ។**

_ ព្រះរាជា ទ្រង់ប្រទាន ( នូវទ្រព្យ ) ដល់ទុគ្គតជនទ. ។

**៩_ជនា ពហូនំ អរហន្តានំ ........ បូជេសុំ ។**

_ជនទ. បូជាហើយ (នូវចតុប្បច្ច័យ ) ដល់ព្រះអរហន្តទ. ច្រើនអង្គ ។

**១០_ ........ សាវត្ថិយំ ជេតវនំ អាគមឹសុ ។**

_ ( ព្រាហ្មទ. ) មកហើយ កាន់វត្ត ជេតពន ជិតក្រុងសាវត្ថី ។

## លំហាត់ប្រែជាភាសាបាលី

១_ព្រាហ្មទ. ចូលទៅរក ព្រះមានព្រះភាគ ក្នុងវត្តជេតពន ។

២_យើងទ. នឹងស្តាប់ នូវធម៌ របស់ព្រះមានព្រះភាគ ក្នុងវិហារ ។

៣_អ្នកទ. ចូរស្លៀកដណ្តប់ នូវសំពត់ របស់ខ្លួនៗ ។

៤_ដំរី នៃព្រះរាជា ចូលទៅ កាន់ព្រៃ ។

៥_អាមាត្យ របស់ព្រះរាជា នឹងចូលទៅ កាន់ភូមិ ។

៦_ព្រះមានព្រះភាគ កំពុងសំដែង ធម៌ ដល់ព្រហ្មទ. ។

៧_យើងទ. គប្បីធ្វើ នូវទីពឹង ដើម្បីខ្លួន ។

៨_ជនទ. គប្បីប្រព្រឹត្ត នូវសុចរិត ។

៩_អ្នកទ. មិនគប្បីប្រព្រឹត្ត នូវទុច្ចរិតទេ ។

១០_ព្រះយោគី ធ្វើ នូវសមាធិ លើភ្នំ ខ្ពស់ ។

## ភវន្ត "អ្នកដ៏ចំរើន" ជាទ្វិលិង្គិកៈ គឺ បុំលិង្គ និងឥត្ថីលិង្គ ២
## បុំលិង្គ បំបែកដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ភវំ | ភវន្តា, ភវន្តោ |
| ទុ. | ភវន្តំ | ភវន្តេ, ភវន្តោ |
| ត. | ភវតា, (ភោតា, ភវន្តេន) | ភវន្តេហិ, ភវន្តេភិ |
| ច. | ភវតោ, (ភោតោ, ភវន្តស្ស) | ភវតំ, ភវន្តានំ |
| បញ្ច. | ភវតា, ភោតា, (ភវន្តស្មា, ភវន្តម្ហា) | ភវន្តេហិ, ភវន្តេភិ |
| ឆ. | ភវតោ, ភោតោ, (ភវន្តស្ស) | ភវតំ, ភវន្តានំ |

| | |
|---|---|
| ស. ភវន្តេ, (ភវន្តស្មឹ, ភវន្តម្ហិ) | ភវន្តេសុ |
| អា. ភោ | ភវន្តា, ភវន្តោ, |
| | ភោន្តា, ភោន្តោ |

បើឥត្ថី. ផ្លាស់ ភវន្ត ជា ភោត ចុះ ឦ-បច្ច័យ បានរូបជា ភោតី បំបែកដូច " នារី " ។

## សត្ថុ "សាស្តា, គ្រូ" ឧ ការន្ត បុំលិង្គ បំបែកដូច្នេះ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. សត្ថា | សត្ថារោ |
| ទុ. សត្ថារំ | សត្ថារោ |
| ត. សត្ថារា, សត្ថុនា | សត្ថារេហិ, សត្ថារេភិ |
| ច. សត្ថុ, សត្ថុនោ (សត្ថុស្ស) | សត្ថារានំ, (សត្ថានំ, សត្ថូនំ) |
| បញ្ច. សត្ថារា | សត្ថារេហិ, សត្ថារេភិ |
| ឆ. សត្ថុ, សត្ថុនោ (សត្ថុស្ស) | សត្ថារានំ, (សត្ថានំ, សត្ថូនំ) |
| ស. សត្ថរិ | សត្ថារេសុ |
| អា. សត្ថា, (សត្ថ) | សត្ថារោ |

## បិតុ " បិតា " ឧ ការន្ត បុំលិង្គ បំបែកដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | បិតា | បិតរោ |
| ទុ. | បិតរំ | បិតរោ |
| ត. | បិតរា, បិតុនា | បិតរេហិ, បិតរេភិ, បិតូហិ, បិតូភិ |
| ច. | បិតុ, បិតុនោ (បិតុស្ស) | បិតរានំ, បិតូនំ |
| បញ្ច. | បិតរា | បិតរេហិ, បិតរេភិ, បិតូហិ, បិតូភិ |
| ឆ. | បិតុ, បិតុនោ (បិតុស្ស) | បិតរានំ, បិតូនំ |
| ស. | បិតរិ | បិតរេសុ, បិតូសុ |
| អា. | បិតា, | បិតរោ |

## មាតុ " មាតា " ឧ ការន្ត ឥត្ថីលិង្គ បំបែកដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | មាតា | មាតរោ |
| ទុ. | មាតរំ | មាតរោ |
| ត. | មាតរា, មាតុយា | មាតរាហិ, មាតរាភិ, មាតូហិ, មាតូភិ |
| ច. | មាតុ, មាតុយា | មាតរានំ, មាតូនំ |
| បញ្ច. | មាតរា, មាតុយា | មាតរាហិ, មាតរាភិ, មាតូហិ, មាតូភិ |

| | |
|---|---|
| ឆ. មាតុ, មាតុយា | មាតរានំ, មាតូនំ |
| ស. មាតរិ | មាតរាសុ, មាតូសុ |
| អា. មាតា | មាតរោ |

មន " ចិត្ត " ជាទ្វិលិង្គិកៈ គឺ បុំ. និងនបុំសកលិង្គ ។ បុំលិង្គ បំបែកដូច បុរិស នបុំសកលិង្គ បំបែកដូច " កុល " ដែលប្លែកគ្នា នោះ តែ ៦ វិភត្តិ ត្រង់ ឯកវចនៈ ដូច្នេះ

| ឯកវចនៈ | ឯកវចនៈ |
|---|---|
| ទុ. មនោ | បញ្ច. មនសា |
| ត. មនសា | ឆ. មនសោ |
| ច. មនសោ | ស. មនសិ |

កម្ម "កម្ម (អំពើ)" អ ការន្ត នបុំសកលិង្គ បំបែកដូច្នេះ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. កម្មំ | កម្មានិ |
| ទុ. កម្មំ | កម្មានិ |
| ត. កម្មុនា, កម្មេន (កម្មនា, កម្មានា) | កម្មេហិ, កម្មេភិ, |
| ច. កម្មុនោ, កម្មស្ស | កម្មានំ |
| បញ្ច. កម្មុនា, កម្មស្មា, កម្មម្ហា | កម្មេហិ, កម្មេភិ |

| | |
|---|---|
| ឆ. កម្មុនោ, កម្មស្ស | កម្មានំ |
| ស. កម្មុនិ, កម្មស្មឹ, កម្មម្ហិ, កម្មេ | កម្មេសុ, កម្មាសុ |
| អា. កម្ម | កម្មានិ |

## គោ "គោ" ឱ ការន្ត ជាទ្វិលិង្គិកៈ គឺ បុំ. និងឥត្ថីលិង្គ ៗ

## បុំលិង្គ បំបែកដូច្នេះ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. គោ | គាវោ |
| ទុ. គាវំ, គាវុំ | គាវោ |
| ត. គាវេន | គោហិ, គោភិ, គាវេហិ, គាវេភិ |
| ច. គាវស្ស | គោនំ, គុន្នំ, គាវានំ, គវំ |
| បញ្ច.គាវស្មា, គាវម្ហា, គាវា | គោហិ, គោភិ, គាវេហិ, គាវេភិ |
| ឆ. គាវស្ស | គោនំ, គុន្នំ, គាវានំ, គវំ |
| ស. គាវស្មឹ, គាវម្ហិ, គាវេ | គោសុ, គាវេសុ |
| អា. គាវ | គាវោ |

## កិរិយាសព្ទ ខាងក្រោមនេះ ជាអតីតកាល

| | | | |
|---|---|---|---|
| វន្ទិ | ថ្វាយបង្គំហើយ | បាជេសិ | កៀងទៅហើយ |
| បុច្ឆិ | សួរហើយ | កសិ | ភ្ជួរហើយ |
| សុណិ | ស្តាប់ហើយ | នេសិ | នាំទៅហើយ |

| | | | |
|---|---|---|---|
| ករថេសិ | សំដែងហើយ | ឱតរិ | ចុះហើយ |
| ឱលោកេសិ | ក្រឡេកមើលហើយ | ចរិ | ត្រាច់ទៅហើយ |
| | | ចវិ | ច្យុតហើយ |

## សំរាយប្រែជាភាសាខ្មែរ

១-ព្រហ្មានោ ទេវលោកេ សត្ថារំ អភិវន្ទឹសុ ។

២-ទេវតា រត្តិភាគេ ភគវន្តំ បញ្ហេ បុច្ឆិ ។

៣-ពហូ ទេវា ភគវតោ ធម្មំ សុណន្តិ ។

៤-មនុស្សា ជេតវនេ សត្ថុ ធម្មំ សុណេយ្យុំ ។

៥-បុត្តា បិតុ ឱវាទេន កម្មានិ ករិស្សន្តិ ។

៦-ធីតរោ មាតុយា ឱវាទេ តិដ្ឋេយ្យុំ ។

៧-បុត្តធីតរោ មាតាបិតូនំ វត្ថូនិ ទេន្តិ ។

៨-គោបាលោ ទណ្ឌេន គាវោ គោចរំ បាជេតិ ។

៩-មច្ចូ បាណីនំ អាយុំ បាជេតិ ។

១០-កសកា អត្តនោ អត្តនោ គាវេហិ ខេត្តានិ កសឹសុ ។

## បំពេញពាក្យបាលី ត្រង់ចន្លោះ

១-ជយតុ .......... មហារាជ ។

- បពិត្រមហារាជ (ព្រះអង្គជ៏ចម្រើន) សូមឈ្នះ ។

២-ព្រហ្មានោ ទេវលោកេ .......... អភិវន្ទឹសុ ។

- ព្រហ្មទ. ថ្វាយបង្គំហើយ ( នូវព្រះសាស្តា ) ក្នុងទេវលោក ។

**៣-បុត្តា បិតុ ឱវាទេន .......... ករិស្សន្តិ ។**

- បុត្រទ. និងធ្វើ ( នូវការងារទ. ) តាមឱវាទ នៃបិតា ។

**៤-គោបាលោ ទណ្ឌេន .......... បាជេសិ ។**

- នាយគោបាល កៀងហើយ ( នូវគោទ. ) ដោយដំបង ។

**៥-មនុស្សា ជេតវនេ ............ ធម្មំ សុណឹសុ ។**

- មនុស្សទ. ស្តាប់ហើយ នូវធម៌ ( នៃព្រះសាស្តា ) ក្នុងវត្តជេតពន ។

**៦-តុម្ហេ .......... គារវេន បរិត្តំ សុណាថ ។**

- (បពិត្រអ្នកដ៏ចម្រើនទ. ) អ្នកទ. សូមស្តាប់ នូវព្រះបរិត្ត ដោយ-សេចក្តីគោរព ។

**៧-រាជា ............ អាសនេ និសីទិ ។**

- ព្រះរាជាគង់ហើយ លើអាសនៈ ( របស់ព្រះអង្គ ) ។

**៨-អរហន្តោ .......... សន្តិកំ គមឹសុ ។**

- ព្រះអរហន្តទ. ទៅហើយ កាន់សំណាក់ ( នៃព្រះរាជា ) ។

**៩-មាតរោ អត្តនោ បុត្តានំ ឱវាទំ ........... ។**

- មាតាទ. ( តែងឱ្យ ) នូវឱវាទ ដល់បុត្រទ. របស់ខ្លួន ។

**១០-ពហូ ទេវា ............ ធម្មំ សុណឹសុ ។**

- ទេវតាទ. ច្រើន ស្តាប់ហើយ នូវធម៌ ( របស់ព្រះមានព្រះភាគ ) ។

# លំហាត់ប្រែជាភាសាបាលី

១_ទេវតាទ. ចុតិហើយ ចាកទេវលោក ។

២_ភិក្ខុ ទូលសួរហើយ នូវប្រស្នា នឹងព្រះសាស្តា ។

៣_មនុស្សទ. ច្រើននាក់ ស្តាប់ហើយ នូវធម៌ ។

៤_កូនប្រុសទ. តែងធ្វើ ការងារទ. ក្នុងស្រែ ។

៥_កូនស្រីទ, តែងធ្វើ ការងារទ. ក្នុងផ្ទះ ។

៦_កូនប្រុសស្រីទ. តែងធ្វើ តាមឱវាទ មាតាបិតាទ. ។

៧_នាយគោបាល កៀងហើយ នូវគោទ. ដោយដំបង ។

៨_មច្ចុ តែងកៀង នូវអាយុ របស់សត្វទ, ។

៩_មនុស្សទ. នឹងស្តាប់ ព្រះធម៌ របស់ព្រះសាស្តា ។

១០_អ្នកស្រែ ភ្ជួរហើយ នូវស្រែ ដោយនង្គ័ល ។



នាមដែលប្រើជំនួស ឬ ជំនួយនាមនាម ហៅថា សព្វនាម, មាន ២ យ៉ាង គឺ : បុរិសសព្វនាម ១, វិសេសនសព្វនាម ១ ។

## បុរិសសព្វនាម

**សព្វនាម** ដែលប្រើជំនួសឈ្មោះ មនុស្ស សត្វ ឬ អ្វីៗ ហៅថា **បុរិសសព្វនាម** មាន ៣ យ៉ាង គឺ :

" **ត** " ប្រែថា "ព្រះអង្គ, លោក, នាង, គេ, គាត់, វា" ១,

" **តុម្ហ** " ប្រែថា "ព្រះអង្គ, លោក, អ្នក, នាង, ឯង, អា, ហង," ១,

" **អម្ហ** " ប្រែថា "ខ្ញុំព្រះអង្គ, ខ្ញុំព្រះករុណា, ខ្ញុំបាទ, ខ្ញុំឯង, អញខ្ញុំ, ខ្ញុំម្ចាស់, ខ្ញុំ, អាត្មាភាព, អាត្មា, អញ, យើង, យើងខ្ញុំ..." ១ ។

### ត សព្ទ ក្នុងបុំលិង្គ បំបែកដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | សោ | តេ |
| ទុ. | តំ, នំ | តេ, នេ |
| ត. | តេន | តេហិ, នេហិ |
| ច. | តស្ស, អស្ស | តេសំ, តេសានំ, នេសំ, នេសានំ |

| | |
|---|---|
| បញ្ច.តស្មា, អស្មា, តម្ហា | តេហិ, នេហិ |
| ឆ. តស្ស, អស្ស, | តេសំ, តេសានំ, នេសំ, នេសានំ |
| ស. តស្មឹ, អស្មឹ, តម្ហិ, នម្ហិ | តេសុ, នេសុ |

## ត សព្ទ ក្នុងឥត្ថីលិង្គ បំបែកដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | សា | តា |
| ទុ. | តំ, នំ | តា |
| ត. | តាយ, (នាយ) | តាហិ, (នាហិ) |
| ច. | តស្សា, អស្សា, តិស្សា, តិស្សាយ | តាសំ, (តាសានំ) |
| បញ្ច. | តាយ, (នាយ) | តាហិ, (នាហិ) |
| ឆ. | តស្សា, អស្សា, តិស្សា, តិស្សាយ | តាសំ, (តាសានំ) |
| ស. | តស្សំ, អស្សំ, (តិស្សំ, តាយំ, នាយំ) | តាសុ |

ត សព្ទ ក្នុងនបុំសកលិង្គ បំបែកដូច ត សព្ទ ក្នុងបុំលិង្គដែរ ប្លែកតែ ប. ឯក. ជា តំ ប. ទុ. ពហុ. ជា តានិ ប៉ុណ្ណោះ ។

តុម្ហ សព្ទ ជាតិលិង្គិកៈ គឺ បុំ. ឥ. និង នបុំ. បំបែកតែបែបមួយដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ត្វំ, តុវំ | តុម្ហេ, (តុម្ហំ, តុម្ហានំ), វោ |
| ទុ. | តំ, តវំ, តុវំ, (ត្វំ) | តុម្ហេ, (តុម្ហាកំ, តុម្ហំ, តុម្ហានំ), វោ |
| ត. | តយា, (ត្វយា) តេ, | តុម្ហេហិ, វោ |
| ច. | តុយ្ហំ, (តុម្ហំ), តវ, តេ | តុម្ហាកំ, វោ |
| បញ្ច. | តយា | តុម្ហេហិ |
| ឆ. | តុយ្ហំ, (តុម្ហំ), តវ, តេ | តុម្ហាកំ, វោ |
| ស. | តយិ, (ត្វយិ) | តុម្ហេសុ |

អម្ហ សព្ទ ជាតិលិង្គិកៈ គឺ បុំ. ឥ. និង នបុំ. បំបែកតែបែបមួយដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | អហំ | មយំ, (អម្ហេ, អម្ហំ, អម្ហានំ), នោ |
| ទុ. | មំ, មមំ | អម្ហេ, (អម្ហាកំ, អម្ហំ, អម្ហានំ), នោ |
| ត. | មយា, មេ | អម្ហេហិ, នោ |

| | | |
|---|---|---|
| ច. | មយ្ហំ, (អម្ហំ), មម (មមំ), មេ | អម្ហាកំ, នោ |
| បញ្ច. | មយា | អម្ហេហិ |
| ឆ. | មយ្ហំ, (អម្ហំ), មម, (មមំ) មេ | អម្ហាកំ, នោ |
| ស. | មយិ | អម្ហេសុ |

## លំហាត់ប្រែជាភាសាខ្មែរ

១-តវ បុត្តោ អារាមំ គច្ឆតិ ។ សោ ធម្មំ សុណាតិ ។

២-មម ធីតា គេហេ វសតិ ។ សា មញ្ចេ សេតិ ។

៣-កសកស្ស គាវោ អរញ្ញេ វិចរន្តិ ។ តេ តិណានិ ខាទន្តិ ។

៤-នារិយោ ធម្មំ សុណឹសុ ។ តា គេហេសុ បសីទន្តិ ។

៥-តុម្ហាកំ អស្សា អរញ្ញេ ធាវឹសុ ។ មយំ តេ គណ្ហិស្សាម ។

៦-ហត្ថី តុយ្ហំ កទលី ខាទិ ។ ត្វំ តំ បហរ ។

៧-សេដ្ឋិនោ ធីតា អារាមំ គច្ឆតិ ។ តស្សា ចិត្តំ សទ្ធម្មិ បសីទិ ។

៨-មម បុត្តា ធម្មំ សុណន្តិ ។ តេសំ ចិត្តំ តុស្សតិ ។

៩-ឧបាសិកាយោ សត្ថុ ធម្មំ ឧគ្គណ្ហន្តិ ។ តាសំ មនោ បមោទតិ ។

១០-ភិក្ខូ គាមំ បិណ្ឌាយ ចរឹសុ ។ តេ អារាមំ បច្ចាគមិស្សន្តិ ។

# បំពេញពាក្យបាលី ត្រង់ចន្លោះ

**១- .... ឧបជ្ឈាយោ ជិណ្ណោ ហោតិ ...... ពលវា ហោតិ ។**

- ឧបជ្ឈាយ៍ (របស់ខ្ញុំ) ជាបុគ្គលចាស់ ( លោក ) ជាអ្នកមានកម្លាំង។

**២- .... អាចរិយោ កុសលោ ហោតិ ឡ .... ព្យាធិកោ ហោតិ ។**

- អាចារ្យ (របស់លោក) ជាអ្នកឈ្លាស ។ (លោក) ជាបុគ្គល មានជំងឺ ។

**៣- ....... មយ្ហំ អាចរិយោ ហោថ ឡ ....... សិស្សោ ហោមិ ។**

- ( លោកម្ចាស់ ) ជាអាចារ្យ របស់ខ្ញុំ ។ ( ខ្ញុំ ) ជាសិស្ស ។

**៤-បិតា ....... បិយោ ហោតិ ឡ ....... អម្ហាកំ អនុកម្បតិ ។**

- បិតាជាទីស្រឡាញ់ ( នៃយើងទ. ) ។ ( លោក ) តែងអនុគ្រោះ ដល់យើងទ. ។

**៥- ......... បុត្តោ អវជាតបុត្តោ ហោតិ ឡ មហាថេរោ ........ ឱវាទំ ទស្សតិ ។**

- កូន (របស់ខ្ញុំ) ជាអវជាតបុត្រ ។ មហាថេរៈ នឹងឱ្យនូវឱវាទ (ដល់វា) ។

**៦-ធម្មំ តិក្ខវេ ........ ទេសិស្សាមិ ។**

- ម្នាលភិក្ខុទ. តថាគត នឹងសំដែង នូវធម៌ ( ដល់អ្នកទ. ) ។

**៧-បិតា មរិ ឡ ជេដ្ឋកោ បុត្តោ ......... ធនំ លភតិ ។**

- ឪពុក ស្លាប់ហើយ ។ កូនច្បង តែងបាននូវទ្រព្យ ( របស់គាត់ ) ។

**៨. ....... ធីតា គេហេ វសតិ ។ ....... មញ្ចេ សយតិ ។**

. ធីតា ( របស់ខ្ញុំ ) នៅក្នុងផ្ទះ ។ ( វា ) ដេក លើគ្រែ ។

**៩.ភិក្ខុ គាមំ ....... ចរិស្សុ ។ ....... អារាមំ បច្ចាគមិស្សន្តិ ។**

. ភិក្ខុទ. ត្រាច់ទៅ កាន់ស្រុក ( ដើម្បីបិណ្ឌបាត ) ។ ( លោកទ. ) នឹងត្រឡប់មកវិញ កាន់វត្ត ។

**១០.ឧបាសិកាយោ ...... ធម្មំ សុណន្តិ ។ ...... ចិត្តំ បសីទតិ ។**

. ឧបាសិកាទ. ស្តាប់ នូវធម៌ ( នៃព្រះសាស្តា ) ។ ចិត្ត ( របស់នាងទ. ) រមែងជ្រះថ្លា ។

## លំហាត់ប្រែជាភាសាបាលី

១.គោ របស់ខ្ញុំ ទៅ ស្រែ ។ វា កំពុងស៊ី ស្មៅទ. ។

២.មាន់ញីទ. ទើបមក កាន់ផ្ទះ ។ វាទ. កំពុងដេក ។

៣.កូនប្រុសទ. របស់ខ្ញុំ ទៅហើយ កាន់វត្ត ។ វាទ. កំពុងស្តាប់ ធម៌។

៤.កូនស្រីទ. របស់លោក តែងស្តាប់ ធម៌ ។ ចិត្ត របស់វាទ. កំពុង-ជ្រះថ្លា ។

៥.ឆ្កែ កំពុងស៊ី បាយ ។ ចូរឯង វាយ វា ។

៦.សេះទ. កំពុងបោល តាមផ្លូវ ។ យើង នឹងចាប់ នូវវាទ. ។

៧.ឧបាសកទ. កំពុងស្តាប់ ធម៌ ។ ចិត្ត របស់គាត់ទ. តែងរីករាយ ក្រៃលែង ។

៨_គោ របស់អ្នក កំពុងឈរ ជិតផ្ទះ របស់ខ្ញុំ ។

៩_ឥសីទ. ច្រើនអង្គ នៅហើយ ក្នុងវត្ត របស់យើងទ. ។

១០_អ្នកទ. គួរប្រគេន អាហារ ដល់ឥសីទ. ។

## វិសេសនសព្វនាម

សព្វនាមសម្រាប់ប្រើជាជំនួយនាមនាម មានលំនាំជាបទ_វិសេសនៈ ហៅថា វិសេសនសព្វនាម, មាន ២ យ៉ាងគឺ : និយម ១ អនិយម ១ ។

## និយម

វិសេសនសព្វនាម ដែលសំដែងសេចក្តីទៀងទាត់ដាច់ស្រេច ហៅថា **និយម** មាន ៥ សព្ទ គឺ : **ត** "នោះ", **ឯត** "នុ៎ះ, នុ៎ះហ្ន៎, ហ្នឹង, នេះ", **ឥម** "នេះ", **ឥតរ** "ម្នាក់ទៀត, មួយទៀត, ក្រៅនេះ", **អមុ** " ឯនោះ, ( ឯណោះ )" ។

## អនិយម

វិសេសនសព្វនាម ដែលសំដែងសេចក្តីមិនទៀងទាត់ មិនដាច់ស្រេច ហៅថា **អនិយម** មាន ១២ សព្ទគឺ: **យ** "ឯណា, ណា, ដែល" **អញ្ញ** "ដទៃ, ឯទៀត" **អញ្ញតរ**, **អញ្ញតម** "ណាមួយ, ម្នាក់" **បរ** "ដទៃ, ឯទៀត" **អបរ** "ដទៃទៀត, ផ្សេងទៀត" **កតរ**, **កតម**,

"ណា, ណាមួយ, ណាខ្លះ, អ្វី, ដូចម្ដេច" **ឯក** "ពួកមួយ" **ឯកច្ច** "អ្នកខ្លះ, ពួកខ្លះ, ខ្លះ", **សព្វ** "ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រុង", **កឹំ** "ណា, អ្នកណា, ដូចម្ដេច, អ្វី" ។

## **បំបែកខាង អនិយម មុន**

### យ សព្ទ ក្នុងបុំលិង្គ បំបែកដូច្នេះ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. **យោ** | **យេ** |
| ទុ. **យំ** | **យេ** |
| ត. **យេន** | **យេហិ** |
| ច. **យស្ស** | **យេសំ, យេសានំ** |
| បញ្ច. **យស្មា, យម្ហា** | **យេហិ** |
| ឆ. **យស្ស** | **យេសំ, យេសានំ** |
| ស. **យស្មឹ, យម្ហិ** | **យេសុ** |

### **យ សព្ទ ក្នុងឥត្ថីលិង្គ បំបែកដូច្នេះ**

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. **យា** | **យា** |
| ទុ. **យំ** | **យា** |

| | | |
|---|---|---|
| ត. | យាយ | យាហិ |
| ច. | យស្សា | យាសំ, យាសានំ |
| បញ្ច. | យាយ | យាហិ |
| ឆ. | យស្សា | យាសំ, យាសានំ |
| ស. | យស្សំ, (យាយំ) | យាសុ |

យ សព្ទ ក្នុងនបុំសកលិង្គ បំបែកដូច យ សព្ទ ក្នុងបុំលិង្គដែរ ប្លែកតែ ប. ឯក. ជា យំ, ប. ទុ. ពហុ, ជា យានិ ប៉ុណ្ណោះ ។

អនិយម ១០ សព្ទ គឺ អញ្ញ, អញ្ញតរ, អញ្ញតម, បរ, អបរ, កតរ, កតម, ឯក, ឯកច្ច, សព្វ, និង ឧភយ, "ទាំងពីរ" នេះ បំបែក ដូច យ សព្ទ ក្នុងលិង្គទាំង ៣ ។

កឹ សព្ទ គង់រូបនៅជា កឹ តែក្នុងនបុំសកលិង្គ ប. ទុ. ឯក. ប៉ុណ្ណោះ ក្រៅពីនេះ ផ្លាស់ជា ក ហើយបំបែកក្នុងត្រៃលិង្គ ដូច យ សព្ទ ។

## វិធីបំបែកខាង និយម

**ត-សព្ទ** មានវិធីបំបែកទាំង ៣ លិង្គ ត្រូវគ្នានឹង ត សព្ទជា បុរិសសព្វនាមដែរ ព្រោះហេតុនោះ មិនបាច់បំបែកក្នុងទីនេះទៀតទេ ។

**ឯត**-សព្ទ បើជាបុំលិង្គ ប. ឯក. **ឯសោ**, ពហុ, **ឯតេ** ។ ល ។

បើជា ឥត្ថីលិង្គ ជា **ឯសា, ឯតា** ។ នបុំ. ជា **ឯតំ, ឯតានិ** ។ ល ។

មិនប្លែកអំពីវិធីបំបែក **ឥ** សព្ទ តាមលិង្គទាំង ៣ ខាងលើទេ ។

## ឥម សព្ទ ក្នុងបុំលិង្គ បំបែកដូច្នេះ

| ឯកវចនៈ | | ពហុវចនៈ |
|---|---|---|
| ប. | **អយំ** | **ឥមេ** |
| ទុ. | **ឥមំ** | **ឥមេ** |
| ត. | **ឥមិនា, អនេន** | **ឥមេហិ,** (**ឯហិ**) |
| ច. | **ឥមស្ស, អស្ស** | **ឥមេសំ, ឥមេសានំ** (**ឯសំ**) |
| បញ្ច. | **ឥមស្មា, ឥមម្ហា, អស្មា** | **ឥមេហិ, ឯហិ** |
| ឆ. | **ឥមស្ស, អស្ស** | **ឥមេសំ, ឥមេសានំ** (**ឯសំ**) |
| ស. | **ឥមស្មឹ, ឥមម្ហិ, អស្មឹ** | **ឥមេសុ,** (**ឯសុ**) |

## ឥម សព្ទ ក្នុងឥត្ថីលិង្គ បំបែកដូច្នេះ

| ឯកវចនៈ | | ពហុវចនៈ |
|---|---|---|
| ប. | **អយំ** | **ឥមា** |
| ទុ. | **ឥមំ** | **ឥមា** |
| ត. | **ឥមាយ,** | **ឥមាហិ** |
| ច. | **ឥមិស្សា, ឥមិស្សាយ,អស្សា** | **ឥមាសំ, ឥមាសានំ,** |

| | |
|---|---|
| បញ្ច. ឥមាយ, | ឥមាហិ |
| ឆ. ឥមិស្សា, ឥមិស្សាយ, អស្សា | ឥមាសំ, ឥមាសានំ |
| ស. ឥមិស្សំ, អស្សំ, ( ឥមាយំ ) | ឥមាសុ |

ឥម សព្ទ ក្នុងនបុំសកលិង្គ បំបែកដូច ឥម សព្ទ ក្នុងបុំលិង្គ ដែរ ប្លែកតែ ប. ទុ. ឯក. ជា ឥទំ ប. ទុ. ពហុ. ជា ឥមានិ ប៉ុណ្ណោះ។

### អមុ សព្ទ ក្នុងបុំលិង្គ បំបែកដូច្នេះ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. អមុ, អសុ | អមូ |
| ទុ. អមុំ | អមូ |
| ត. អមុនា | អមូហិ |
| ច. អមុស្ស, អមុនោ | អមូសំ, អមូសានំ |
| បញ្ច. អមុស្មា, អមុម្ហា | អមូហិ |
| ឆ. អមុស្ស, អមុនោ | អមូសំ, អមូសានំ |
| ស. អមុស្មឹ, អមុម្ហិ | អមូសុ |

## អមុ សព្ទ ក្នុងឥត្ថីលិង្គ បំបែកដូច្នេះ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. អមុ, អសុ | អមូ |
| ទុ. អមុំ | អមូ |
| ត. អមុយា | អមូហិ |
| ច. អមុស្សា | អមូសំ, អមូសានំ |
| បញ្ច. អមុយា | អមូហិ |
| ឆ. អមុស្សា | អមូសំ, អមូសានំ |
| ស. អមុស្សំ, (អមុយំ) | អមូសុ |

អមុ សព្ទ ក្នុងនបុំសកលិង្គ បំបែកដូចក្នុងបុំលិង្គ ប្លែកតែ ប. ទុ. ឯក. ជា អទុំ ពហុ. ជា អមូនិ ប៉ុណ្ណោះ ។

### លំហាត់ប្រែជាភាសាខ្មែរ

១-យោ ពាលំ សេវតិ, សោ វិនាសំ បាបុណាតិ ។

២-មាតា បុត្តំ អនុសាសតិ, សោ តស្សា ឱវាទេ តិដ្ឋតិ ។

៣-យេ ធម្មំ ចរន្តិ, តេ សុខំ អនុភវន្តិ ។

៤-អាចរិយោ សិស្សានំ ឱវាទំ ទេតិ, តេ តំ សុណន្តិ ។

៥-កុមារា សិប្បំ សិក្ខន្តិ, តេ វុឌ្ឍឹ បាបុណន្តិ ។

៦-សព្វេ មម បុត្តា សត្ថុ សាសនេ បព្វជឹសុ ។

៧-យា ឧបាសិកា សីលេ តិដ្ឋតិ, តស្សា ចិត្តំ បសីទតិ ។

៨-យេ បាបានិ ករោន្តិ, តេ មហន្តំ ទុក្ខំ អនុភវិស្សន្តិ ។

៩-កា នាម នារី អម្ហាកំ ឱទនំ បចិស្សតិ ។

១០-កោ នាម ចោរោ សព្វេសំ ជនានំ ធនានិ ចោរេតិ ។

## បំពេញពាក្យបាលី ត្រង់ចន្លោះ

១-យោ ជនោ ទុច្ចរិតំ ចរតិ, .......... ទុក្ខំ អនុភវតិ ។

- ជនណា ប្រព្រឹត្ត នូវទុច្ចរិត ( ជននោះ ) រមែងសោយ នូវទុក្ខ ។

២-យេ កុមារា សិប្បំ សិក្ខន្តិ ........... ធនំ លភន្តិ ។

-កុមារទ. ណា សិក្សា នូវសិប្បៈ(កុមារទ. នោះ) តែងបាន នូវទ្រព្យ ។

៣- ......... វចនំ វទាមិ ......... វទេហិ ។

- ខ្ញុំពោល នូវពាក្យ ( ណា ) អ្នកចូរ ពោល នូវពាក្យ ( នោះ ) ។

៤-យា ឧបាសិកា សីលេ តិដ្ឋតិ, ........ ចិត្តំ បសីទតិ ។

- ឧបាសិកាណា តាំងនៅ ក្នុងសីល ចិត្ត (របស់ឧបាសិកានោះ) រមែងជ្រះថ្លា ។

៥-មាតា បុត្តំ អនុសាសតិ ......... តស្សា ឱវាទេ តិដ្ឋតិ ។

-មាតា ប្រៀនប្រដៅ នូវកូន,( វា ) តាំងនៅក្នុងឱវាទ នៃមាតា នោះ ។

**៦-ភត្តស្ស ភិក្ខុនោ ចីវរំ ទេម សោ ........ លភតិ ។**

- យើងទ. ប្រគេន ចីវរ ដល់ភិក្ខុអង្គណា ភិក្ខុអង្គនោះ តែងបាន (នូវចីវរនោះ) ។

**៧-កតរស្មឹ អារាមេ វសសិ, .......... លង្ការាមេ វសាមិ ។**

- អ្នកនៅ ក្នុងអារាម ណាមួយ, ( ខ្ញុំ ) នៅក្នុងលង្ការាម ។

**៨-កោ តវ អាចរិយោ ហោតិ ...... មយ្ហំ អាចរិយោ ហោតិ ។**

- អ្នកណា ជាអាចារ្យ របស់អ្នក ( លោក ) ជាអាចារ្យ របស់ខ្ញុំ ។

**៩-មយំ ភត្តំ ....... ភិក្ខុនោ ទេម, សោ ...... បដិគ្គណ្ហតិ ។**

- យើងទ. ឱ្យនូវភត្ត ដល់ភិក្ខុ (ណាមួយ) ភិក្ខុនោះ ទទួល (នូវភត្តនោះ) ។

**១០- ....... រាជា ធម្មេ តិដ្ឋតិ ....... បជា សុខំ លភតិ ។**

- ព្រះរាជា ( ណា ) ស្ថិតនៅ ក្នុងធម៌ ប្រជា ( នៃព្រះរាជាអង្គនោះ ) តែងបាន នូវសេចក្តីសុខ ។

## លំហាត់ប្រែជាភាសាបាលី

១-ជនណា គប់រក បុគ្គលពាល, ជននោះ រមែងបាន សេចក្តីវិនាស ។

២-បិតា ប្រៀនប្រដៅ កូនស្រី, នាង តែងតាំងនៅ ក្នុងឱវាទ របស់គាត់ ។

៣-ជនទ. ណា ប្រព្រឹត្ត ធម៌, ជនទ. នោះ តែងបាន នូវសេចក្តីសុខ ។

៤-លោកគ្រូ ឱ្យ ឱវាទ ដល់សិស្សទ. គេទ. តែងតែស្តាប់ ឱវាទនោះ ។

៥-កុមារីទ. សិក្សា សិប្បៈទ. , គេទ. នឹងបាន សេចក្តីចំរើន ។

៦.កូនប្រុសទ. គ្រប់គ្នា របស់អ្នកស្រែ នឹងបួស ក្នុងពុទ្ធសាសនា ។

៧.ឧបាសិកាទ. ឯណា តាំងនៅ ក្នុងសីលទ. , ចិត្ត របស់គាត់ទ. រមែងជ្រះថ្លា ។

៨.ជនណា ធ្វើ បាប, ជននោះ តែងដល់ ទុក្ខ ធំ ។

៩.ស្រីទ. ឈ្មោះអ្វី កំពុងដាំ បាយ ដើម្បីលោកទ. ។

១០.បុរស ឈ្មោះអ្វី លួច គោទ. របស់គេ ។

## សំខ្យាសព្ទ

សព្ទសម្រាប់រាប់នាមនាម ហៅថា **សំខ្យា** មាន ២ យ៉ាងគឺ : **បកតិសំខ្យា ១ , បូរណសំខ្យា ១** ។

សំខ្យាដែលរាប់តាមប្រក្រតី ឱ្យដឹងចំនួននាមនាម គឺរាប់ថា "មួយ, ពី, បី, បួន, ប្រាំ, " ជាដើម ហៅថា **បកតិសំខ្យា** ចែកចេញជា ៣ ពួក គឺ :

.តាំងពី **ឯក** "មួយ" រៀងដល់ **ចតុ** "បួន" ហៅថា **សំខ្យាសព្វនាម**,

.តាំងពី **បញ្ច** "ប្រាំ" រៀងដល់ **អដ្ឋនវុតិ** "កៅសិបប្រាំបី" ហៅថា **សំខ្យាគុណនាម** ,

.តាំងពី **ឯកូនសតំ** ឬ *ឱនសតំ* "កៅសិបប្រាំបួន" រៀងដល់

**អសង្ខេយ្យ** "អសង្ខេយ្យ" ជួនណាហៅថា **សំខ្យាគុណនាម** ជួនណាហៅថា **សំខ្យានាមនាម**, ។

-**បូរណសំខ្យា** ហៅថា **សំខ្យាគុណនាម** ។

## វិធីរាប់បកតិសំខ្យា

ដើម្បីឱ្យងាយចំណាំ, វិធីរាប់បកតិសំខ្យា ចែកជា ៤ ផ្នែកដូច្នេះ

ផ្នែកទី ១ វិធីរាប់ពីត្រឹម ១ ដល់ ១០

| សព្ទបាលី | សព្ទប្រែ | សព្ទបាលី | សព្ទប្រែ |
|---|---|---|---|
| **ឯក** | ១ | **ឆ** | ៦ |
| **ទ្វិ** | ២ | **សត្ត** | ៧ |
| **តិ** | ៣ | **អដ្ឋ** | ៨ |
| **ចតុ** | ៤ | **នវ** | ៩ |
| **បញ្ច** | ៥ | **ទស** | ១០ |

**ផ្នែកទី ២ វិធីរាប់ពីត្រឹម ១១ ដល់ ៩៩**

| សព្ទបាលី | សព្ទប្រែ |
|---|---|
| **ឯកាទស, ឯការស** | ១១ |
| **ទ្វាទស, ពារស** | ១២ |
| **តេរស** | ១៣ |
| **ចតុទ្ទស, ចុទ្ទស, ចោទ្ទស** | ១៤ |

| សព្ទបាលី | សព្ទប្រែ |
|---|---|
| បញ្ចទស, បណ្ណរស | ១៥ |
| សោឡស | ១៦ |
| សត្តរស | ១៧ |
| អដ្ឋារស | ១៨ |
| .ឯកូនវីស, *ឩនវីស*, ឯកូនវីសតិ, *ឩនវីសតិ* | ១៩ |
| វីស, វីសតិ | ២០ |
| ឯកវីស, ឯកវីសតិ | ២១ |
| ទ្វាវីស, ទ្វាវីសតិ, ពាវីស, ពាវីសតិ | ២២ |
| តេវីស, តេវីសតិ | ២៣ |
| ចតុវីស, ចតុវីសតិ, ចតុព្វីស, ចតុព្វីសតិ | ២៤ |
| បញ្ចវីស, បញ្ចវីសតិ | ២៥ |
| ឆព្វីស, ឆព្វីសតិ | ២៦ |
| សត្តវីស, សត្តវីសតិ | ២៧ |
| អដ្ឋវីស, អដ្ឋវីសតិ | ២៨ |
| .ឯកូនតឹស, ឯកូនតឹសតិ, *ឩនតឹស*, *ឩនតឹសតិ* | ២៩ |
| តឹស, តឹសតិ | ៣០ |
| ឯកត្តឹស, ឯកត្តឹសតិ | ៣១ |

| សព្ទបាលី | សព្ទប្រែ |
|---|---|
| ទ្វត្តឹស, ទ្វត្តឹសតិ, ពត្តឹស, ពត្តឹសតិ | ៣២ |
| តេត្តឹស, តេត្តឹសតិ | ៣៣ |
| ចតុត្តឹស, ចតុត្តឹសតិ | ៣៤ |
| បញ្ចត្តឹស, បញ្ចត្តឹសតិ | ៣៥ |
| ឆត្តឹស, ឆត្តឹសតិ | ៣៦ |
| សត្តត្តឹស, សត្តត្តឹសតិ | ៣៧ |
| អដ្ឋត្តឹស, អដ្ឋត្តឹសតិ | ៣៨ |
| .ឯកូនចត្តាឡីស, *ឩនចត្តាឡីស*, ឯកូនតាឡីស, *ឩនតាឡីស* | *៣៩* |
| ចត្តាឡីស, តាឡីស | ៤០ |
| ឯកចត្តាឡីស, ឯកត្តាឡីស | ៤១ |
| ទ្វេចត្តាឡីស, ទ្វេតាឡីស | ៤២ |
| តេចត្តាឡីស, ទ្វេតាឡីស | ៤៣ |
| ចតុច្ចត្តាឡីស, ចតុត្តាឡីស | ៤៤ |
| បញ្ចចត្តាឡីស, បញ្ចត្តាឡីស | ៤៥ |
| ឆចត្តាឡីស, ឆត្តាឡីស | ៤៦ |
| សត្តចត្តាឡីស, សត្តត្តាឡីស | ៤៧ |

| សព្ទបាលី | សព្ទប្រែ |
| --- | --- |
| អដ្ឋចត្តាឡីស, អដ្ឋត្តាឡីស | ៤៨ |
| .ឯកូនបញ្ញាស, *ឩនបញ្ញាស*, ឯកូនបណ្ណាស, *ឩនបណ្ណាស* | ៤៩ |
| បញ្ញាស, បណ្ណាស | ៥០ |
| ឯកបញ្ញាស, ឯកបណ្ណាស | ៥១ |
| ទ្វេបញ្ញាស, ទ្វេបណ្ណាស | ៥២ |
| តេបញ្ញាស, តេបណ្ណាស | ៥៣ |
| ចតុប្បញ្ញាស, ចតុប្បណ្ណាស | ៥៤ |
| បញ្ចបញ្ញាស, បញ្ចបណ្ណាស | ៥៥ |
| ឆប្បញ្ញាស, ឆប្បណ្ណាស | ៥៦ |
| សត្តបញ្ញាស, សត្តបណ្ណាស | ៥៧ |
| អដ្ឋបញ្ញាស, អដ្ឋបណ្ណាស | ៥៨ |
| .ឯកូនសដ្ឋី, *ឩនសដ្ឋី* | ៥៩ |
| សដ្ឋី | ៦០ |
| ឯកសដ្ឋី | ៦១ |
| ទ្វេសដ្ឋី, ទ្វាសដ្ឋី | ៦២ |
| តេសដ្ឋី | ៦៣ |

| សព្ទបាលី | សព្ទប្រែ |
|---|---|
| ចតុស្សដ្ឋី | ៦៤ |
| បញ្ចសដ្ឋី | ៦៥ |
| ឆស្សដ្ឋី | ៦៦ |
| សត្តសដ្ឋី | ៦៧ |
| អដ្ឋសដ្ឋី | ៦៨ |
| .ឯកូនសត្តតិ, *ឩនសត្តតិ,* ឯកូនសត្តរិ, *ឩនសត្តរិ* | ៦៩ |
| សត្តតិ, សត្តរិ | ៧០ |
| ឯកសត្តតិ, ឯកសត្តរិ | ៧១ |
| ទ្វេសត្តតិ, ទ្វេសត្តរិ | ៧២ |
| តេសត្តតិ, តេសត្តរិ | ៧៣ |
| ចតុស្សត្តតិ, ចតុស្សត្តរិ | ៧៤ |
| បញ្ចសត្តតិ, បញ្ចសត្តរិ | ៧៥ |
| ឆស្សត្តតិ, ឆស្សត្តរិ | ៧៦ |
| សត្តសត្តតិ, សត្តសត្តរិ | ៧៧ |
| អដ្ឋសត្តតិ, អដ្ឋសត្តរិ | ៧៨ |
| .ឯកូនអសីតិ, ឯកូនាសីតិ, *ឩនអសីតិ, ឩនាសីតិ,* | ៧៩ |

| សព្ទបាលី | សព្ទប្រែ |
| --- | --- |
| **អសីតិ** | ៨០ |
| **ឯកអសីតិ, ឯកាសីតិ** | ៨១ |
| **ទ្វេអសីតិ, ទ្វាសីតិ** | ៨២ |
| **តេអសីតិ, តេ្យាសីតិ** | ៨៣ |
| **ចតុអសីតិ, ចតុរាសីតិ** | ៨៤ |
| **បញ្ចអសីតិ, បញ្ចាសីតិ** | ៨៥ |
| **ឆអសីតិ, (ឆាសីតិ), ឆរាសីតិ, ឆឡាសីតិ** | ៨៦ |
| **សត្តអសីតិ, សត្តាសីតិ** | ៨៧ |
| **អដ្ឋអសីតិ, អដ្ឋាសីតិ** | ៨៨ |
| **.ឯកូននវុតិ,** *ឧនទវុតិ* | ៨៩ |
| **នវុតិ** | ៩០ |
| **ឯកនវុតិ** | ៩១ |
| **ទ្វេនវុតិ, ទ្វានវុតិ** | ៩២ |
| **តេនវុតិ** | ៩៣ |
| **ចតុន្នវុតិ** | ៩៤ |
| **បញ្ចនវុតិ** | ៩៥ |

| សព្ទបាលី | សព្ទប្រែ |
|---|---|
| **ឆន្នវុតិ** | ៩៦ |
| **សត្តនវុតិ** | ៩៧ |
| **អដ្ឋនវុតិ** | ៩៨ |
| .**ឯកូនសតំ,** *ឩនសតំ* | ៩៩ |

**ផ្នែកទី ៣ វិធីរាប់ពីត្រឹម រយ ដល់ កោដិ**

| | |
|---|---|
| **សតំ** | រយ ( ១00 ) |
| **សហស្សំ** | ពាន់ ( ១.000 ) |
| **ទសសហស្សំ** | ម៉ឺន ( ១0.000 ) |
| **សតសហស្សំ, (លក្ខំ)** | សែន ( ១00.000 ) |
| **ទសសតសហស្សំ** | លាន ( ១.000.000 ) |
| **កោដិ** | កោដិ ( ១0.000.000 ) |

**ផ្នែកទី ៤ វិធីរាប់ពីត្រឹម បកោដិ ដល់ អសំខេយ្យ**

| | |
|---|---|
| **បកោដិ** | រយសែនកោដិ |
| **កោដិបកោដិ** | រយសែនបកោដិ |
| **នហុតំ** | រយសែនកោដិបកោដិ |
| **និន្នហុតំ** | រយសែននហុត |

| សព្ទបាលី | សព្ទប្រែ |
|---|---|
| **អក្ខោភិនី** | រយសែននិន្នហុត |
| **ពិន្ទុ** | រយសែនអក្ខោភិនី |
| **អព្វុទំ** | រយសែនពិន្ទុ |
| **និរព្វុទំ** | រយសែនអព្វុទៈ |
| **អហហំ** | រយសែននិរព្វុទៈ |
| **អពពំ** | រយសែនអហហៈ |
| **អដដំ** | រយសែនអពពៈ |
| **សោគន្ធិកំ** | រយសែនអដដៈ |
| **ឧប្បលំ** | រយសែនសោគន្ធិកៈ |
| **កុមុទំ** | រយសែនឧប្បលៈ |
| **បុណ្ឌរីកំ** | រយសែនកុមុទៈ |
| **បទុមំ** | រយសែនបុណ្ឌរីកៈ |
| **កថានំ** | រយសែនបទុមៈ |
| **មហាកថានំ** | រយសែនកថានៈ |
| **អសំខេយ្យំ** | រយសែនមហាកថានៈ ។ |

# **វិធីប្រើ ឧត្តរ និង អធិក**

សំខ្យាគុណនាម គឺចំនួនពី ១ ដល់ ៩៨ តភ្ជាប់នឹងសំខ្យានាមនាម គឺចំនួនតាំងពី ១០០ ឡើងទៅ ត្រូវប្រើ **ឧត្តរ** " លើស " ដាក់ត្រង់ចន្លោះសំខ្យាទាំង ២ ដូចជា ១០១, ១,០០២ ។ ល ។ ៩០៩ ត្រូវផ្សំ **ឯក** + **ឧត្តរ** + **សតំ** > **ឯកុត្តរសតំ** ប្រែថា ១០០ លើសដោយ ១, **ទ្វិ** + **ឧត្តរ** + **សហស្សំ** > **ទ្វយុត្តរសហស្សំ** ប្រែថា ១.០០០ លើសដោយ ២, **នវ** + **ឧត្តរ** + **នវសតំ** > **នវុត្តរនវសតំ** ប្រែថា ៩០០ លើសដោយ ៩ ។

សំខ្យានាមនាម តនឹងសំខ្យានាមនាមដូចគ្នា គឺចំនួនពី ១០០ ឡើងទៅតនឹងចំនួនតាំងពី ១០០០ ឡើងទៅ ត្រូវប្រើ **អធិក** " ក្រៃលែង " ដាក់ត្រង់ចន្លោះដូចជា ១.១០០, ២.៣០០ ។ ល ។ ១២.៤០០ ត្រូវផ្សំ **សត** + **អធិក** + **សហស្សំ** > **សតាធិកសហស្សំ** ប្រែថា ១.០០០ ក្រៃលែងដោយ ១០០, **តិសត** + **អធិក** + **ទ្វិសហស្សំ** > **តិសតាធិកទ្វិសហស្សំ** ប្រែថា ២.០០០ ក្រៃលែងដោយ ៣០០, **ចតុស្សត** + **អធិក** + **ទ្វិសហស្ស** + **អធិក** + **ទសសហស្សំ** > **ចតុស្សតាធិកទ្វិសហស្សាធិក-ទសសហស្សំ** ប្រែថា ១០.០០០ ក្រៃលែងដោយ ២,០០០ ក្រៃលែងដោយ ៤០០ ។

# វិធីបំបែក បកតិសំខ្យា

ឯក បើប្រើជាសំខ្យាសព្វនាម ជាឯកវចនៈតែម្យ៉ាង បំបែកដូច្នេះ

| បុំលិង្គ ឯក. | | ឥត្ថីលិង្គ ឯក. | | នបុំសកលិង្គ ឯក. | |
|---|---|---|---|---|---|
| ប. | ឯកោ | ប. | ឯកា | ប. | ឯកំ |
| ទុ. | ឯកំ | ទុ. | ឯកំ | ទុ. | ឯកំ |
| ត. | ឯកេន | ត. | ឯកាយ | ត. | ឯកេន |
| ច. | ឯកស្ស | ច. | ឯកាយ | ច. | ឯកស្ស |
| បញ្ច. | ឯកស្មា | បញ្ច. | ឯកាយ | បញ្ច. | ឯកស្មា |
| ឆ. | ឯកស្ស | ឆ. | ឯកាយ | ឆ. | ឯកស្ស |
| ស. | ឯកស្មឹ | ស. | ឯកាយ | ស. | ឯកស្មឹ |

ទ្វិ បំបែកដូចគ្នាទាំង ៣ លិង្គដូច្នេះ

ពហុវចនៈ

| | |
|---|---|
| ប. | ទ្វេ, ទុវេ |
| ទុ. | ទ្វេ, ទុវេ |
| ត. | ទ្វីហិ |
| ច. | ទ្វិន្នំ, ទុវិន្នំ |
| បញ្ច. | ទ្វីហិ |
| ឆ. | ទ្វិន្នំ, ទុវិន្នំ |
| ស. | ទ្វីសុ |

ឧភ "ទាំងពីរ" បំបែកដូច្នេះ

ពហុវចនៈ

| | |
|---|---|
| ប. | ឧភោ |
| ទុ. | ឧភោ |
| ត. | ឧភោហិ |
| ច. | ឧភិន្នំ |
| បញ្ច. | ឧភោហិ |
| ឆ. | ឧភិន្នំ |
| ស. | ឧភោសុ |

## តិ ទាំងបីលិង្គ បំបែកផ្សេងគ្នាដោយអន្លើ ដូច្នេះ

| បុំលិង្គ ពហុ. | | ឥត្ថីលិង្គ ពហុ. | | នបុំសកលិង្គ ពហុ. | |
|---|---|---|---|---|---|
| ប. | តយោ | ប. | តិស្សោ | ប. | តីណិ |
| ទុ. | តយោ | ទុ. | តិស្សោ | ទុ. | តីណិ |
| ត. | តីហិ | ត. | តីហិ | ត. | តីហិ |
| ច. | តិណ្ណំ, តិណ្ណន្នំ | ច. | តិស្សន្នំ | ច. | តិណ្ណំ, តិណ្ណន្នំ |
| បញ្ច. | តីហិ | បញ្ច. | តីហិ | បញ្ច. | តីហិ |
| ឆ. | តិណ្ណំ, តិណ្ណន្នំ | ឆ. | តិស្សន្នំ | ឆ. | តិណ្ណំ, តិណ្ណន្នំ |
| ស. | តីសុ | ស. | តីសុ | ស. | តីសុ |

## ចតុ ទាំងបីលិង្គ បំបែកផ្សេងគ្នាដោយអន្លើ ដូច្នេះ

| បុំលិង្គ ពហុ. | | ឥត្ថីលិង្គ ពហុ. | | នបុំសកលិង្គ ពហុ. | |
|---|---|---|---|---|---|
| ប. | ចត្តារោ | ប. | ចតស្សោ | ប. | ចត្តារិ |
| ទុ. | ចត្តារោ | ទុ. | ចតស្សោ | ទុ. | ចត្តារិ |
| ត. | ចតូហិ | ត. | ចតូហិ | ត. | ចតូហិ |
| ច. | ចតុន្នំ | ច. | ចតស្សន្នំ | ច. | ចតុន្នំ |
| បញ្ច. | ចតូហិ | បញ្ច. | ចតូហិ | បញ្ច. | ចតូហិ |
| ឆ. | ចតុន្នំ | ឆ. | ចតស្សន្នំ | ឆ. | ចតុន្នំ |
| ស. | ចតូសុ | ស. | ចតូសុ | ស. | ចតូសុ |

## **បញ្ច បំបែកដូចគ្នានាំងបីលិង្គ ដូច្នេះ**

| ពហុវចនៈ | | ពហុវចនៈ | |
|---|---|---|---|
| ប. | **បញ្ច** | បញ្ញ. | **បញ្ចហិ** |
| ទុ. | **បញ្ច** | ឆ. | **បញ្ចន្នំ** |
| ត. | **បញ្ចហិ** | ស. | **បញ្ចសុ** |
| ច. | **បញ្ចន្នំ** | | |

តាំងពី ឆ " ៦ " ដល់ **អដ្ឋារស** " ១៨ " បំបែកដូច **បញ្ច** ។ តាំងពី **ឯកូនវីស** " ១៩ " រៀងដល់ **អដ្ឋនវុតិ** " ៩៨ " ដែលមាន **ស** នៅខាងចុងត្រូវចុះ **អា**_បច្ច័យ ជា **សា** បំបែកដូច **កញ្ញា** ខាងឯកវចនៈ, ប្លែកអំពី **កញ្ញា** តែត្រង់បឋមាវិភត្តិ ត្រូវរស្សៈ **អា** ជា **អ** ក៏បាន ចុះនិគ្គហិតអាគមជា **សំ** ក៏បានខ្លះ, ដែលមានស្រះ **ឥ** នៅខាងចុងបំផុត ដូចយ៉ាង **ឯកូនវីសតិ** ជាដើម ត្រូវបំបែកដូច "**រត្តិ** " ខាងឯកវចនៈ, ដែលមានស្រះ **ឦ** នៅខាងចុងបំផុត ដូចយ៉ាង **ឯកូនសដ្ឋី** ជាដើម ត្រូវបំបែកដូច "**នារី** " ខាងឯកវចនៈ ប៉ុន្តែត្រង់ទុតិយាវិភត្តិ ចុះនិគ្គហិត ក៏បានខ្លះ ។ ឯ **សត** និង **សហស្ស**
បំបែកដូច " **កុល** " ទាំងពីរវចនៈ ។

# បូរណសំខ្យា

របៀបបំបែក បូរណសំខ្យា ទាំង ៣ លិង្គដូច្នេះ

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ | ពាក្យប្រែ |
|---|---|---|---|
| បឋមោ | បឋមា | បឋមំ | ទី ១ |
| ទុតិយោ | ទុតិយា | ទុតិយំ | ទី ២ |
| តតិយោ | តតិយា | តតិយំ | ទី ៣ |
| ចតុត្ថោ | ចតុត្ថី, ចតុត្ថា | ចតុត្ថំ | ទី ៤ |
| ។ល។ | ។ល។ | ។ល។ | ។ល។ |
| អសង្ខេយ្យមោ | អសង្ខេយ្យមា | អសង្ខេយ្យមំ | ទី ឬគំរប់អសង្ខេយ្យ |

**បូរណសំខ្យា** បំបែកតាមដំណើរលិង្គទាំង ៣ សព្ទណាជាលិង្គណា មានការន្តយ៉ាងណា ត្រូវបំបែកតាមលិង្គនោះ ការន្តនោះ ។

## លំហាត់ប្រែជាភាសាខ្មែរ

**១-មយំ ឥមេ ចត្តារោ បច្ចយេ សង្ឃស្ស ទេម ។**

**២-មយំ ឥមានិ តីណិ ចីវរានិ សង្ឃស្ស ទេម ។**

**៣-តីសុ បុត្តេសុ ទុតិយោ សិក្ខាគារំ គច្ឆិ ។**

**៤-ចតូសុ ធីតូសុ បឋមា ចត្តារិ វត្ថានិ កីណិ ។**

**៥-បញ្ចមេ ទិវសេ បញ្ច កសកា វីសតិយា ភិក្ខូនំ ទានំ ទេន្តិ ។**

៦-តីសាយ ភិក្ខុស្ស សត្ថមោ បញ្ញាសាយ ជនានំ ធានំ ទេតិ ៕
៧-ឧស ទ្វាសកា វីសតិយា បទុមេហិ ធម្មំ បូជេសុំ ៕
៨-វីសតិ សិស្សា បាលិភាសំ សិក្ខន្តិ ៕
៩-អហំ សោឡស វត្ថូនិ លភាមិ ៕
១០-កតិវស្សោសិ ត្វំ , អហំ បញ្ចវីសតិវស្សោម្ហិ ៕

### បំពេញពាក្យបាលី ត្រង់ចន្លោះ

**១-ទ្វិសុ .......... ឯកោ គោណោ មរិ ។**

-( បណ្តាគោទ.) ២ គោ ១ ស្លាប់ ហើយ ។

**២-រាជា .......... សេនានំ ឋានំ ទេតិ ។**

- ព្រះរាជា ប្រទាន នូវឋានៈ ដល់សេនាទ.( ១៨ នាក់ )

**៣-មយ្ហំ បិតា ភត្តំ ......... បព្វជិតានំ ទេតិ ។**

- បិតា របស់ខ្ញុំ ប្រគេន ភត្ត ដល់បព្វជិតទ.( ៤៤ អង្គ ) ។

**៤-......... នាដកា រញ្ញោ មហោសវេ គាយន្តិ ។**

- អ្នករបាំទ.( ៥០០ នាក់ ) ច្រៀង ក្នុងមហោស្រព របស់ព្រះរាជា ។

**៥- .........រាជានោ ពារាណសីរញ្ញោ សន្តិកំ គច្ឆឹសុ ។**

- ស្តេចទ.( ១០១ អង្គ ) យាងទៅហើយ កាន់សំណាក់ នៃព្រះរាជា ក្រុងពារាណសី ។

**៦-បច្ចុប្បន្នេ ......... មនុស្សា បទេសេ រុក្ខេ រោបេន្តិ ។**

-ក្នុងបច្ចុប្បន្ន មនុស្សទ. (១០ សែននាក់) ដាំ នូវដើមឈើទ. ក្នុងប្រទេស ។

**៧-មម ធីតា .......... ពុទ្ធសកេ វិជាយិ ។**

- កូនស្រី របស់ខ្ញុំ កើតហើយ ក្នុងពុទ្ធសករាជ ( ទី ២៥៤០ ) ។

**៨-តស្ស បិតា .......... សំវច្ឆរេ មរិ ។**

- ឪពុក របស់គាត់ ស្លាប់ហើយ ក្នុងឆ្នាំ ( ទី ១៩០០ ) ។

**៩-( ......... ) ឧបាសកា ......... បុប្ផេហិ ធម្មំ បូជេសុំ ។**

- ឧបាសកទ. (១០ នាក់) បូជាហើយ នូវធម៌ ដោយផ្កាទ. ( ៣ ទង ) ។

**១០- មយំ .......... បច្ចយេ ........ ភិក្ខូនំ ទទិម្ហា ។**

- យើងទ. ប្រគេនហើយ នូវបច្ច័យទ. ( ៤ ) ដល់ភិក្ខុទ. ( ៥ អង្គ ) ។

## លំហាត់ប្រែជាភាសាបាលី

១-ខ្ញុំ ប្រគេន បច្ច័យទ. បួន ដល់ភិក្ខុទ. ៣០ អង្គ ។

២-អ្នកទ. ចូរចាត់ចែង ចីវរទ. បី ដល់សមណៈទ. ។

៣-បណ្តាបុរសទ. ប្រាំនាក់ បុរសទី ៣ ទៅកាន់វត្ត ។

៤-បណ្តានារីទ. ដប់នាក់ នារីទីប្រាំ ទិញហើយ នូវផ្កាឈូកទ. ២០ ផ្កា ។

៥-ក្នុងថ្ងៃទីដប់ ទាយកទ. ម្ភៃនាក់ ប្រគេនភត្ត ដល់ភិក្ខុទ. ៥០ អង្គ ។

៦-បណ្តាភិក្ខុទ. ៥០ អង្គ ភិក្ខុទី ១០ សំដែងធម៌ ដល់មនុស្សទ. ៦០ នាក់។

៧_កុមារីទ. បួននាក់ បូជា នូវធម៌ ដោយសំពត់ទ. ប្រាំបី ។

៨_បណ្ដាសិស្សទ. ១៩ នាក់ សិស្សទ. ២ នាក់ រៀន នូវវិន័យ ។

៩_កូនស្រីទ. ពីរនាក់ របស់សេដ្ឋី អង្គុយហើយ ក្នុងបន្ទប់ ។

១០_ឪពុក របស់ខ្ញុំ ប្រគេនហើយ នូវសាដកទ. ២៥ ដល់ភិក្ខុទ. ។

## អព្យយសព្ទ

សព្ទដែលមិនវិនាសប្រែប្រួលចាកភាពដើមរបស់ខ្លួន ហៅថា អព្យយសព្ទ ប្រែថា " សព្ទមិនវិនាស " ឬហៅថា អលិង្គ ប្រែថា " សព្ទគ្មានលិង្គ ចែកជា ៣ ពួក គឺ ឧបសគ្គ ១ ពួក, និបាត ១ ពួក, បច្ច័យ ១ ពួក ។

**ឧបសគ្គ** នោះមាន ២០ សព្ទ គឺ

**អតិ** កន្លង, ក្រៃ, ក្រៃពេក, ពេក, ....

**អធិ** ក្រៃលែង, ក្រៃពេក, លើសលប់, សង្កត់, លើសលែង, ....

**អនុ** តាម, តូច, បន្ទាប់, រង, ក្រោយ, បណ្ដោយ, លំដាប់, ....

**អប** ប្រាស, គេច, ចៀស, ....

**អបិ** ឬ **បិ** ជិត, ខាងលើ, ....

**អភិ** ក្រៃពេក, ធំ, ចំពោះ, ឆ្ពោះ, ខាងមុខ,....

**អវ** ឬ **ឱ** ចុះ, ចុះក្រោម, ទាប, ស្រេច, ....

**អា** ទូទៅ, សព្វ, ក្រៃលែង, ....

ឧ ឡើង, ខ្ពស់, ក្រៅ, ....

ឧប ជិត, ចូល, ចូលទៅជិត, មាំ, ស៊ប់, ....

ទុ អាក្រក់, ក្រ, កម្រ, លំបាក ( ពិបាក ), ....

និ ចេញ, មិនសល់, មិនមាន, ឥត, ....

នី ចេញ, ចូល, ចុះ, ....

ប ទូទៅ, ខាងមុខ, ចេញ, មុន,....

បដិ ឬ បតិ ចំពោះ, តប, ត, ច្រាស, ត្រឡប់ ។

បរា ខាងមុខ, .....

បរិ ជុំ, ជុំវិញ, គ្រប់គ្រាន់, ស្រេច, .....

វិ ផ្សេង, ប្លែក, ច្បាស់, ជាក់, ប្រាកដ, .....

សំ ព្រម, ជាមួយ, ល្អ, ប្រពៃ,.....

សុ ងាយ, ស្រួល, ស្រណុក, ល្អ, ប្រពៃ, ណាស់, ម្ល៉េះ, អ្វីម្ល៉េះ,...

និបាត មានច្រើនអនេក ( ចូរមើលកច្ចាយនូបត្ថម្ភកៈ និង សម្ពន្ធមាលា ) ។

បច្ច័យ មាន ២២ តួ គឺ : តោ, ត្រ, ត្ថ, ហ, ធ, ធិ, ហឹ, ហំ, ហិញ្ចនំ, ទ ; ទា, ទានិ, រហិ, ធុនា, ទាចនំ, ជ្ជ, ជ្ជុ ; តវេ, តុំ, ត្វា, ត្វាន, តូន ។

**ឧបសគ្គៈ** បើនាំមុខនាមនាម មានអាការៈដូចគុណនាម ជាបទវិសេសនៈ ឧ. **បតិ** "ម្ចាស់, ចៅហ្វាយ" **អធិបតិ** "ចៅហ្វាយធំ" **នាយកោ** "នាយក" **អនុនាយកោ** "នាយករង, នាយកបន្ទាប់" ។ បើនាំមុខគុណនាម ច្រើនតែជា អតិវិសេសគុណនាម ឧ. **សុន្ទរោ** "ល្អ" **អតិសុន្ទរោ** "ល្អណាស់" បើនាំមុខកិរិយាសព្ទ មានអាការៈដូចកិរិយាវិសេសនៈ ឧ. **ជានាតិ** "ដឹង, ស្គាល់, ចេះ" **បជានាតិ** "ដឹង-ច្បាស់, ស្គាល់ជាក់, ចេះប្រាកដ" ។ ល ។ យ៉ាងនេះ ហៅថា **ឧបសគ្គានុលោម** "អនុលោមតាមឧបសគ្គ ឬ ឧបសគ្គអនុលោម" ។

**ឧបសគ្គ** បៀតបៀន ឬបំបែកសព្ទ បំបែកធាតុ ចាកលំនាំដើម ឱ្យក្លាយជាសេចក្ដីផ្សេង ហៅថា **ឧបសគ្គគុស** ឧ. **ភវតិ** "កើត, មាន" **អនុភវតិ** "សោយ, ទទួល, រង" **អភិភវតិ** "គ្របសង្កត់, រំលោភ, គំរាម", **គច្ឆតិ** "ទៅ, ដល់" **អាគច្ឆតិ** "មក", **អធិគច្ឆតិ** "លុះ, បាន, ត្រាស់ដឹង" **ភវោ** "សេចក្ដីចំរើន" **បរាភវោ** "សេចក្ដីវិនាស, អ្នកវិនាស" ។ ល ។

**បច្ច័យ ២២ តួនេះ ចែកជា ៤ ពួកគឺ :**

ពួកទី ១ **តោ** ចុះខាងមុខនាមនាម ឬសព្វនាម ជំនួសវិភត្តិតតិយា និងបញ្ចមី ឬ សត្តមីបានខ្លះ, ឧ. **អត្តតោ, សព្វតោ, តតោ,**

**ឯកតោ, ឥតោ, សព្វតោ,** ។

ពួកទី ២ **ត្រ, ត្ថ, ហ, ធ, ធិ, ហឹ, ហំ, ហិញ្ចនំ, វ,** ៩ តួនេះ ចុះខាងចុងសព្វនាម ជំនួសសត្តមីវិភត្តិ ទាំង ៣ លិង្គ ទាំង ២ វចនៈ ឧ. **យត្រ, តត្ថ, ឥធ, សព្វធិ, តហំ, កុហឹ** ។

ពួកទី ៣ **ទា, ទានិ, រហិ, ធុនា, ទាចនំ, ជ្ជ, ជ្ជុ,** ៧ តួនេះ ចុះខាងចុងសព្វនាម ជំនួសសត្តមីវិភត្តិ ( ច្រើនប្រាប់ពេលវេលា ) ឧ. **យទា, តទា, ឥទានិ, ឯតរហិ, អជ្ជ,** ។

ពួកទី ៤ **តវេ, តុំ, ត្វា, ត្វាន, តូន** ៥ តួនេះ ចុះតែខាងចុងធាតុ ប៉ុណ្ណោះ ឧ. **ភាតវេ, ភាតុំ, ភត្វា, ភត្វាន,** ។ ល ។

## មេរៀនសង្ខេប

**តោ, ត្រ, ត្ថ, ហ, ហឹ, ហំ, ធ, ធិ, ហិញ្ចនំ, វ,** ( **ឝម្មិកា** ) “ប្រាប់ទីកន្លែង”

**ទានិ, ជ្ជុ, ទាចនំ, ទា, ជ្ជ, រហិ, ធុនា,** ( **តិ កាលិកា** ) “ប្រាប់កាល”

**តូន, ត្វាន, តវេ, ត្វា, តុំ,** ( **ឥតិ ធាតុនិយោជិកា** ) “ប្រកបនឹងធាតុ”

# ឋានត្ថវាចកនិបាត

| | | | | | |
|---|---|---|---|---|---|
| យត្ថ | ក្នុងទីណា | ឥធ | ក្នុងទីនេះ | ឯកត្ថ | ក្នុងទីមួយ |
| តត្រ | ក្នុងទីនោះ | កុតោ | អំពីទីណា | សព្វត្ថ | ក្នុងទីទាំងពួង |
| តត្ថ | ក្នុងទីនោះ | តតោ | អំពីទីនោះ | ឧបរិ | ឰដ៏ខាងលើ |
| | | | | ឯត្ថ | ក្នុងទីនេះ |

## លំហាត់ប្រែជាភាសាខ្មែរ

១-មយំ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា សង្ឃស្ស ទេម ។

២-មយំ ឥមានិ តីណិ ចីវរានិ សជ្ជេត្វា សង្ឃស្ស ទេម ។

៣-តីសុ បុត្តេសុ ទុតិយោ សិក្ខាគារំ អគច្ឆិ ។

៤-ចតូសុ ធីតូសុ បឋមា ចត្តារិ វត្ថានិ អកិណិ ។

៥-ឥតោ បញ្ចមេ ទិវសេ បញ្ច កសកា វីសតិយា ភិក្ខូនំ ទានំ ទេន្តិ ។

៦-តីសាយ ភិក្ខូសុ សត្តមោ បណ្ណាសាយ ជនានំ ធម្មំ ទេសេសិ ។

៧-ទស ឧបាសកា វីសតិយា បទុមេហិ ធម្មំ បូជេសុំ ។

៨-សក្កោសិ ត្វំ បាលិភាសាយ សល្លបិតុំ ។

៩-អាម អហំ ថោកំ សល្លបិតុំ សក្កោមិ ។

១០-កតិវស្សោសិ ត្វំ អាយុនា, អហំ បញ្ចវីសតិវស្សោម្ហិ អាម ។

# បំពេញពាក្យបាលី ត្រង់ចន្លោះ

**១- ........ គេហំ គច្ឆសិ ?** -អ្នកទៅ កាន់ផ្ទះ (ក្នុងពេលណា) ។

**២- ....... គេហំ គច្ឆិស្សាមិ ?** -ខ្ញុំនឹងទៅ កាន់ផ្ទះ (ក្នុងថ្ងៃស្អែក) ។

**៣- ....... គច្ឆសិ ?** -លោកទៅ (ក្នុងទីណា ) ។

**៤- ....... គច្ឆាមិ ?** -ខ្ញុំទៅ ( កាន់ស្រុកកំណើត ) ។

**៥- ....... ត្វំ ករិតុំ អាគច្ឆសិ ?** -លោកមក ដើម្បីធ្វើ (នូវអ្វី) ។

**៦-អហំ ........ ឧគ្គណ្ហិតុំ អាគមឹ ?**

-ខ្ញុំ មកហើយ ដើម្បីរៀន ( នូវភាសាបាលី ) ។

**៧- ........ សន្តិកេ បាលិភាសំ ឧគ្គណ្ហិស្សសិ ?**

-អ្នក នឹងរៀន នូវភាសាបាលី ក្នុងសំណាក់ ( នៃអ្នកណា ) ។

**៨-អហំ ឧបជ្ឈាយស្ស (.......) បាលិភាសំ ឧគ្គណ្ហិស្សាមិ ?**

-ខ្ញុំ នឹងរៀន នូវភាសាបាលី ( ក្នុងសំណាក់ ) នៃឧបជ្ឈាយ៍ ។

**៩- (........) និក្ខមិត្វា (........) គមិស្សសិ ?**

-អ្នក ចេញហើយ ( អំពីទីនេះ ) នឹងទៅ ( ក្នុងទីណា ) ។

**១០-អហំ ឥតោ និក្ខមិត្វា (.......) គេហំ គមិស្សាមិ ?**

-ខ្ញុំ ចេញហើយ អំពីទីនេះ នឹងទៅកាន់ ផ្ទះ ( របស់ខ្ញុំ ) ។

## លំហាត់ប្រែជាភាសាបាលី

១_ខ្ញុំ នាំបច្ច័យទ. បួន ហើយប្រគេន ដល់ភិក្ខុទ. ។

២_អ្នកទ. ចូរចាត់ចែង ចីវរទ. បី ហើយប្រគេន ដល់សមណៈទ. ។

៣_បណ្ដាបុរសទ. ប្រាំនាក់ បុរសទី ៣ បានទៅ ហើយកាន់វត្ត ។

៤_បណ្ដានារីទ. ដប់នាក់ នារីទី ៥ បានទិញផ្កាឈូកទ. ២០ ផ្កា ។

៥_ក្នុងថ្ងៃទីដប់ អំពីថ្ងៃនេះទៅ ទាយកទ. ម្ភៃនាក់ នឹងប្រគេន ភត្ត ដល់ភិក្ខុទ. ៥០ អង្គ ។

៦_បណ្ដាភិក្ខុទ. ៥០ អង្គ ភិក្ខុទី ១០ សំដែងធម៌ ដល់មនុស្សទ. ៦០ នាក់ ។

៧_កុមារីទ. បួននាក់ បូជា ធម៌ ដោយសំពត់ទ. ប្រាំបី ។

៨_អ្នកទ. អាច ដើម្បីសន្ទនា ដោយភាសាបាលី ( បានទេ ) ។

៩_បាទ ! យើងទ. អាច ដើម្បីសន្ទនា បន្តិចបន្តួច ( បាន ) ។

១០_ឪពុក របស់ខ្ញុំ មានឆ្នាំ ៥០ ដោយអាយុ ។

## ៣_អាខ្យាត

កិរិយាសព្ទដែលប្រាប់នូវដំណើរនៃអំពើ ដូចពាក្យថា ដេក, ដើរ, ឈរ, អង្គុយ, ស៊ី, ផឹក, និយាយ, ស្ដាប់, គិត ជាដើម ហៅថា អាខ្យាត ។ អាខ្យាតនោះ លោកកំណត់បែបគ្រឿងសំគាល់មាន ៨ គឺ វិភត្តិ, កាល, បទ, វចនៈ, បុរិសៈ, ធាតុ, វាចកៈ, បច្ច័យ ។

វិភត្តិ អាខ្យាតមាន ៨ ពួក ក្នុងពួកមួយៗ សុទ្ធតែមាន ១២ ដូចគ្នាដូច្នេះ

**១_វត្តមានា** "កំពុង_, កំពុងតែ_, ទើប_, ទើបនឹង_, ហើយ_, នឹង_, រមែង_, តែង_, តែងតែ_, គង់_, គង់តែ_," ។

| | បរស្សបទ | | អត្តនោបទ | |
|---|---|---|---|---|
| បុរិស | ឯក. | ពហុ. | ឯក. | ពហុ. |
| ប. | តិ | អន្តិ | តេ | អន្តេ |
| ម. | សិ | ថ | សេ | វ្ហេ |
| ឧ. | មិ | ម | ឯ | ម្ហេ |

| បច_ធាតុ + អ_បច្ច័យ | | | បច_ធាតុ + យ_បច្ច័យ + ឥ_អាគម | |
|---|---|---|---|---|
| | បរស្សបទ កត្តុវាចក: | | អត្តនោបទ កម្មវាចក: | |
| បុរិស | ឯក. | ពហុ. | ឯក. | ពហុ. |
| ប. | បចតិ | បចន្តិ | បចិយតេ | បចិយន្តេ |
| ម. | បចសិ | បចថ | បចិយសេ | បចិយវ្ហេ |
| ឧ. | បចាមិ | បចាម | បចិយេ | បចិយម្ហេ |

## ២_បញ្ចមី " ចូរ_, ចូរ_ចុះ, សូម_, សូមឱ្យ_ចុះ, "

| | បរស្សបទ | | អត្តនោបទ | |
|---|---|---|---|---|
| បុរិស | ឯក. | ពហុ. | ឯក. | ពហុ. |
| ប. | តុ | អន្តុ | តំ | អន្តំ |
| ម. | ហិ | ថ | ស្សុ | វ្ហោ |
| ឧ. | មិ | ម | ឯ | អាមសេ |

| បច_ធាតុ + អ_បច្ច័យ | | | បច_ធាតុ + យ_បច្ច័យ + ត៏_អា. | |
|---|---|---|---|---|
| | បរស្សបទ កត្តុ. | | អត្តនោបទ កម្ម. | |
| បុរិស | ឯក. | ពហុ. | ឯក. | ពហុ. |
| ប. | បចតុ | បចន្តុ | បចិយតំ | បចិយន្តំ |
| ម. | បចាហិ, បច | បចថ | បចិយស្សុ | បចិយវ្ហោ |
| ឧ. | បចាមិ | បចាម | បចិយេ | បចិយាមសេ |

កត្តុវាចកៈ កិរិយាសព្ទប្រាប់កត្តា "អ្នកធ្វើខ្លួនឯង" ឱ្យឡើងជាប្រធាន ប្រកបដោយបឋមាវិភត្តិ, វចនៈ ស្មើគ្នានឹងកិរិយាសព្ទ តួកម្មជាទុតិយាវិភត្តិ វចនៈ ណាក៏បាន, កិរិយាសព្ទប្រកបដោយបច្ច័យ ១៥ ណាមួយ, វិភត្តិ ទាំង ៨ ពួក ណាមួយផ្នែកបរស្សបទ ឧ. សូទោ ឱទនំ បចតិ ។ បុរិសា រុក្ខំ ឆិន្ទន្តុ ។ ត្វំ សូបំ បចាហិ ។

វិធីរៀងប្រយោគបាលី តាមធម្មតា ត្រូវរៀងបទប្រធានទី ១ បទកម្មទី ២ និងកិរិយាសព្ទទី ៣ ។ ប៉ុន្តែ មានការផ្លាស់ប្តូរទីកន្លែងគ្នាក៏មាន, ឧ. **ភវតុ សព្វមង្គលំ ។ សុណាតុ មេ ភន្តេ សង្ឃោ ។ ធាតេមិ បស្សតិ ភគ្គំ, យាវ ធាមំ ន បច្ចតិ ។**

**កម្មវាចកៈ** កិរិយាសព្ទប្រាប់កម្មដែលគេត្រូវធ្វើ ជាបទប្រធានប្រកបដោយបឋមាវិភត្តិ, វចនៈស្មើគ្នានឹងកិរិយាសព្ទ, មានកត្តាមួយប្រកបដោយតតិយាវិភត្តិ វចនៈណាក៏បាន, កិរិយាសព្ទបានតែសកម្មធាតុប្រកបដោយ **យ**-បច្ច័យ និង **ឥ**-អាគម, វិភត្តិ ទាំង ៨ ពួក ណាមួយផ្នែកអត្តនោបទ, ឧ. **សូទេន ឱទនោ បចិយតេ ឬ បច្ចតេ ។ បុរិសេហិ រុក្ខា ឆិន្ទិយន្តេ ។**

**វិធីផ្លាស់ វិភត្តិ**

វិភត្តិអាខ្យាតទាំងនោះ កាលបើប្រកបនឹងធាតុហើយ គង់រូបនៅដូចដែលក៏មាន ផ្លាស់រូបផ្សេងៗ ទៅក៏មាន យ៉ាងនេះ :

**តិ, អន្តិ** + **អស**-ធាតុ ផ្លាស់ជា **ត្ថិ** ឧ, **អត្ថិ, នត្ថិ** ឬជា (**អស្សុ**) ខ្លះ ផ្លាស់ **អន្តិ** ជា " **រេ** " ខ្លះ ឧ. **ទុច្ចរេ, ឧយ្ហរេ, វិរោចរេ** ។

**សិ, ថ** + **អស**-ធាតុ ផ្លាស់ជា **អសិ, អត្ថ** ។

**មិ, ម** វត្តមានា និង បញ្ចមី មានអំណាចឱ្យទីឃៈស្រៈខាង ដើមខ្លួនដែលជារស្សៈ ឧ. **បចាមិ, បចាម** ។ បើនៅខាងចុង **ឥា**-ធាតុ

ឱ្យផ្លាស់ អា នៃ ឧា ជានិគ្គហិត ហើយផ្លាស់និគ្គហិត ជា "ម" ឧ. ឧម្ហិ, ឧម្ហ ។ បើប្រកបនឹង អស-ធាតុ ផ្សំជា អម្ហិ, អម្ហ, អស្មិ, អស្ម ។

តេ, អន្តេ, សេ, វ្ហេ, ឯ, ម្ហេ អត្តនោបទ បើផ្សំនឹង ករ-ធាតុ ទៅជា ករិយតេ = កយ្យតេ, កយ្យន្តេ ។ល។ ករិយម្ហេ = កយ្យម្ហេ ។

ត្ថ ប្រកបនឹង អស-ធាតុ ផ្លាស់ជា ត្ថ ឧ. អត្ថ ។

ហិ មានអំណាចឱ្យទីឃៈស្រះខាងដើមខ្លួន ដូច មិ, ម ដែរ តែបើលុបហើយ មិនត្រូវទីឃៈទេ, បើស្រះខាងដើមខ្លួនជាទីឃៈ ក៏ត្រូវតែរស្សៈ ឧ. បស្ស, គច្ឆ, ជាន ។

## លំហាត់ប្រែជាភាសាខ្មែរ

១-មា បរេសំ ជនានំ វត្ថំ គវេសថ (កត្តុ.) ។

២-អត្តនោ វត្ថំ គវេសេត្វា តំ បជហថ (កត្តុ.) ។

៣-មយំ ភន្តេ ឥមានិ ចីវរានិ អានេត្វា សង្ឃស្ស ទេម (កត្តុ.) ។

៤-សង្ឃោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហតុ (កត្តុ.) ។

៥-ន ភជេ បាបកេ មិត្តេ ភជេថ បុរិសុត្តមេ (កត្តុ.) ។

៦-ឥទំ សិប្បំ សិស្សេហិ សិក្ខាគារេ សិក្ខិយតេ (កម្ម.) ។

៧-មាតាបិតូហិ ឱវាទោ បុត្តធីតូនំ ទីយតេ (កម្ម.) ។

៨_បញ្ញ សិក្ខាបទានិ ភិក្ខូនា ឧបាសកានំ ទីយន្តេ (កម្ម.) ។

៩_អយំ ធម្មោ អម្ហាកំ សត្ថារា មហាជនានំ ទេសិយតេ (កម្ម.) ។

១០_ឥមានិ បុប្ផានិ មេ មាតរា តវ អាចរិយស្ស ទីយន្តេ (កម្ម.) ។

## បំពេញពាក្យបាលី ត្រង់ចន្លោះ

១_ឧបជ្ឈាយោ វិនយំ ......... វាចេតិ ។

_ ឧបជ្ឈាយ៍ បង្រៀន នូវវិន័យ ( ដល់សិស្សទ. ) ។

២_ .......... វិនយោ សិស្សានំ វាចិយតេ ។

_ វិន័យ ( គឺឧបជ្ឈាយ៍ ) បង្រៀន ដល់សិស្សទ. ។

៣_សង្ឃោ ........, ........ បដិគ្គណ្ហាតិ ។

_ ព្រះសង្ឃ ទទួល ( នូវបច្ច័យទ. ៤ នេះ ) ។

៤_ ........, ........., .......... សង្ឃេន បដិគ្គហិយន្តេ ។

_ ( បច្ច័យទ. ៤ នេះ ) គឺព្រះសង្ឃ ទទួល ។

៥_សាមណេរា ឧបដ្ឋានសាលាយ ........ ភុញ្ជន្តិ ។

_ សាមណេរទ. កំពុងឆាន់ ( នូវភត្ត ) ក្នុងឧបដ្ឋានសាលា ។

៦_ ........ ឧបដ្ឋានសាលាយំ ភត្តំ ភុញ្ជិយតេ ។

_ ភត្ត ( គឺសាមណេរទ. ) ឆាន់ ក្នុងឧបដ្ឋានសាលា ។

៧_ ........... សិស្សានំ ឱវាទំ ទេតិ ។

_ (លោកគ្រូ ) តែងឱ្យនូវឱវាទដល់សិស្ស ទ. ។

## ៨_គរុនា ........ សិស្សានំ ឱវទេ ។

_( ឱវាទ ) គឺគ្រូ ឱ្យ ដល់សិស្សទ. ។

## ៩_ឧបាសកា ..........., ......... សមាទិយន្តិ ។

_ ឧបាសកទ. សមាទាន ( នូវសីលទ. ៨ ) ។

## ១០_ ........ អដ្ឋ សីលានិ សមាទីយន្តេ ។

_ សីលទ. ៨ ( គឺឧបាសកទ. ) សមាទាន ។

## លំហាត់ប្រែជាភាសាបាលី

១_អ្នកទ. កុំមើល ទោស របស់មនុស្សទ. ដទៃ ។

២_អ្នកទ. គប្បីមើល ទោស របស់ខ្លួន ។

៣_យើងខ្ញុំទ. សូមវេរប្រគេន នូវបច្ច័យទ. ៤ ចំពោះភិក្ខុទ. ។

៤_ភិក្ខុទ. សូមទទួលយក នូវសេនាសនៈទ. នេះ ។

៥_បុគ្គលទ. គួរគប់រក នូវបណ្ឌិតទ. មិនត្រូវគប់រក នូវមិត្តអាក្រក់ទេ ។

៦_វិជ្ជា នេះ គឺអ្នកទ. តែងតែសិក្សា ។

៧_ឱវាទ គឺលោកគ្រូទ. តែងឱ្យ ដល់សិស្សទ. ។

៨_សិក្ខាបទទ. ៨ គឺសាមណេរ ឱ្យ ដល់ទាយកទ. ។

៩_ធម៌ របស់ព្រះពុទ្ធ គឺសាវ័កទ. សំដែងប្រាប់ ដល់ឧបាសកទ. ។

១០_បច្ច័យទ. បួន គឺទាយកទ. ប្រគេន ដល់ភិក្ខុសង្ឃ ។

## ៣_សត្តមី "គួរ_, គួរតែ_," "គប្បី_, ត្រូវ_,"

| | បរស្សបទ | | អត្តនោបទ | |
|---|---|---|---|---|
| បុរិស, | ឯក. | ពហុ. | ឯក. | ពហុ. |
| ប. | ឯយ្យ | ឯយ្យុំ | ឯថ | ឯរំ |
| ម. | ឯយ្យាសិ | ឯយ្យាថ | ឯថោ | ឯយ្យវ្ហោ |
| ឧ. | ឯយ្យាមិ | ឯយ្យាម | ឯយ្យំ | ឯយ្យាម្ហេ |

**វន្ទ_ធាតុ + អ_បច្ច័យ** **វន្ទ_ធាតុ + យ_បច្ច័យ + ឥ_អា.**

| | បរស្សបទ កត្តុ. | | អត្តនោបទ កម្ម. | |
|---|---|---|---|---|
| បុរិស, | ឯក. | ពហុ. | ឯក. | ពហុ. |
| ប. | វន្ទេយ្យ, វន្ទេ | វន្ទេយ្យុំ | វន្ទិយេថ | វន្ទិយេរំ |
| ម. | វន្ទេយ្យាសិ | វន្ទេយ្យាថ | វន្ទិយេថោ | វន្ទិយេយ្យវ្ហោ |
| ឧ. | វន្ទេយ្យាមិ | វន្ទេយ្យាម | វន្ទិយេយ្យំ | វន្ទិយេយ្យាម្ហេ |

## ៤_បរោក្ខា "…. ហើយ "

| | បរស្សបទ | | អត្តនោបទ | |
|---|---|---|---|---|
| បុរិស, | ឯក. | ពហុ. | ឯក. | ពហុ. |
| ប. | អ | ឧ | ត្ថ | រេ |
| ម. | ឯ | ត្ថ | ត្ថោ | វ្ហោ |
| ឧ. | អំ | ម្ហ | ឥំ | ម្ហេ |

**វន្ទ_ធាតុ + អ_បច្ច័យ** **វន្ទ_ធាតុ + យ_បច្ច័យ + ឥ_អា.**

| បរស្សបទ កត្តុ. | | | អត្តនោបទ កម្ម. | |
|---|---|---|---|---|
| បុរិស, | ឯក. | ពហុ. | ឯក. | ពហុ. |
| ប. | **វន្ទ** | **វន្ទុ** | **វន្ទិយត្ថ** | **វន្ទិយរេ** |
| ម. | **វន្ទេ** | **វន្ទិត្ថ** | **វន្ទិយត្ថោ** | **វន្ទិយវ្ហោ** |
| ឧ. | **វន្ទំ** | **វន្ទិម្ហ** | **វន្ទិយឹ** | **វន្ទិយម្ហេ** |

**ហេតុកត្តុវាចកៈ** កិរិយាសព្ទប្រាប់ហេតុកត្តា ( អ្នកធ្វើជាហេតុ គឺអ្នកប្រើគេ ) ជាបទប្រធាន ប្រកបដោយបឋមាវិភត្តិ វចនៈណាមួយ, កត្តា គឺអ្នកទទួលបង្គាប់ ជាទុតិយា ឬ តតិយាវិភត្តិ វចនៈណាក៏បាន, តួកម្មប្រកបដោយទុតិយាវិភត្តិ, កិរិយាសព្ទប្រកបដោយបច្ច័យ ៤ គឺ **ណេ, ណយ, ណាបេ, ណាបយ** បច្ច័យណាមួយ, វិភត្តិ ៨ ពួកផ្នែកខាងបរស្សបទ, ឧទាហរណ៍ **សាមិកោ សូទេន ឱទនំ បាចេតិ ។** .... **បាចយតិ ។** ..... **បាចាបេតិ ។** ...... **បាចាបយតិ ។**

## កិរិយាសព្ទ ជាហេតុកត្តុវាចកៈ

| | | | |
|---|---|---|---|
| **ការាបេតិ** | ញុំាង....ឱ្យធ្វើ | **និសីទាបេតិ** | ញុំាង...ឱ្យអង្គុយ |
| **គណ្ហាបេតិ** | - .....ឱ្យកាន់យក | **ហារាបេតិ** | - ....ឱ្យនាំទៅ |
| **ឧគ្គណ្ហាបេតិ** | - .....ឱ្យរៀនយក | **អាហារាបេតិ** | -.....ឱ្យនាំមក |

| | |
|---|---|
| នយាបេតិ - ......ឱ្យង្វែត | គច្ឆាបេតិ - ......ឱ្យទៅ |
| ភោជាបេតិ - ......ឱ្យបរិភោគ | អាគច្ឆាបេតិ - ....ឱ្យមក |

## វិធីផ្លាស់ វិភត្តិ

ឯយ្យ លុប យ្យ ទុកតែ ឯ ខ្លះ ឧ. ភវេ, ជហេ, ភរេ, ប្រើ ឯថ អត្តនោបទ ជំនួសខ្លះ ឧ. ភវេថ, ភជេថ, ផ្លាស់ជា អា ខ្លះ ឧ. កយិរា, ផ្លាស់ជា ឥយា ខ្លះ ឧ. ជានិយា, សិយា, ផ្លាស់ជា ញ្ញា ខ្លះ ឧ. ជញ្ញា, ផ្លាស់ជាមួយ អស ធាតុជា អស្ស ខ្លះ ។

ឯយ្យុំ ប្រកបនឹង អស-ធាតុ ផ្លាស់ជា ឥយុំ ខ្លះ ឧ. សិយុំ ផ្លាស់ជា អស្សុ ខ្លះ,

ឯយ្យាសិ, ឯយ្យាថ, ឯយ្យាមិ, ឯយ្យាម ផ្លាស់ជាមួយនឹង អស-ធាតុទៅជា អស្ស, អស្សថ, អស្សំ, អស្សាម ។ល។

ឯយ្យាមិ ប្រើ ឯយ្យំ អត្តនោបទជំនួសបាន ឧ. ភវេយ្យំ, មុញ្ចេយ្យំ ។ល។

ឯយ្យាម ផ្លាស់ជា ឯមុ ខ្លះ ឧ. ជានេមុ ។ ក្រៅពីនេះ គង់រូបនៅដូចដើម ។

អ ឱ , បរោក្ខា ប្រកបនឹង ព្រូ-ធាតុ បានរូបជា អាហ, អាហុ ។ល។

## ៥_ហីយត្តនី "... ហើយ, បាន... ហើយ, កុំ... ឡើយ"

| បុរិស, | បរស្សបទ ឯក. | បរស្សបទ ពហុ. | អត្តនោបទ ឯក. | អត្តនោបទ ពហុ. |
|---|---|---|---|---|
| ប. | អា | ឩ | ត្ថ | ត្ថុំ |
| ម. | ឱ | ត្ថ | សេ | វ្ហំ |
| ឧ. | អំ | ម្ហា | ឥំ | ម្ហសេ |

បច_ធាតុ + អ_បច្ច័យ + អ_អា. បរស្សបទ កត្តុ, បំបែកដូច្នេះ

បរស្សបទ កត្តុ.

| បុរិស, | ឯក. | ពហុ. |
|---|---|---|
| ប. | អបចា, អបច | អបចូ |
| ម. | អបចោ | អបចត្ថ |
| ឧ. | អបចំ | អបចម្ហា |

បច_ធាតុ + យ_បច្ច័យ + អ_អា. អត្តនោបទ កម្ម. បំបែកដូច្នេះ

អត្តនោបទ កម្ម.

| បុរិស, | ឯក. | ពហុ. |
|---|---|---|
| ប. | អបចិយត្ថ | អបចិយត្ថុំ |
| ម. | អបចិយសេ | អបចិយវ្ហំ |
| ឧ. | អបចិយឹ | អបចិយម្ហសេ |

## ៦_អជ្ជតនី "... ហើយ, បាន... ហើយ"

| | បរស្សបទ | | អត្តនោបទ | |
|---|---|---|---|---|
| បុរិស, | ឯក. | ពហុ. | ឯក. | ពហុ. |
| ប. | ឍ្ល | ទ្ធំ | អោ | ឩ |
| ម. | ឡិ | ត្ថ | សេ | វ្ហំ |
| ឧ. | ឥំ | ម្ហា | អំ | ម្ហេ |

**បច_ធាតុ + អ_បច្ច័យ + អ_អា. + ឥ_អា.** បរស្សបទ កត្តុ.

បំបែកដូច្នេះ

បរស្សបទ កត្តុ.

| បុរិស, | ឯក. | ពហុ. |
|---|---|---|
| ប. | **អបចិ, អបចេសិ** | **អបចុំ, អបចឹសុ** |
| ម. | **អបចោ** | **អបចិត្ថ** |
| ឧ. | **អបចឹ** | **អបចិម្ហា** |

**បច_ធាតុ + ណយ_បច្ច័យ + ឥ_អា. + អ~អា. អត្តនោបទ កម្ម.**

បំបែកដូច្នេះ

អត្តនោបទ កម្ម.

| បុរិស, | ឯក. | ពហុ. |
|---|---|---|
| ប. | **អបចិយា** | **អបចិយុំ** |
| ម. | **អបចិយសេ** | **អបចិយវ្ហំ** |
| ឧ. | **អបចិយំ** | **អបចិយម្ហេ** |

**ហេតុកម្មវាចកៈ** កិរិយាសព្ទប្រាប់ហេតុកម្ម គឺកម្មដែលគេត្រូវប្រើអ្នកដទៃឱ្យធ្វើជាបទប្រធាន ប្រកបដោយបឋមាវិភត្តិ, កត្តាជាអ្នកប្រើ ប្រកបដោយតតិយាវិភត្តិ អ្នកទទួលបង្គាប់ ប្រកបដោយទុតិយា ឬ តតិយាវិភត្តិ, កិរិយាសព្ទប្រកបដោយបច្ច័យ សម្រាប់ពួកធាតុផង ចុះការិតប្បច្ច័យ **ឥ**_អាគម និង **ណយ**_បច្ច័យផង វិភត្តិទាំង ៨ ពួក ផ្នែកខាងអត្តនោបទ, ឧ. **សាមិកេន សូទំ ឱទនោ បាចាបិយតេ** បាយដែល ម្ចាស់ ញ៉ាំងអ្នកគ្រួ ឱ្យចំអិន ។

...... **ឱទនា បាចាបិយន្តេ ៗ រុន្ធាបិយតេ, រុន្ធាបិយន្តេ** ដែល ...... ញ៉ាំង ...... ឱ្យបិទ ។ **សុណាបិយតេ, សុណាបិយន្តេ** ដែល... ញ៉ាំង... ឱ្យស្តាប់ ។ **ភីនាបិយតេ, ភីនាបិយន្តេ** គឺ ....

ញុំាង .... ឱ្យទិញ ។ **គាហាបិយតេ, គាហាបិយន្តេ** គឺ... ញុំាង... ឱ្យកាន់យក ។

**វិធីផ្លាស់ វិភត្តិ**

**អា** ហើយត្តនី ច្រើនតែរស្សៈជា **អ**, ឧ. **អបច** ។ **ឧ** ជា **អបចុ** ។

**ឱ** ហីយត្តនី និងអជ្ជត្តនី ប្រើ **ឡ** ជំនួស ឬផ្លាស់ **ឱ** ជា **ឥ** តែម្តង ឧ. **អបចិ** ។

**អំ, ម្ហ** ហីយត្តនី ច្រើនមាន **អ**_អាគម, ឧ. **អគ្ងមំ, អគ្ងមម្ហ** ។

**ឡ** ច្រើនតែរស្សៈជា **ឥ**, ឧ. **អទធិ, អជិនិ**, ចុះ **ស** និង **ហ** អាគម ហើយរស្សៈ **ឡ** ជា **ឥ**, ឧ. **អទាសិ, បតិដ្ឋាហិ** ផ្លាស់ជា **ច្ឆិ** ខ្លះ ឧ. **អភ្លោច្ឆិ** ផ្លាស់ជា **ត្ថ** ខ្លះ ឧ. **អលត្ថ**, រស្សៈ **ឡ** ជា **ឥ** ហើយទីឃៈ ស្រះខាងដើមខ្លះ, ឧ. **អាសិ, បតិដ្ឋាសិ** ។

**ឱំ** ផ្លាស់ជា **ឥស្មុំ** បានខ្លះ ឧ. **វិព្ភមឹស្មុំ, សញ្ជានឹស្មុំ** ផ្លាស់ជា **អឹស្មុំ** ខ្លះ ឧ. **អភឹស្មុំ**, បើមិនផ្លាស់ទេ អាចទីឃៈដើមធាតុបានខ្លះ ឧ. **អាសិត្ថ** ។

**ឥំ** ផ្លាស់ជា **ត្ថំ** បានខ្លះ ឧ. **អលត្ថំ** ។

## ៧_ភវិស្សន្តិ " នឹង... "

| បរស្សបទ | | | អត្តនោបទ | |
|---|---|---|---|---|
| បុរិស, | ឯក. | ពហុ. | ឯក. | ពហុ. |
| ប. | ស្សតិ | ស្សន្តិ | ស្សតេ | ស្សន្តេ |
| ម. | ស្សសិ | ស្សថ | ស្សសេ | ស្សវ្হេ |
| ឧ. | ស្សាមិ | ស្សាម | ស្សំ | ស្សាម្হេ |

**បច_ធាតុ + អ_បច្ច័យ + ឥ_អា. បរស្សបទ កត្តុ. បំបែកដូច្នេះ**

បរស្សបទ

| បុរិស, | ឯក. | ពហុ. |
|---|---|---|
| ប. | **បចិស្សតិ** | **បចិស្សន្តិ** |
| ម. | **បចិស្សសិ** | **បចិស្សថ** |
| ឧ. | **បចិស្សាមិ** | **បចិស្សាម** |

**បច_ធាតុ + យ_បច្ច័យ + ឥ_អា. អត្តនោបទ កម្ម. បំបែកដូច្នេះ**

អត្តនោបទ

| បុរិស, | ឯក. | ពហុ. |
|---|---|---|
| ប. | **បចិយិស្សតេ** | **បចិយិស្សន្តេ** |
| ម. | **បចិយិស្សសេ** | **បចិយិស្សវ្হេ** |
| ឧ. | **បចិយិស្សំ** | **បចិយិស្សាម្হេ** |

## ៨_កាលាតិបត្តិ " នឹង... ហើយ_, នឹងបាន... ហើយ "

| | បរស្សៃបទ | | អត្តនោបទ | |
|---|---|---|---|---|
| បុរិស, | ឯក. | ពហុ. | ឯក. | ពហុ. |
| ប. | ស្សា | ស្សំសុ | ស្សថ | ស្សឹស្សុ |
| ម. | ស្សេ | ស្សថ | ស្សសេ | ស្សវ្ហេ |
| ឧ. | ស្សំ | ស្សាម្ហា | ស្សំ | ស្សាម្ហសេ |

**បច_ធាតុ + អ_បច្ច័យ + ឥ_អា. បរស្សៃបទ កត្តុ. បំបែកដូច្នេះ**

បរស្សៃបទ កត្តុ.

| បុរិស, | ឯក. | ពហុ. |
|---|---|---|
| ប. | **អបចិស្សា, អបចិស្ស** | **អបចិស្សំសុ** |
| ម. | **អបចិស្សេ** | **អបចិស្សថ** |
| ឧ. | **អបចិស្សំ** | **អបចិស្សាម្ហា** |

**បច_ធាតុ + យ_បច្ច័យ + ឥ_អា. អត្តនោបទ កម្ម. បំបែកដូច្នេះ**

អត្តនោបទ កម្ម.

| បុរិស, | ឯក. | ពហុ. |
|---|---|---|
| ប. | **អបចិយិស្សថ** | **អបចិយិស្សឹសុ** |
| ម. | **អបចិយិស្សសេ** | **អបចិយិស្សវ្ហេ** |
| ឧ. | **អបចិយិស្សំ** | **អបចិយិស្សាម្ហសេ** |

ភាវវាចកៈ មានកត្តាមួយប្រកបដោយតតិយាវិភត្តិ, កិរិយាសព្ទច្រើនតែជាអកម្មធាតុ ប្រកបដោយ យ-បច្ច័យ, វត្តមានាវិភត្តិ គឺ តេ អត្តនោបទ, ឧ. តេន ភូយតេ ។

## វិធីផ្លាស់ វិភត្តិ

**ស្សតិ, ស្សន្តិ, ស្សសិ, ស្សថ, ស្សាមិ, ស្សាម** លុប **ស្ស** ចោល ខ្លះ, ឧ. **កាហតិ, កាហន្តិ, កាហសិ, កាហថ, កាហាមិ, កាហាម** ។

**ស្សាមិ** ផ្លាស់ជា **ខាមិ** ជា **ឆាមិ** ខ្លះ ឧ. **វក្ខាមិ, វច្ឆាមិ** ។

**ស្សាម** ផ្លាស់ជា **ខាម** ជា **ឆាម** ខ្លះ ឧ. **វក្ខាម, វច្ឆាម** ។

**ស្សា** រស្សៈ **អា** ជា **អ** ខ្លះ ឧ. **អបចិស្ស, អករិស្ស** ។

## អាគមរបស់វិភត្តិ

អាគមសម្រាប់ចុះក្នុងអាខ្យាត មាន ៥ គឺ **អ, ឥ, ស, ហ,** និង និគ្គហិត ។

**អ**-អាគម ចុះខាងដើមធាតុ ចំពោះវិភត្តិ ៣ គឺ : **ហីយត្តនី, អជ្ជត្តនី, កាលាតិបត្តិ** ។

**ឥ**-អាគម សម្រាប់ចុះត្រង់ទីបំផុតធាតុ ចំពោះវិភត្តិ ៤ គឺ : **បរោក្ខា, អជ្ជត្តនី, ភវិស្សន្តិ, កាលាតិបត្តិ** ។

**ស**_អាគម ចុះត្រង់ទីបំផុតធាតុ ចំពោះតែ **អជ្ជត្តនី** វិភត្តិមួយ ។

**ហ**_អាគម ចុះត្រង់ទីបំផុតធាតុ តាមគួរដល់ការប្រកប ។

**និគ្គហិត**_អាគម សម្រាប់ចុះក្នុងពួក រុធ_ធាតុ និងលើតួអក្ខរៈបានខ្លះ, ឧ. **ចង្កមតិ** ។

## លំហាត់ប្រែជាភាសាខ្មែរ

១_សាមិកោ សូទំ ឱទនំ បាចេតិ (ហេតុកត្តុ.) ៗ

២_បិតា បុត្តំ ធនំ លាភយតិ (ហេតុកត្តុ.) ៗ

៣_ភិក្ខុ សាមណេរេ ទ្វារានិ វិវរាបេតិ ( ហេតុកត្តុ. ) ៗ

៤_មាតរោ អត្តនោ ធីតរំ វត្ថានិ សិព្វាបេន្តិ (ហេតុកត្តុ.) ៗ

៥_ឧបាសកា បុត្តេ ពុទ្ធសាសនេ បព្វាជេន្តិ (ហេតុកត្តុ.) ៗ

៦_សាមិកេន សូទំ ឱទនោ បាចាបិយតេ (ហេតុកម្ម.) ៗ

៧_ភិក្ខុនា សាមណេរេន ទ្វារំ វិវរាបិយតេ (ហេតុកម្ម.) ៗ

៨_មាតរា ធីតរំ បទុមានិ ឱចិនាបិយិស្សន្តេ (ហេតុកម្ម.) ៗ

៩_បិតុនា បុត្តេ ធម្មោ សុណាបិយិស្សតេ (ហេតុកម្ម.) ៗ

១០_ថេរេន សាមណេរំ បត្តា គណ្ហាបិយន្តេ (ហេតុកម្ម.) ៗ

# បំពេញពាក្យបាលី ត្រង់ចន្លោះ

**១-កសកេន ភរិយំ ឱទនោ ..........ឡ**

- បាយ គឺកសិករ ញ៉ាំងភរិយា ( ឱ្យចំអិន ) ។

**២-ភិក្ខូ ......... ធម្មំ ជនានំ ទេសាបេន្តិ ឡ**

- ភិក្ខុទ. ( ញ៉ាំងសាមណេរ ) ឱ្យសំដែង នូវធម៌ ដល់ជនទ. ។

**៣-បិតា បុត្តំ អត្តនោ ខេត្តានិ ......... ឡ**

- បិតា ញ៉ាំងកូន ( ឱ្យភ្ជួរ ) នូវស្រែទ. របស់ខ្លួន ។

**៤-អនាថបិណ្ឌិកោ ភិក្ខុសតានិ អត្តនោ គេហេ ភត្តំ ...... ឡ**

- អនាថបិណ្ឌិក ញ៉ាំងរយនៃភិក្ខុទ. (ឱ្យទទួល) នូវភត្ត ក្នុងផ្ទះរបស់ខ្លួន ។

**៥-តថាគតោ ........ សគ្គមគ្គេ ច មោក្ខមគ្គេ ច ........ ឡ**

- ព្រះតថាគត ( ញ៉ាំងមហាជន ) ( ឱ្យតាំងនៅ ) ក្នុងផ្លូវនៃស្ថានសួគ៌ផង ក្នុងផ្លូវនៃព្រះនិព្វានផង ។

**៦-ឱទនោ ........., .........., បាចាបិយតេ ឡ**

- បាយ ( គឺម្ចាស់ ) ( ញ៉ាំងអ្នកគ្រួ ) ឱ្យចំអិន ។

**៧-ទ្វារានិ ភិក្ខុនា សាមណេរេន ......... ឡ**

- ទ្វារទ. គឺភិក្ខុ ញ៉ាំងសាមណេរ ( ឱ្យបិទ ) ។

**៨_ធម្មោ បិតរា ......... សុណាបិយតេ ។**

_ ធម៌ គឺបិតា ( ញុំាងកូនទ. ) ឱ្យស្តាប់ ។

**៩_ហត្ថី អជាតសត្តុនា ហត្ថាចរិយំ ......... ។**

_ ដំរី គឺព្រះបាទអជាតសត្រូវ ញុំាងហ្មដំរី ( ឱ្យលែងទៅហើយ ) ។

**១០_ជេតវនំ អនាថបិណ្ឌិកេន ........., ........., ។**

_ វត្តជេតពន គឺអនាថបិណ្ឌិក ញុំាងជាង ( ឱ្យធ្វើហើយ ) ( ដើម្បីព្រះ_សាស្តា ) ។

## សំហាត់ប្រែជាភាសាបាលី

១_ព្រះឧបជ្ឈាយ៍ ញុំាងភិក្ខុ សាមណេរ ឱ្យថ្វាយបង្គំ ព្រះធម៌ ។

២_អំពើបាប ញុំាងសត្វទ. ឱ្យបាន នូវសេចក្តីទុក្ខ ។

៣_ព្រះធម៌ ញុំាងអ្នកប្រព្រឹត្តធម៌ ឱ្យដល់ នូវសេចក្តីសុខ ។

៤_លោកអាចារ្យ ញុំាងសិស្សទ. ឱ្យសិក្សា នូវព្រះធម៌ ។

៥_ខ្ញុំ ញុំាងសមណសិស្ស ឱ្យរៀនយក នូវភាសាបាលី ។

៦_បបរ គឺស្វាមី ញុំាងប្រពន្ធ ឱ្យចំអិន ។

៧_អាហារ គឺម្តាយ ញុំាងកូន ឱ្យហូប ។

៨_ព្រះធម៌ គឺលោកគ្រូ ញុំាងសិស្សទ. ឱ្យសិក្សា ។

៩_ទ្វារទ. គឺឪពុក ញុំាងកូន ឱ្យបិទ ។

១០_ចីវរទ. គឺព្រះឧបជ្ឈាយ៍ ញុំាងភិក្ខុ ឱ្យកាន់យក ។

## កាល ៣ យ៉ាង

**១-បច្ចុប្បន្នកាល** : ពេលដែលកំពុងមាននៅចំពោះមុខ គឺពេល ឥឡូវនេះ ចែកចេញជា ៣ យ៉ាងគឺ : **សុទ្ធប្បច្ចុប្បន្ន ១ អតីតប្បច្ចុប្បន្ន ១ អនាគតប្បច្ចុប្បន្ន ១ ៗ**

**២-អតីតកាល** : ពេលដែលកន្លងហួសទៅហើយ ចែកចេញជា ៣ យ៉ាងគឺ : **អប្បច្ចក្ខាតីតកាល ១ ហីយោបត្តត្យាតីតកាល ១ អជ្ជប្បត្តត្យាតីតកាល ១ ៗ**

**៣-អនាគតកាល** : ពេលដែលមិនទាន់មកដល់ គឺពេលដែលនៅខាងមុខ ចែកចេញជា ២ យ៉ាងគឺ : **បច្ចុប្បន្នាគត ១ អតីតានាគត ១ ៗ**

**អនុត្តកាល** : កាលដែលមិនប្រាប់ដំណើរថាជាបច្ចុប្បន្ន ឬ អតីតៈ ឬអនាគតឡើយ ចែកចេញជា ៤ យ៉ាងគឺ : **អាណត្តិ ១ អាសិដ្ឋ ១ អនុមតិ ១ បរិកប្ប ១ ៗ**

## វិធីសង្កេតកាល

គេអាចនឹងដឹងនូវកាលទាំងនោះបានក្នុងភាសាខ្មែរ តាមពាក្យប្រែរបស់ វិភត្តិ ក្នុងភាសាបាលី តាមវិភត្តិទាំង ៨ ពួក ដូច្នេះ ។

វត្តមានាវិភត្តិ ប្រាប់បច្ចុប្បន្នកាលទាំង ៣ យ៉ាងគឺ :

ក/ **សុទ្ធបច្ចុប្បន្ន** ឱ្យប្រែថា "កំពុង..." ឬប្រែទទេៗ ក៏បាន, ឧ. **ឥទានិ បន សោ កឹ ករោតិ** - ចុះឥឡូវនេះ គាត់ **កំពុងធ្វើ** អ្វី ។ **បញ្ញាយ បភា សព្វាហិ បភាហិ វិរោចតិ** = ពន្លឺនៃប្រាជ្ញា **រុងរឿង** ជាងពន្លឺទាំងឡាយ ទាំងអស់ ។

ខ/ **អតីតបច្ចុប្បន្ន** ឱ្យប្រែថា " ទើប..., ទើបនឹង..." ឬប្រែថា "…. ហើយ" ក៏បានខ្លះ ឧ. **កុតោ នុ ត្វំ អាគច្ឆសិ** ចុះឯង **ទើបមក** ពីណាហ្នឹង ។ **ឥទានេវ សោ អាគច្ឆតិ** គាត់ **ទើបមក** អម្បាញ់មិញនេះឯង ។ **តទា បុញ្ញំ ករោមិ ហំ** ក្នុងកាលនោះ ខ្ញុំ **ធ្វើហើយ** នូវបុណ្យ ។

គ/ **អនាគតបច្ចុប្បន្ន** ឱ្យប្រែថា "នឹង..., រមែង..., តែងតែ..." ឬ "គង់..., គង់តែ...," ឧ. **ឯវំ តយា កតេ បាបេ និរយំ នូន គច្ឆសិ** កាលបើអំពើបាប គឺឯងធ្វើយ៉ាងនេះហើយ ឯង **នឹងទៅ** នរក ពុំខានឡើយ ។ **អយតោ មលំ សមុដ្ឋាយ, តមេវ ខាទតិ** ព្រេះ កើតអំពើដែក **រមែងស៊ី** ដែកនោះវិញ ។

**យោ ពាលំ សេវតិ សោ វិនាសំ បាប្ុណាតិ** បុគ្គលណា សេពគប់ នូវជនពាល បុគ្គលនោះ **គង់ដល់** នូវសេចក្ដីវិនាស ។

**បញ្ចមីវិភត្តិ ប្រាប់អនុត្តកាល ២ យ៉ាង គឺ :**

**ក/ អាណត្តិ** ប្រាប់សេចក្ដីបង្គាប់ ឱ្យប្រែថា "ចូរ..., ចូរ... ចុះ" ឧ. **មម វចនេន ករោហិ** ឯង **ចូរធ្វើ** តាមពាក្យ អញ ។ **គច្ឆាហិ** ឯង **ចូរទៅចុះ** ។

**ខ/ អាសិដ្ឋ** ប្រាប់សេចក្ដីប្រាថ្នា, សេចក្ដីប៉ុនប៉ង ឱ្យប្រែថា "ចូរ..." ឬ "សូម..., សូមឱ្យ... ចុះ" ឧ. **សុខំ តេ ហោតុ** សេចក្ដីសុខ **ចូរមាន** ដល់អ្នក ។ **ភវតុ សព្វមង្គលំ** មង្គលទាំងពួង **ចូរមាន** ។ **ឯវំ ហោតុ សូមបាន** យ៉ាងនេះចុះ ។ **តំ មេ ខមថ សូម** ព្រះអង្គ អត់ នូវទោសនោះដល់ខ្ញុំ ។

**សត្តមីវិភត្តិ ប្រាប់អនុត្តកាល ២ យ៉ាង គឺ :**

**ក/ អនុមតិ** ប្រាប់សេចក្ដីយល់ឃើញ ឱ្យប្រែថា "គួរ..., គួរតែ..." ឧ. **ភជេថ មិត្តេ កល្យាណេ, ភជេថ បុរិសុត្តមេ** បុគ្គល **គួរគប់រក** នូវកល្យាណមិត្ត **គួរគប់រក** នូវបុរសឧត្តមទ. ។

ខ/ **បរិកប្ប** ប្រាប់សេចក្តីកំណត់ ឱ្យប្រែថា "គប្បី..., ត្រូវ..."

ឧ. **បុញ្ញញ្ចេ បុរិសោ កយិរា, កយិរាថេនំ បុនប្បុនំ,**

**តម្ហិ ឆន្ទំ កយិរាថ, សុខោ បុញ្ញស្ស ឧច្ចយោ ។**

បើបុរស **គប្បីធ្វើ** នូវបុណ្យ **គប្បីធ្វើ** នូវបុណ្យនុ៎ះរឿយៗ **គប្បីធ្វើ** នូវសេចក្តីពេញចិត្តក្នុងបុណ្យនោះ ( ព្រោះ )ការសន្សំបុណ្យ **នាំមក** នូវសេចក្តីសុខ ។

ប្រាប់សេចក្តីសញ្ជឹង, សេចក្តីត្រិះរិះ ឱ្យប្រែថា "គប្បី..., ត្រូវ..."

ឧ. **កឹ បនាហំ ករេយ្យំ** ចុះអាត្មាអញ **ត្រូវធ្វើ** ដូចម្តេច ។

**បរោក្ខាវិភត្តិ** ប្រាប់អប្បច្ចក្ខាតីតកាល ឱ្យប្រែថា "ហើយ..."

ឧ. **តេនាហ ភគវា** ព្រោះហេតុនោះ ព្រះមានព្រះភាគ **ត្រាស់ហើយ** ។

**ហិយ្យត្តនីវិភត្តិ** ប្រាប់ហីយោបភូត្យាតីតកាល ឱ្យប្រែថា "ហើយ..." ឧ. **សោ អគមា** គេ **បានទៅហើយ** ។ បើមាន **មា** សព្ទ យោគចូលផង ឱ្យប្រែថា "កុំ... ឡើយ" ឧ. **ខណោ មា វោ ឧបច្ចគា** ខណៈ **កុំកន្លង** នូវអ្នកទ. **ឡើយ** ។

**អជ្ជត្តនីវិភត្តិ** ប្រាប់អជ្ជប្បភូត្យាតីតកាល ឱ្យប្រែថា "ហើយ..." ឧ. ថេរោ **អាគមិ** ព្រះថេរៈ **មកហើយ** ។

**ភវិស្សន្តិវិភត្តិ** ប្រាប់បច្ចុប្បន្នាគត ឱ្យប្រែថា "នឹង...," ឧ. សោ **គច្ឆិស្សតិ** គេ **នឹងទៅ** ។

**កាលាតិបត្តិវិភត្តិ** ប្រាប់អតីតានាគត ឱ្យប្រែថា "នឹង... ហើយ" បើមាន អ អាគម នៅខាងដើម ឱ្យប្រែថា "នឹងបាន... ហើយ" ឧ. សោ ចេ យានំ **លភិស្សា អគច្ឆិស្សា** បើគេ **នឹងបានហើយ** នូវយាន គេ **នឹងបានទៅហើយ** ។

## បទ

វិភត្តិមួយពួកៗ ចែកចេញជា ២ បទ គឺ :

**១_បរស្សបទ** សម្រាប់សំគាល់ កត្តុវាចកៈ និង ហេតុកត្តុវាចកៈ ។

**២_អត្តនោបទ** សម្រាប់សំគាល់ កម្មវាចកៈ ភាវវាចកៈ និង ហេតុកម្មវាចកៈ ។ ជួនណា បរស្សបទ ប្រើជាកម្មវាចកៈ ឬ ភាវវាចកៈ វិញក៏មាន ឧ. **តស្មា ឯសោ ន ទុច្ចតិ, ន ច លព្ភតិ រូបេ** ព្រោះហេតុនោះ ខ្លួនន៎ុះ ( គឺព្រះមានព្រះភាគ ) មិនពោល ; ម្យ៉ាងទៀត ( អំណាច គឺបុគ្គល ) មិនបានក្នុងរូប ។ អត្តនោបទ ប្រើជាកត្តុវាចកៈ

វិញក៏មាន ឧ. **បេមតោ ជាយតេ សោកោ** សេចក្ដីសោកកើតឡើង ព្រោះ សេចក្ដីស្រឡាញ់ ។

## វចនៈ

វិភត្តិទាំងនោះ មានវចនៈ ២ គឺ ឯកវចនៈ ១ ពហុវចនៈ ១ ។ កិរិយាសព្ទ និងបទប្រធាន ត្រូវមានវចនៈស្មើគ្នា ; ឧ. **សោ គាមំ គច្ឆតិ** គេទៅ កាន់ស្រុក ។ **តេ គាមំ គច្ឆន្តិ** គេទ. ទៅ កាន់ស្រុក ។ វៀរលែងតែបទប្រធានជាឯកវចនៈច្រើនៗ បទ រួមចូល ដោយនិបាត សព្ទ មាន " ច " ជាដើមនេះ កិរិយាត្រូវជា ពហុវចនៈ បាន ឧ. **សេដ្ឋី ច សេដ្ឋិជាយា ច** រាជានំ **ឧបសង្កមឹសុ សេដ្ឋី និង ប្រពន្ធសេដ្ឋី ចូលទៅរក** ព្រះរាជា ។

## បុរិស

វិភត្តិអាខ្យាត ចាត់ជាបុរិសៈ មាន ៣ គឺ : បឋមបុរិសៈ ១ មជ្ឈិមបុរិសៈ ១ ឧត្តមបុរិសៈ ១ ។ ត្រូវប្រើកិរិយាសព្ទប្រកបវិភត្តិ ឱ្យ ត្រូវគ្នានឹងបុរិសសព្វនាម ឧ. **សោ យាតិ, ត្វំ យាសិ, អហំ យាមិ** គេទៅ, ឯងទៅ, ខ្ញុំទៅ ។

# ធាតុ

វិភត្តិប្រកបដោយ កាល, បទ, វចនៈ, បុរិសៈ ប៉ុណ្ណោះ ត្រូវផ្សំជាមួយធាតុ ឱ្យចេញប្រាកដមកជាកិរិយារបស់នាម ។

ធាតុនោះនិយាយដោយសង្ខេប ចែកជាធាតុគណៈ មាន ៨ ពួក តាមដំណើរដែលចុះបច្ច័យត្រូវគ្នា ដូច្នេះ :

១_ពួក **ភូ**_ធាតុ ចុះ **អ**_បច្ច័យ : **ភូ** "កើត, មាន, ជា" **ហុ** ឬ **ហូ** "កើត, មាន, ជា", **សី** "ដេក", **ខន** "ជីក", **វទ** "ពោល, ស្តី, និយាយ", **បច** "ចំអិន...", **ឥក្ខ** "ឃើញ", **មរ** "ស្លាប់", **លភ** "បាន", **គម** "ទៅ, ដល់" , **គុប** "គ្រប់គ្រង, រក្សា" ។

២_ពួក **រុធ**_ធាតុ ចុះ **អ**, **ឥ**, **ឦ**, **ឯ**, **ឱ** បច្ច័យ និងនិគ្គហិតអាគមផង : **រុធ** "បិទ, រាំង, ខ្ទប់", **មុច** "រួច, លែង, រដោះ", **ភុជ** "ស៊ី", **ឆិទ** "កាត់", **ភិទ** "បែក, ធ្លាយ", **លិប** "លាប, បូក" ។

៣_ពួក **ទិវ**_ធាតុ ចុះ **យ**_បច្ច័យ : **ទិវ** "លេង", **សិវ** "ដេរ", **ខី** "អស់" , **មុហ** "ភ្លេច, វង្វេង, ភាន់", **រជ** "ជ្រលក់" , **មុស** "ភ្លេច", **ពុធ** "ដឹង, ត្រាស់ដឹង", **យុធ** "ច្បាំង" ។

៤_ពួក **សុ**_ធាតុ ចុះ **ណុ**, **ណា**, **ឧណា**_បច្ច័យ : **សុ** "ឮ, ស្តាប់", **វុ** "ក្រង", **អាប** "ជ្រួតជ្រាប, ហូរទៅ", **ប** + **អាប** "ដល់,

ទាន់, លុះ", **សិ** "ចង" ។

៥_ពួក **កី**_ធាតុ ចុះ **នា**_បច្ច័យ : **កី** "ទិញ", **ចិ** "សន្សំ, បេះ", **ជិ** "ឈ្នះ, ផ្ចាញ់", **ញា** "ដឹង, ស្គាល់", **ធុ** "កំចាត់, កំចាត់បង់", **ផុ** "អុំ, ស្ទែ", **លុ** "កាត់" ។

៦_ពួក **គហ**_ធាតុ ចុះ **ប្ប, ណ្ហា**_បច្ច័យ : **គហ** "កាន់, ចាប់, យក..." ។

៧_ពួក **តន**_ធាតុ ចុះ **ឱ, យិរ**_បច្ច័យ : **តន** "ផ្សាយចេញ, ត្រដាង, លាត, លា", **ករ** "ធ្វើ", **ជាគរ** "ភ្ញាក់, រលឹក", **សក** "អាច, ហ៊ាន" ។

៨_ពួក **ចុរ**_ធាតុ ចុះ **ណេ, ណយ**_បច្ច័យ : **ចុរ** "លួច", **ចិន្ត** "គិត", **តក្ក** "ត្រិះរិះ", **មន្ត** "ប្រឹក្សា, ពិភាក្សា, ជជែក", **លក្ខ** "កំណត់" ។

ធាតុទាំង ៨ ពួកនោះ បំប្រួញឱ្យខ្លីមកនៅត្រឹមតែ ២ ពួក គឺ :

**១_សកម្មធាតុ** ធាតុប្រកបដោយកម្ម គឺអំពើដែលគេត្រូវធ្វើ ឧ. **ឱទនំ បចតិ** គេចំអិន នូវបាយ ។

**២_អកម្មធាតុ** ធាតុដែលមិនប្រកបដោយកម្ម ឧ. **មញ្ចេ សយតិ** គេ ដេក លើគ្រែ ។

## វាចក:

កិរិយាសព្ទ ចែកចេញជាវាចក: មាន ៥ យ៉ាង គឺ

**១~កត្តុវាចក:** កិរិយាសព្ទប្រាប់កត្តា គឺប្រាប់ថាជាកិរិយារបស់អ្នកធ្វើ ឧ. **សូទោ ឱទនំ បចតិ** អ្នកគ្រូ ចំអិន នូវបាយ ។

**២~កម្មវាចក:** កិរិយាសព្ទប្រាប់កម្ម គឺប្រាប់ថាជាកិរិយារបស់អំពើដែលគេត្រូវធ្វើ ឧ. **សូទេន ឱទនោ បចិយតេ** បាយ គឺអ្នកគ្រូចំអិន ។

**៣~ភាវវាចក:** កិរិយាសព្ទប្រាប់ភាព គឺមិនប្រាប់កត្តា ឬកម្មឡើយ ឧ. **តេន ភូយតេ** គឺគេ កើត ។

**៤~ហេតុកត្តុវាចក:** កិរិយាសព្ទប្រាប់កត្តាដែលជាហេតុ គឺប្រាប់ថា ជាកិរិយារបស់អ្នកប្រើឱ្យជនដទៃធ្វើ ឧ. **សេដ្ឋី សូទំ ឱទនំ បាចេតិ** សេដ្ឋីញ៉ាំងអ្នកគ្រូ ឱ្យចំអិន នូវបាយ ។

**៥~ហេតុកម្មវាចក:** កិរិយាសព្ទប្រាប់កម្មដែលជាហេតុ គឺប្រាប់ ថាជាកិរិយារបស់អំពើ ដែលគេប្រើឱ្យបុគ្គលដទៃធ្វើ ឧ. **សេដ្ឋិនា សូទេន ឱទនោ បាចាបិយតេ** បាយ គឺសេដ្ឋី ញ៉ាំងអ្នកគ្រូឱ្យចំអិន ។

# បច្ច័យ

គេអាចនឹងយល់វាចកៈទាំង ៥ នោះបាន ដោយអាស្រ័យបច្ច័យជាគ្រឿងចំណាំ ។ បច្ច័យក្នុងអាខ្យាតមាន ២៥ តួ គឺ : **អ**, **ឥ**, **ឦ**, **ឯ**, **យ**, **ណុ**, **ណា**, **ឧណា**, **នា**, **ប្ប**, **ណ្ហា**, **ឱ**, **យិរ**, **ណេ**, **ណយ**, **ណាបេ**, **ណាបយ**, **ខ**, **ឆ**, **ស**, **អាយ**, **ឦយ**, **អល**, **អារ**, **អាល** ។

បច្ច័យ សម្រាប់ចុះក្នុងកត្តុវាចកៈ មាន ១៥ តាមពួកធាតុទាំង ៨ រួចហើយ ។

បច្ច័យ សម្រាប់ចុះក្នុងកម្មវាចកៈ មាន ១ គឺ **យ** ។ កម្មវាចកៈច្រើនតែចុះ **ឥ**_អាគមផ្សំផង ។

បច្ច័យ សម្រាប់ចុះក្នុងភាវវាចកៈ មាន ១ គឺ **យ** ។

បច្ច័យ សម្រាប់ចុះក្នុងហេតុកត្តុវាចកៈ មាន ៤ គឺ : **ណេ**, **ណយ**, **ណាបេ**, **ណាបយ** ។

ក្នុងហេតុកម្មវាចកៈ ចុះបច្ច័យតាមពួកធាតុផងក៏មាន មិនបាច់ចុះក៏មាន ចុះការិតប្បច្ច័យផង ចុះ **ឥ**_អាគមផង ចុះ **យ**_បច្ច័យផង ឧ. **ឃាតាបិយតេ** ។

# ១) កត្តុវាចកៈ ធាតុផ្សំនឹងបច្ច័យទាំង ៨ ពួក ដូច្នេះ

## ១_ពួក ភូ_ធាតុ ចុះ អ_បច្ច័យ

| | |
|---|---|
| ភូ + អ > ភវ | បច + អ > បច |
| ហុ + អ > ហោ | ឥក្ខ + អ > ឥក្ខ |
| សី + អ > សេ, សយ | លភ + អ > លភ |
| មរ + អ > មរ | គម + អ > គច្ឆ, គម |

## ២_ពួក រុធ_ធាតុ ចុះ អ, ឯ_បច្ច័យ

| | |
|---|---|
| រុធ + អ, ឯ > រុន្ធ, រុន្ធេ | ភិទ + អ, ឯ > ភិន្ទ, ភិន្ទេ |
| មុច + អ, ឯ > មុញ្ច, មុញ្ចេ | លិប + អ, ឯ > លិម្ប, លិម្បេ |
| ភុជ + អ, ឯ > ភុញ្ជ, ភុញ្ជេ | |

## ៣_ពួក ទិវ_ធាតុ ចុះ យ_បច្ច័យ

| | |
|---|---|
| ទិវ + យ > ទិព្វ | មុហ + យ > មុយ្ហ |
| សិវ + យ > សិព្វ | មុស + យ > មុស្ស |
| ពុធ + យ > ពុជ្ឈ | នជ + យ > នជ្ជ |

## ៤_ពួក សុ_ធាតុ ចុះ ណុ, ណា, ឧណា_បច្ច័យ

សុ + ណា > សុណា, សុណ

សុ + ណុ > សុណោ

សិ + ណុ > សិណោ

ធុ + ណា > ធុណា, ធុណ

ប + អប + ឧណា > បាបុណា, បាបុណ (ផ្លាស់ ឧ > ឱ)

## ៥_ពួក កី_ធាតុ ចុះ នា_បច្ច័យ

| | |
|---|---|
| កី + នា > កីនា, កីន | លុ + នា > លុនា, លុន |
| ជិ + នា > ជិនា, ជិន | ញា + នា > ជានា, ជាន |
| ធុ + នា > ធុនា, ធុន | ផុ + នា > ផុនា, ផុន |
| ចិ + នា > ចិនា, ចិន | |

## ៦_ពួក គហ_ធាតុ ចុះ ណ្ហា_បច្ច័យ

គហ + ណ្ហា = គណ្ហា, គណ្ហ

## ៧_ពួក តន_ធាតុ ចុះ ឱ, យិរ_បច្ច័យ

តន + ឱ > តនោ, តន ( លុប ឱ )

ករ + ឱ > ករោ, ករ ( លុប ឱ )

សក្ក + ឱ > សក្កោ, សក្ក ( លុប ឱ )

ជាគរ + ឱ > ជាគរោ, ជាគរ ( លុប ឱ )

ករ + យិរ > កយិរ ( លុប រ នៃ ករ )

៨_ពួក ចុរ_ធាតុ ចុះ ណេ, ណយ_បច្ច័យ

ចុរ + ណេ, ណយ > ចោរេ, ចោរយ

តក្ក + ណេ, ណយ > តក្កេ, តក្កយ

លក្ខ + ណេ, ណយ > លក្ខេ, លក្ខយ

មន្ត + ណេ, ណយ > មន្តេ, មន្តយ

ចិន្ត + ណេ, ណយ > ចិន្តេ, ចិន្តយ

២) **កម្មវាចកៈ សកម្មធាតុ** ចុះ **យ**_បច្ច័យ **ឥ**_អាគមផង ក៏មាន បំបែកតែវត្តមានវិភត្តិ បឋមបុរិសៈ ឱ្យឃើញជាបែប :

| ឯក. | ពហុ. | ឯក. | ពហុ. |
|---|---|---|---|
| បចិយតេ, បច្ចតេ | បចិយន្តេ, បច្ចន្តេ | ករីយតេ | ករីយន្តេ |
| លភិយតេ, លព្ភតេ | លភិយន្តេ, លព្ភន្តេ | គហិយតេ | គហិយន្តេ |

| | | | |
|---|---|---|---|
| **រុន្ធិយតេ** | **រុន្ធិយន្តេ** | **ករិយតេ,** | **ករិយន្តេ** |
| **ភិន្ទិយតេ** | **ភិន្ទិយន្តេ** | ( **កយ្យតេ** ) | ( **កយ្យន្តេ** ) |
| **សិវិយតេ, សិព្វតេ** | **សិវិយន្តេ, សិព្វន្តេ** | **ចុរិយតេ** | **ចុរិយន្តេ** |
| **យុជ្ជតេ** | **យុជ្ជន្តេ** | **ចិន្តិយតេ** | **ចិន្តិយន្តេ** |

៣) **ភាវវាចកៈ អកម្មធាតុ** ចុះ **យ**_បច្ច័យ ប្រើតែវត្តមានាវិភត្តិ បឋមបុរិសៈ ឯកវចកៈ គឺ :

**ភូយតេ, សយតេ, សុបយតេ, មរយតេ, មុញ្ចយតេ, មុច្ចតេ, ខិយតេ, មុយ្ហតេ, មុស្សតេ, សុយ្យតេ, ជិយតេ, ជាគរយតេ, ចិន្តយតេ** ។

៤) **ហេតុកត្តុវាចកៈ** ចុះ **ណេ, ណយ, ណាបេ, ណាបយ**_បច្ច័យ ឱ្យលុប **ណ** ទុកតែ **ឯ, អយ, អាបេ, អាបយ,** ហើយព្រឹទ្ធិស្រៈ ដើមធាតុដែលមិនមាន ព្យញ្ជនៈតម្រួតគ្នានៅខាងចុង រួចប្រកបនឹង វិភត្តិ តាមការគួរ :

**១_ភូ : ភាវេ, ភាវយ, ភាវាបេ, ភាវាបយ ។**

**បច : បាចេ, បាចយ, បាចាបេ, បាចាបយ ។**

**ឥក្ខ : ឥក្ខេ, ឥក្ខយ, ឥក្ខាបេ, ឥក្ខាបយ ។**

**២_រុធ : រោធេ, រោធយ, រុន្ធាបេ, រុន្ធាបយ ។**

ភិទ : ភេទេ, ភេទយ, ភេទាបេ, ភេទាបយ ។

៣.សិវ : សិព្វេ, សិព្វយ, សិព្វាបេ, សិព្វាបយ ។

មុហ + យ > មុយ្ហាបេ, មុយ្ហាបយ ។

៤.សុ + ណា > សុណាបេ, សុណាបយ ។

៥.កី + នា > កីណាបេ, កីណាបយ ។

ញា + នា > ជានាបេ, ជានាបយ ។

៦.គហ + ណ្ហា > គណ្ហាបេ, គណ្ហាបយ ។

៧.តន + ឱ (លុប ឱ ចេញ) > តានាបេ, តានាបយ ។

៨.ចុរ : ចោរេ, ចោរយ, ចោរាបេ, ចោរាបយ ។

មរ : មារេ, មារយ, មារាបេ, មារាបយ ។

លភ : លាភេ, លាភយ, លាភាបេ, លាភាបយ ។

មុច : មុញ្ចេ, មុញ្ចយ, មោចាបេ, មោចាបយ ។

ភុជ : ភោជេ, ភោជយ, ភោជាបេ, ភោជាបយ ។

ទុ + ណា > ទុណាបេ, ទុណាបយ ។

ជិ + នា > ជិនាបេ, ជិនាបយ ។

ចិ + នា > ចិនាបេ, ចិនាបយ ។

គហ : គាហាបេ, គាហាបយ ។

ភរ : ភារេ, ភារយ, ភារាបេ, ភារាបយ ។

ចិន្ត : ចិន្តេ, ចិន្តយ, ចិន្តាបេ, ចិន្តាបយ ។

៥) ហេតុកម្មវាចកៈ ចុះ ណាបេ + ឥ + យ = អាបិយ, ចុះ បច្ច័យ ពួកធាតុក៏មានខ្លះ ច្រើនប្រើវត្តមានវិភត្តិ បឋមបុរិសៈ ទាំង ២ វចនៈ

ភូ : ភាវាបិយតេ ។
លភ : លាភាបិយតេ ។
គម : គច្ឆាបិយតេ ។
រុធ : រុន្ធាបិយតេ ។
មុច : មុញ្ចាបិយតេ ។
ភុជ : ភុញ្ជាបិយតេ ។
ភិទ : ភិន្ទាបិយតេ ឬ ភេទាបិយតេ ។

ឆិទ : ឆិញ្ញបិយតេ ។
ពុធ : ពុជ្ឈាបិយតេ ។
កី : កីណាបិយតេ ។
ញា : ជានាបិយតេ ។
គហ : គណ្ហាបិយតេ ។
តន : តានាបិយតេ ។
ចុរ : ចោរាបិយតេ ។

## វិធីតែងវាចកៈអាខ្យាត

ការតែងវាចកៈទាំង ៥ ត្រូវស្គាល់សកម្មធាតុ និងអកម្មធាតុ ហើយប្រៀបធៀបវាចកៈ ដែលជាគូៗ គ្នា ដូចខាងក្រោមនេះ :

## សកម្មធាតុ និង អកម្មធាតុ

១_កត្តុវាចក: សកម្មធាតុ : **សិស្សោ ធម្មំ សិក្ខតិ ។**

_កត្តុវាចក: អកម្មធាតុ : **ជនោ មរតិ ។**

២_កម្មវាចក: សកម្មធាតុ : **សិស្សេន ធម្មោ សិក្ខិយតេ ។**

៣_ហេតុកត្តុវាចក: សកម្មធាតុ : **អាចរិយោ សិស្សំ ធម្មំ សិក្ខាបេន្តិ ។**

_ហេតុកត្តុវាចក: អកម្មធាតុ : **ជនោ ហត្ថី មារាបេតិ ។**

៤_ហេតុកម្មវាចក: សកម្មធាតុ : **អាចរិយេន សិស្សំ ធម្មោ សិក្ខាបិយតេ ។**

_ហេតុកម្មវាចក: អកម្មធាតុ : **ជនេន ហត្ថី មារាបិយតេ ។**

៥_ភាវវាចក: អកម្មធាតុ : **ជនេន មរយតេ ។**

## កត្តុវាចក: ជាគូនឹង កម្មវាចក:

| ភាសាខ្មែរ | ភាសាបាលី |
|---|---|
| សាមណេរ តែងបិទ នូវទ្វារ។ | ~សាមណេរោ ទ្វារំ ថុន្ធតិ (កត្តុ.) ។ |
| ទ្វារ ដែលសាមណេរ តែងបិទ ។ | ~សាមណេរេន ទ្វារំ ថុន្ធិយតេ (កម្ម.)។ |
| កញ្ញា កំពុងដេរ នូវសំពត់ទ. ។ | ~កញ្ញា វត្ថានិ សិព្វតិ (កត្តុ.) ។ |
| សំពត់ទ. គឺកញ្ញា កំពុងដេរ ។ | ~កញ្ញាយ វត្ថានិ សិវិយន្តេ (កម្ម.)។ |
| អ្នកប្រាជ្ញទ. រមែងសំដែង ធម៌។ | ~មុនយោ ធម្មំ ភាថេន្តិ (កត្តុ.)។ |
| ធម៌ ដែលអ្នកប្រាជ្ញទ. រមែងសំដែង។ | ~មុនីហិ ធម្មោ ភាថិយតេ (កម្ម.)។ |

| | |
|---|---|
| មនុស្សទ. តែងចេះ ភាសា ។ | ~មនុស្សា ភាសំ ជានន្តិ ( កត្តុ. )។ |
| ភាសា គឺមនុស្សទ. តែងចេះ ។ | ~មនុស្សេហិ ភាសា ញាយតេ (កម្ម.)។ |
| ភិក្ខុ កំពុងគិត ធម៌ទ. ។ | ~ភិក្ខុ ធម្មេ ចិន្តេតិ ( កត្តុ. )។ |
| ធម៌ទ. គឺភិក្ខុ កំពុងគិត ។ | ~ភិក្ខុនា ធម្មា ចិន្តិយន្តេ ( កម្ម. ) ។ |

## ហេតុកត្តុវាចកៈ ជាគូនឹង ហេតុកម្មវាចកៈ

| ភាសាខ្មែរ | ភាសាបាលី |
|---|---|
| សេដ្ឋី ញ៉ាំងអ្នកគ្រួ ឱ្យចំអិន បាយ ។ | ~សេដ្ឋី សូទំ ឱទនំ បាចេតិ (ហេតុកត្តុ.)។ |
| បាយ ដែលសេដ្ឋី ញ៉ាំងអ្នកគ្រួ ឱ្យចំអិន ។ | ~សេដ្ឋិនា សូទំ ឱទនោ បាចាបិយតេ ( ហេតុកម្ម. ) ។ |
| បិតា ញ៉ាំងកូន ឱ្យបិទទ្វារ ។ | ~បិតា បុត្តំ ទ្វារំ រុន្ធាបេតិ (ហេតុកត្តុ.)។ |
| ទ្វារ គឺបិតា ញ៉ាំងកូន ឱ្យបិទ។ | ~បិតរា បុត្តំ ទ្វារំ រុន្ធាបិយតេ (ហេតុកម្ម.)។ |
| ភិក្ខុ ញ៉ាំងទាយក ឱ្យកាន់យក បាត្រទ. ។ | ~ភិក្ខុ ទាយកំ បត្តេ គណ្ហាបេតិ ( ហេតុកត្តុ. ) ។ |
| បាត្រទ. គឺភិក្ខុ ញ៉ាំងទាយក ឱ្យកាន់យក ។ | ~ភិក្ខុនា ទាយកំ បត្តា គណ្ហាបិយន្តេ ( ហេតុកម្ម. ) ។ |
| ព្រះថេរៈ ញ៉ាំងភិក្ខុទ. ឱ្យប្រឹក្សា ធម៌ទ. ។ | ~ថេរោ ភិក្ខូ ធម្មេ មន្តាបេតិ ( ហេតុកត្តុ. ) ។ |

ធម៌ទ. ដែលព្រះថេរៈ ញ៉ាំង- ~ថេរេន ភិក្ខូ ធម្មំ មន្តាបិយន្តេ

ភិក្ខុទ. ឱ្យប្រឹក្សា ។ ( ហេតុកម្ម. ) ។

## ៣~កិរិយាកិតកៈ

**កិតកៈ** ដែលជាកិរិយា ហៅថា កិរិយាកិតកៈ ឬ កិតកិរិយា ឬ ហៅថា កិរិយាគុណ ត្រូវប្រកបដោយ វិភត្តិ, វចនៈ, កាល, ធាតុ, វាចកៈ និងបច្ច័យ ។

## វិភត្តិ និង វចនៈ

វិភត្តិនៃកិរិយាកិតកៈ ត្រូវប្រកបដោយវិភត្តិនាម បើនាមសព្ទប្រកបដោយវិភត្តិណា វចនៈណា កិរិយាកិតកៈ ក៏ត្រូវប្រកបវិភត្តិនោះ វចនៈនោះ, ទាំងលិង្គ ក៏ត្រូវប្រកបឱ្យស្មើគ្នា ឧ. បុំ. ឯក. **ភិក្ខុ ធម្មេ រតោ** "ភិក្ខុ ត្រេកអរហើយ ក្នុងធម៌" ។ បុំ. ពហុ. **ភិក្ខូ ធម្មេ រតា** "ភិក្ខុទ. ត្រេកអរហើយ ក្នុងធម៌", ឥ. ឯក. **ភិក្ខុនី ធម្មេ រតា** "ភិក្ខុនី ត្រេកអរ-ហើយ ក្នុងធម៌", នបុំ. ឯក. **ចិត្តំ ធម្មេ រតំ** "ចិត្ត ត្រេកអរហើយ ក្នុងធម៌", នបុំ. ពហុ. **ចិត្តានិ ធម្មេ រតានិ** "ចិត្តទ. ត្រេកអរហើយ ក្នុងធម៌" ។

## កាល

កាលក្នុងកិរិយាកិតកៈ មាន ២ យ៉ាងគឺ : បច្ចុប្បន្នកាល ១, អតីតកាល ១, បើរាប់អនុត្តកាលចូលផង ជា ៣ យ៉ាង ។

## បច្ចុប្បន្នកាល ចែកចេញជា ២ យ៉ាងគឺ :

១) **បច្ចុប្បន្នសុទ្ធ** ឱ្យប្រែថា "កំពុងតែ..." ឬ គ្រាន់តែប្រែចេញសព្ទ របស់ធាតុក៏បាន ។ ឧទាហរណ៍ :

**ឧបាសកោ ធម្មំ សុណន្តោ សទ្ធំ ជនេតិ** "ឧបាសក កំពុងស្តាប់ នូវធម៌ ញ៉ាំងសទ្ធា ឱ្យកើត" ។

**ឧបាសិកា ធម្មំ សុណន្តី សទ្ធំ ជនេតិ** "ឧបាសិកា កំពុងស្តាប់ នូវធម៌ ញ៉ាំងសទ្ធា ឱ្យកើត" ។

**កុលំ ធម្មំ សុណន្តំ សទ្ធំ ជនេតិ** "ត្រកូល កំពុងស្តាប់ នូវធម៌ ញ៉ាំងសទ្ធា ឱ្យកើត" ។

២) **បច្ចុប្បន្នជិតអនាគត** ឱ្យប្រែថា "កាល... កាលនឹង..."

ឧ. **ពុទ្ធោ ច នាម ធម្មំ ទេសេន្តោ សត្តានំ ឧបនិស្សយំ ឱលោកេត្វា ទេសេតិ** "ក៏ធម្មតា ព្រះពុទ្ធទ. កាលសំដែងនូវធម៌ (តែងតែ) ប្រមើលមើលនូវឧបនិស្ស័យ នៃសត្វទ. ហើយសំដែង" ។

## អតីតកាល ចែកចេញជា ២ យ៉ាងគឺ :

១) **អតីតកាល** "គ្រាន់តែប្រាប់ថាកន្លងហើយ" ឱ្យប្រែថា "... ហើយ" ឬថា "... រួចហើយ" ក៏បាន ឧ. **តយោ មាសា អតិក្កន្តា** " ខែទ. ៣ កន្លងហើយ" ។

២) **អតីតកាល** "កន្លងស្រេចហើយ" ឱ្យប្រែថា "លុះ... ហើយ" ឬថា "លុះ... រួចហើយ" ឧ. **អយំ កុលបុត្តោ មំ ទិស្វា មម សង្គហំ ករិស្សតិ កត្វា ច បន មហាសម្បត្តឹ លភិស្សតិ** "កុលបុត្តនេះ ឃើញនូវអញហើយ នឹងធ្វើ នូវសេចក្តីសង្គ្រោះ ដល់អញ, ក៏លុះធ្វើរួចហើយ នឹងបាននូវសម្បត្តិធំ" ។

## អនុត្តកាល ចែកចេញជា ២ យ៉ាងគឺ :

១) **អនុមតិ** "ប្រាប់សេចក្តីយល់ឃើញ" ឱ្យប្រែថា "គួរ..., គួរតែ..." ឧ. **ន ភេជេថ ពាលោ សេវិតព្វោ បណ្ឌិតោ បន សេវិតព្វោ** "បុគ្គលពាល គឺអ្នកណាមួយ មិនគួរសេពគប់ឡើយ ឯបុគ្គលជាបណ្ឌិត ( គឺជន ) គួរសេពគប់" ។

២) **បរិកប្ប** "ប្រាប់សេចក្តីកំណត់" ឱ្យប្រែថា "គប្បី..." ឬ "ត្រូវ..." ឧ. **រាជកិច្ចំ តេ កត្តព្វំ** "កិច្ចរបស់ស្តេច គឺអ្នកគប្បីធ្វើ" ។ "ប្រាប់សេចក្តីជញ្ជឹង, សេចក្តីត្រិះរិះ" ឱ្យប្រែថា "គប្បី..." ឬ "ត្រូវ..." ឧ. **កិន្នុខោ បនេតំ មយា កាតព្វំ** "ចុះ ( កិច្ច ) ហ្នឹង គឺអញ ត្រូវធ្វើដូចម្តេចហ្ន៎ ? " ។

## ធាតុ និង វាចកៈ

ធាតុក្នុងកិតកៈនេះ ក៏ដូចគ្នានឹងធាតុក្នុងអាខ្យាតដែរ ដូចតទៅនេះ :

- **បច្ចុប្បន្ន** : អាខ្យាត - **លភតិ**,

កិតកៈ បុំ. **លភន្តោ**, ឥ. **លភន្តី**, នបុំ. **លភន្តំ** ។

- **អតីតកាល** : អាខ្យាត : **លភិ**,

កិតកៈ បុំ. **លទ្ធោ**, ឥ. **លទ្ធា**, នបុំ. **លទ្ធំ** ។

- **អនាគតកាល** : អាខ្យាត - **លភេយ្យ**,

កិតកៈ បុំ. **លភិតព្វោ** ឬ **លទ្ធព្វោ**, ឥ. **លភិតព្វា** ឬ **លទ្ធព្វា**, នបុំ. **លភិតព្វំ** ឬ **លទ្ធព្វំ** ។

### វាចកៈ មាន ៥ យ៉ាងគឺ :

១) កត្តុវាចកៈ **ពុទ្ធស្ស សាវកោ ធម្មំ ទេសេន្តោ** "សាវ័កនៃព្រះពុទ្ធ កាលសំដែង នូវធម៌" ។

២) កម្មវាចកៈ **ពុទ្ធស្ស សាវកេន ធម្មោ ទេសិតោ** "ធម៌គឺសាវ័ក នៃព្រះពុទ្ធ សំដែងហើយ" ។

៣) ភាវវាចកៈ **សត្តេហិ មរិតព្វំ** "គឺសត្វទាំងឡាយ គប្បីស្លាប់" ។

៤) ហេតុកត្តុវាចកៈ **ពុទ្ធោ សាវកំ ធម្មំ ភាសាបេន្តោ** "ព្រះពុទ្ធញ៉ាំងសាវ័ក ឱ្យសំដែង នូវធម៌" ។

៥) ហេតុកម្មវាចកៈ **ពុទ្ធេន សាវកំ ធម្មោ កថាបេតព្វោ** “ធម៌ គឺព្រះពុទ្ធ ញុំាងសាវ័ក ឱ្យសំដែង” ។

## បច្ច័យនៃកិរិយាកិតកៈ

បច្ច័យសម្រាប់ចុះប្រកបនឹងកិរិយាកិតកៈនោះ ចែកជា ៣ ពួកគឺ :

១) **កិតប្បច្ច័យ** មាន ៣ គឺ : **អន្ត, តវន្តុ, តាវី**, សម្រាប់សំគាល់ កត្តុវាចកៈ, ហេតុកត្តុវាចកៈ ។

២) **កិច្ចប្បច្ច័យ** មាន ២ គឺ : **តព្វ, អនីយ**, សម្រាប់សំគាល់ កម្មវាចកៈ, ភាវវាចកៈ, ហេតុកម្មវាចកៈ ។

៣) **កិតកិច្ចប្បច្ច័យ** មាន ៥ គឺ : **មាន, ត, ត្វា, ត្វាន, តូន**, សម្រាប់ សំគាល់វាចកៈទាំង ៥ ។

**អន្ត, មាន** ពីរនេះ ប្រាប់បច្ចុប្បន្នកាល ។

**តព្វ, អនីយ** ពីរនេះ ប្រាប់អនុត្តកាល ។

**ត** មួយនេះ ច្រើនតែប្រាប់អតីតកាល, ខាងអនាគតកាលក៏ប្រើ តែមានតិចណាស់ ។

**តវន្តុ, តាវី, ត្វា, ត្វាន, តូន** ប្រាំនេះ ប្រាប់អតីតកាលដោយ ច្រើនជាងកាលឯទៀត ។

# ឧទាហរណ៍ក្នុងកិតប្បច្ច័យ

**អន្ត**-បច្ច័យ ចុះបានតែវាចកៈ ២ គឺ កត្តុវាចកៈ និងហេតុកត្តុ-វាចកៈ ។

-កត្តុវាចកៈ ចុះបច្ច័យសម្រាប់ពួកធាតុមកផងក៏បាន មិនបាច់ចុះក៏បាន, ឧទាហរណ៍ :

**កថ**-ធាតុ បុំ. **កថេន្តោ**, ឥ.**កថេន្តី**, នបុំ. **កថេន្តំ**, "កំពុងពោល" ។

**លភ**-ធាតុ បុំ. **លភំ** ឬ **លភន្តោ**, ឥ. **លភន្តី** ឬ **លភតី**, នបុំ. **លភន្តំ** "កំពុងបាន, កាលបាន" ។

ហេតុកត្តុវាចកៈ ចុះបច្ច័យសម្រាប់ពួកធាតុមកផងក៏បាន មិនចុះ ក៏បាន ប៉ុន្តែត្រូវចុះការិតប្បច្ច័យមកជាដំរាប , ឧទាហរណ៍ :

**កថ**-ធាតុ បុំ. **កថាបេន្តោ**, ឥ. **កថាបេន្តី**, នបុំ. **កថាបេន្តំ**, "កំពុង-ឱ្យពោល, កាលឱ្យពោល" ។

**លភ**-ធាតុ បុំ. **លាភាបយំ** ឬ **លាភាបយន្តោ**, ឥ. **លាភាបយន្តី** ឬ **លាភាបយតី**, នបុំ. **លាភាបយន្តំ** "កំពុងឱ្យបាន, កាលឱ្យបាន" ។

**អន្ត**-បច្ច័យ បុំ. បំបែកដូចបុរិស ឬ **ភវន្ត**, ឥ. ចុះ **ឦ**-បច្ច័យ បំបែក ដូច "**នារី**" នបុំ. បំបែកដូច "**កុល**" ។

**តវន្តុ**-បច្ច័យ ចុះបានក្នុងវាចកៈ ២ គឺ : កត្តុវាចកៈ និងហេតុ-កត្តុវាចកៈ។

កត្តុវាចកៈ - ធាតុទោលតែមួយតួ ត្រូវទុកធាតុឱ្យគង់រូបនៅដូច ដើម; ឧទាហរណ៍ :

**សុ** + **តវន្តុ** : បុំ. **សុតវា**, ឥ. **សុតវន្តី** ឬ **សុតវតី**, នបុំ. **សុតវន្តំ** "ឮហើយ, ស្តាប់ហើយ" ។

-ធាតុមានអក្សរ ២ តួ ដែលមាន **ច**, **ជ**, **ប** ជាទីបំផុត, ផ្លាស់ទីបំផុតធាតុជា **ត** ក៏បាន , ឧទាហរណ៍ :

**សិច** + **តវន្តុ** : បុំ. **សិត្តវា**, ឥ. **សិត្តវន្តី** ឬ **សិត្តវតី**, នបុំ. **សិត្តវន្តំ** "ស្រោចហើយ" ។

**ភុជ** + **តវន្តុ** : បុំ. **ភុត្តវា** "បរិភោគហើយ" ។

**គុប** + **តវន្តុ** : បុំ. **គុត្តវា** "គ្រប់គ្រងហើយ" ។

-បើមិនផ្លាស់ទីបំផុតធាតុទេ ត្រូវចុះ **ឥ**-អាគម មកផង

ឧ. **ចជ** + **តវន្តុ** : បុំ. **ចជិតវា** "លះបង់ហើយ" ។

-ចំពោះ **វស**-ធាតុមួយ ត្រូវផ្លាស់ **វ** ជា **វុ** ហើយចុះ **ឥ**-អាគម មកផង ឧទាហរណ៍ :

**វស** + **តវន្តុ** : បុំ. **វុសិតវា** "នៅហើយ" ។

ហេតុកត្តុវាចកៈ ត្រូវចុះការិតប្បច្ច័យ : **ណេ, ណយ, ណាបេ, ណាបយ** តាមគួរដល់ការប្រកប, ចំពោះ **ណយ** និង **ណាបយ** ត្រូវចុះ **ឥ**_អាគមផង ; ឧ. បុំ. **ភោជេតវា, ភោជយិតវា, ភោជាបេតវា, ភោជាបយិតវា** "ឱ្យបរិភោគហើយ" ។

**តាវី**_បច្ច័យ មានគតិដូច **តវន្តុ**_បច្ច័យដែរ ខុសតែស្រះទីបំផុត មួយ ជា **ឱ** មួយជា **ឡី** ប៉ុណ្ណោះ ។

កត្តុវាចកៈ **សុ** + **តាវី** : បុំ. **សុតាវី**, ឥ. **សុតាវិនី**, នបុំ. **សុតាវិ** "ឮហើយ, ស្ដាប់ហើយ" ។ បុំ. បំបែកដូច **សេដ្ឋី**, ឥ. បំបែកដូច **នារី**, នបុំ. បំបែកដូច **អដ្ឋិ** ។

**ហេតុកត្តុវាចកៈ ភុជ** + **ការិតប្បច្ច័យ** + **តាវី** : បុំ. **ភោជេតាវី, ភោជយិតាវី, ភោជាបេតាវី, ភោជាបយិតាវី** "ឱ្យបរិភោគហើយ" ។

## ឧទាហរណ៍ក្នុងកិច្ចប្បច្ច័យ

**តព្វ**_បច្ច័យ បើចុះប្រកបនឹងសកម្មធាតុ ត្រូវប្រើជាកម្មវាចកៈ និង ជាហេតុកម្មវាចកៈ, បើប្រកបនឹងអកម្មធាតុ ជាភាវវាចកៈ តែម្យ៉ាង ។

១) ធាតុមានស្រៈ **អា** ជាទីបំផុត គ្រាន់តែផ្សំនឹង **តព្វ**_បច្ច័យ ជាការស្រេចក៏មាន , ឧ. **ធា** + **តព្វ** : បុំ. **ធាតព្វោ**, ឥ. **ធាតព្វា**, នបុំ.

**ឃាតព្វំ** "គួរផឹក, គប្បីផឹក" ។ ផ្លាស់ **អា** ជា **អាយ** ហើយចុះ **ឥ**_អាគម ក៏មាន ឧ. **យា** + **តព្វ** : បុំ. **យាយិតព្វោ**, ឥ. **យាយិតព្វា**, នបុំ. **យាយិតព្វំ**, "គួរទៅ, គប្បីទៅ" ។

២) ធាតុដែលមានស្រៈ **ឥ**, **ឦ**, **ឧ**, **ឩ**, ជាទីបំផុត ផ្លាស់ធាតុជារូប ផ្សេងតាមលំនាំពួក **ភូ**_ធាតុ ; ឧទាហរណ៍ :

**បតិ** ឬ **បដិ** + **ឥ**, **ឥ** > **ឯ** + **តព្វ** : បុំ. **បច្ចេតព្វោ** "គប្បីដល់ចំពោះ, គប្បីជឿ" ។

**នី** > **នេ** + **តព្វ** : បុំ. **នេតព្វោ** "គប្បីនាំទៅ" ។

**សុ** > **សោ** + **តព្វ** : បុំ. **សោតព្វោ** "គប្បីឮ, គប្បីស្តាប់" ។

**ភូ** > **ភវ** + **ឥ** + **តព្វ** : **ភវិតព្វំ** "គប្បីកើត, គប្បីមាន, គប្បីជា" ។

ធាតុមានទីបំផុតជាព្យញ្ជនៈ គ្រាន់តែចុះ **ឥ**_អាគម ជាការស្រេច , ឧ. **បុច្ឆ** + **ឥ** + **តព្វ** : បុំ. **បុច្ឆិតព្វោ** "ដែលជនគប្បីសួរ" ។

ធាតុដែលមានទីបំផុតជាព្យញ្ជនៈ, ធាតុខ្លះមិនត្រូវចុះ **ឥ**_អាគមទេ តែត្រូវផ្លាស់ព្យញ្ជនៈទីបំផុតធាតុ និង **ត** នៃ **តព្វ** ជារូបផ្សេងៗ ក៏មាន ដូចតទៅ :

**លភ** + **តព្វ** > **លទ្ធព្វោ** "គប្បីបាន" ។

**ទិស** + **តព្វ** > **ទដ្ឋព្វោ** "គប្បីឃើញ" ។

**គម** + **តព្វ** > **គន្តព្វោ** "គប្បីទៅ, គប្បីដល់" ។

**ករ**, **រ** > **ត** + **តព្វ** > **កត្តព្វោ** "គប្បីធ្វើ" ។

**ករ** > **កា** + **តព្វ** > **កាតព្វោ** "គប្បីធ្វើ" ។

**បទ** + **តព្វ** > **បត្តព្វោ** "គប្បីដល់" ។

**វទ** + **តព្វ** > **វត្តព្វោ** "គប្បីពោល" ។

ធាតុខ្លះចុះបច្ច័យពួកធាតុផង ចុះ **ឥ**_អាគមផងក៏មាន ;

ឧ. **ពុធ** + **យ** + **ឥ** + **តព្វ** > **ពុជ្ឈិតព្វោ** "គប្បីដឹង, គប្បីត្រាស់ដឹង" ។

**កី** + **ណា** + **ឥ** + **តព្វ** > **កីណិតព្វោ** "គប្បីទិញ" ។

ហេតុកម្មវាចកៈ ត្រូវចុះការិតប្បច្ច័យ, តែត្រង់ **ណយ**, **ណាបយ**, ត្រូវចុះ ; **ឥ**_អាគមផង : ឧ. **ការេតព្វោ**, **ការយិតព្វោ**, **ការាបេតព្វោ**, **ការាបយិតព្វោ** "គប្បីឱ្យធ្វើ, ត្រូវឱ្យធ្វើ, គួរឱ្យធ្វើ" ។

ភាវវាចកៈ ជាអកម្មធាតុ នបុំ. តែម្យ៉ាង ; ឧ. **ភវិតព្វំ** "គប្បីកើត"។

**មរិតព្វំ** "គប្បីស្លាប់" **សក្កិតព្វំ** "គប្បីអាច" ជាដើម ។

**តព្វ**_បច្ច័យ ជាកិរិយាកិតកៈពិតមែន ប៉ុន្តែប្រើជានាមនាម បានខ្លះ ឧ. **គមនំ - គន្តព្វំ** "កិរិយាទៅ, ដំណើរទៅ" **ភ.ភ.** ។

**អនីយ**_បច្ច័យ មានគតិដូច **តព្វ**_បច្ច័យដែរ ប្លែកតែរូបសិទ្ធិ និង សណ្ឋានដូច្នេះ គឺ :

ធាតុមានអក្សរ ២ តួ ផ្លាស់ឱ្យខុសចាករូបដើមខ្លះ ក៏មាន , ឧ. **ទិស** > **ទស្ស** + **អនីយ** > **ទស្សនីយំ** "គប្បីឃើញ, គួរមើល, គួរពិតពិលរមិលមើល" ។

ធាតុទោល ត្រូវព្រឹទ្ធិធាតុខ្លះ , ឧ. **ភូ** > **ភវ** + **អនីយ** > **ភវនីយំ** "គប្បីកើត" មិនបាច់ព្រឹទ្ធិធាតុខ្លះ ឧ. **បា** + **អនីយ** > **បានីយំ** "គួរផឹក" ។

ធាតុមានអក្សរ ២ តួ ព្រឹទ្ធិធាតុបានខ្លះ ឧ. **ភុជ** > **ភោជ** + **អនីយ** > **ភោជនីយំ** "គួរបរិភោគ" ។

ធាតុដែលមាន **រ** ឬ **ហ** ជាទីបំផុត ផ្លាស់ **អនីយ** ជា **អណីយ** ឧ. **ករ** + **អនីយ** > **ករណីយំ** "គប្បីធ្វើ" ។ **គហ** + **អនីយ** > **គហណីយំ** "គប្បីកាន់" ។

សូម្បីធាតុក្រៅពីនេះ ក៏អាចផ្លាស់ **អនីយ** ជា **អណីយ** បានខ្លះដែរ, ឧ. **រម** + **អនីយ** > **មរណីយំ** "គួរត្រេកអរ" ។

តាមធម្មតា បច្ច័យនេះ ច្រើនតែទុកទាំងធាតុ ទាំងបច្ច័យឱ្យនៅដូចដើម ; ឧ. **បច** + **អនីយ** > **បចនីយំ** "គប្បីចំអិន" ។

ហេតុកម្មវាចក: ចុះ **ណាបេ**_បច្ច័យហើយ មិនបាច់ចុះបច្ច័យពួកធាតុក៏មាន ; ឧ. **ករ** + **ណាបេ** + **អនីយ** > **ការាបនីយោ** "គប្បីឱ្យធ្វើ" ។ ចុះ **ណាបេ**_បច្ច័យ ហើយចុះបច្ច័យពួកធាតុផងក៏មាន ; ឧ. **សិវ** + **យ** + **ណាបេ** + **អនីយ** > **សិព្វាបនីយោ** "គប្បីឱ្យដេរ" ត. **សិព្វាបនីយា**, នបុ. **សព្វាបនីយំ** ។

ភាវវាចក: ប្រកបនឹងអកម្មធាតុ ជា នបុំ. តែម្យ៉ាង ; ឧ. **ភវនីយំ** "គប្បីមាន" **សយនីយំ** "គប្បីដេក" **មរណីយំ** "គប្បីស្លាប់" ជាដើម ។

**អនីយ**_បច្ច័យ ជាកិរិយាកិតកៈពិតមែន ប៉ុន្តែប្រើជានាមនាម បានខ្លះ , ឧ. **ខាទិតព្វន្តិ** > **ខាទនីយំ** (**វត្ថុ** ) "(វត្ថុ) ដែលជនគួរទំពាស៊ី = (បង្អែម )" **កម្ម. កម្ម.** ។

## ឧទាហរណ៍ក្នុងកិតកិច្ចប្បច្ច័យ

**មាន_**បច្ច័យ ចុះក្នុងវាចកៈ ទាំង ៥ :

កត្តុវាចកៈ ត្រូវចុះបច្ច័យសម្រាប់ពួកធាតុមកផង ; ឧ. **បច** + **អ** + **មាន** : បុំ. **បចមានោ**, ឥ. **បចមានា**, នបុំ. **បចមានំ** "កំពុងចំអិន, កាលចំអិន" ។ **សិវ** + **យ** + **មាន** > **សិព្វមានោ**, **សុ** + **ណា** + **មាន** > **សុណមានោ**, **កី** + **នា** + **មាន** > **កីណមានោ**, **គហ** + **ណ្ហា** + **មាន** > **គណ្ហមានោ** ។

កម្មវាចកៈ ត្រូវចុះ **យ_**បច្ច័យ និង **ឥ_**អាគម ; ឧ. **ករ** + **ឥ** + **យ** + **មាន** > **ករិយមានោ** "ដែលគេកំពុងធ្វើ" **វច** > **វុច** + **យ** + **មាន** > **វុច្ចមានោ** " គឺគេ កាលពោល" ។

ភាវវាចកៈ ត្រូវចុះ **យ_**បច្ច័យ ប្រកបនឹងអកម្មធាតុ ជានបុំ. តែម្យ៉ាង **ភូ** + **យ** + **មាន** > **ភូយមានំ** "កំពុងកើត" (មិនធ្លាប់ឃើញប្រើ) ។

ហេតុកត្តុវាចកៈ ចុះបច្ច័យពួកធាតុមកក៏មាន មិនចុះក៏មាន ហើយត្រូវចុះ **ណយ** ឬ **ណាបយ** មកជាដរាប ; ឧ. **ករ** + **ណយ** + **មាន** > **ការយមានោ**, **ករ** + **ណាបយ** + **មាន** > **ការាបយមានោ** "កំពុងឱ្យធ្វើ, កាលឱ្យធ្វើ" **ទិវ** + **យ** + **ណយ** + **មាន** > **ទិព្វយមានោ**, **ទិវ** + **យ** + **ណាបយ** + **មាន** > **ទិព្វាបយមានោ** "កំពុងឱ្យលេង, កាលឱ្យលេង" ។

**ហេតុកម្មវាចកៈ** ចុះបច្ច័យពួកធាតុមកក៏មាន មិនបាច់ចុះក៏មាន តែ ត្រូវចុះ **ណាបេ**_បច្ច័យ **ឥ**_អាគម **យ**_បច្ច័យ ជាដរាប ឧ. **ករ** + **ណាបេ** + **ឥ** + **យ** + **មាន** > **ការាបិយមានោ** "(គឺជន) កំពុងឱ្យធ្វើ" **ទិវ** + **យ** + **ណាបេ** + **ឥ** + **យ** + **មាន** > **ទិព្វាបិយមានោ** "(គឺជន) កំពុងឱ្យលេង"។

ត_បច្ច័យ ប្រើបានគ្រប់វាចកៈ ទាំង ៥ :

បើទីបំផុតជាស្រះដែលមិនមែនជា **ឯ** គ្រាន់តែផ្សំនឹង **ត**_បច្ច័យ ជា ការស្រេច **ញា** + **ត** > **ញាតោ** "ដឹងហើយ" ; **ជិ** + **ត** > **ជិតោ** "ឈ្នះហើយ" ; **ភី** + **ត** > **ភីតោ** "ខ្លាចហើយ"

**សុ** + **ត** > **សុតោ** "ឮហើយ, ស្ដាប់ហើយ" ; **ភូ** + **ត** > **ភូតោ** "កើត, មាន, ជាហើយ" ។

ចំពោះ **ឋា**, **ធា**, **ធា**-ធាតុ ឱ្យផ្លាស់ **អា** របស់ **ឋា**, **ធា**, ជា **ឥ**, **អា** របស់ **ធា** ជា **ឦ** ឧ. **ឋា** + **ត** > **ឋិតោ** "ឈរ, ឋិតនៅ, តាំងនៅហើយ" ។ **និ** + **ធា** > **ហិ** + **ត** > **និហិតោ** "តម្កល់, កប់, ដាក់ចុះហើយ" ។ **ធា** + **ត** > **ធីតោ** "ផឹកហើយ" ។

ចំពោះ **ទា**-ធាតុ ត្រូវផ្លាស់ **ត** ជា **ឥន្ន** ហើយលុប **អា** របស់ **ទា** ឧ. **ទិន្នោ** "ឱ្យហើយ" ។ កាលមានបទដទៃនាំមុខ បំប្រួញចូលជាបទសមាសត្រូវផ្លាស់ **ទិន្ន** ជា **ទត្ត** ខ្លះ ឧ. **ទេវទត្តោ** **ព្រហ្មទត្តោ** **ពុទ្ធទត្តោ** ដែល ទេវតា-ព្រហ្ម-ព្រះពុទ្ធឱ្យហើយ ( ប្រទានហើយ )។

ធាតុដែលមាន **រ**, **ន**, **ម** ត្រូវលុបទីបំផុតធាតុក៏មាន ឧ. **ករ** + **ត** > **កតោ** "ធ្វើហើយ" **ជន** > **ជា** + **ត** > **ជាតោ** "កើតហើយ" ។ **គម** + **ត** > **គតោ** "ទៅហើយ" ។

ទីបំផុតធាតុជាព្យញ្ជនៈ បើមិនលុប ឬមិនផ្លាស់ទេ ត្រូវចុះ **ឥ**-អាគម ឧ. **ភថ** + **ត** > **ភថិតោ** " ពោលហើយ "

**ភាស** + **ត** > **ភាសិតោ** "សំដែងហើយ" ។

**ត**_បច្ច័យ ផ្លាស់ជារូបផ្សេងៗ ច្រើនទៀត ប្រព្រឹត្តទៅក្នុងលិង្គទាំង ៣ គឺ : បុំ. **ភថិតោ**, ឥត្ថិ. **ភថិតា** នបុំ. **ភថិតំ** ។

ចុះក្នុងវាចកៈ ៥ ប៉ុន្តែហេតុកត្តុវាចកៈមិនធ្លាប់ឃើញប្រើទេ, បើជា ហេតុកម្មវាចកៈ ត្រូវចុះ **ណេ** ឬ **ណាបេ**_បច្ច័យ ព្រមទាំង **ឥ**_អាគម ផង មិនបាច់ចុះបច្ច័យពួកធាតុក៏មាន , ឧ. **ករ** + **ណេ** + **ឥ** + **ត** > **ការិតោ** "ឱ្យធ្វើហើយ" ។ **មរ** + **ណាបេ** + **ឥ** + **ត** > **មារាបិតោ** "ឱ្យស្លាប់ហើយ" ។

ចុះបច្ច័យសម្រាប់ពួកធាតុមកផងក៏មាន ; ឧ. **ញា** + **នា** + **ណាបេ** + **ឥ** + **ត** > **ជានាបិតោ** "ឱ្យដឹងហើយ" ។

បើជាភាវវាចកៈ ត្រូវប្រកបនឹងអកម្មធាតុ ជានបុំ. បឋមាវិភត្តិ ឯក. តែម្យ៉ាង ឧ. **តេន មតំ** "គឺគេស្លាប់ហើយ" ។

**ត**_បច្ច័យនេះ ជាកិរិយាកិតកៈពិតមែន ប៉ុន្តែអាចប្រើជានាមកិតកៈ បានខ្លះ ឧ. **ជីវនំ** > **ជីវិតំ** "កិរិយារស់នៅ" = ( ជីវិត ) = (**ជីវ** + **ត**) **ភ.ភ.** ។ **ពុជ្ឈតីតិ** > **ពុទ្ធោ** ( **ភគវា** ) "( ព្រះមានព្រះភាគ ) ទ្រង់_ត្រាស់ដឹង" (**ពុធ** + **ត** ) **ក.ក.** ជាដើម ។

ត្វា, ត្វាន, ត្វូន បច្ច័យ ៣ តួនេះ ហៅថា ត្វាទិ_បច្ច័យ ប្រែថា "បច្ច័យមាន ត្វា_ជាដើម" ។ ជា អព្យយសព្ទ ព្រោះមិនមានវិធីបំបែកតាមវិភត្តិណាមួយឡើយ កាលប្រកបផ្សំនឹងធាតុសម្រេចយ៉ាងណា ក៏គង់រូបនៅយ៉ាងនោះជាដរាប ។

គួរចំណាំថា ត្វាទិ_បច្ច័យ ឃើញមានតែជា កត្តុវាចកៈ និងហេតុ_កត្តុវាចកៈ ប៉ុណ្ណោះ វាចកៈ ៣ ទៀត មិនឃើញមានឡើយ ។

បើមានឧបសគ្គណាមួយជាបុព្វបទ ឱ្យផ្លាស់បច្ច័យទាំង ៣ នុ៎ះណាមួយជា យ, ហើយទុកឱ្យនៅជា យ ប៉ុណ្ណោះក៏មាន ផ្លាស់ យ និងទីបំផុតធាតុជារូបផ្សេងក៏មាន ។

ធាតុមាន អា ជាទីបំផុត ឱ្យលុប អា ចេញ ; ឧ. ទា + ត្វា > ទត្វា "ឱ្យហើយ" ញា + ត្វា > ញត្វា "ដឹងហើយ", ឋា + ត្វា > ឋត្វា "ឈរហើយ" ។

ធាតុមានស្រៈ ឥ, ឦ ជាទីបំផុត ឱ្យផ្លាស់ ឥ, ជា ឦ ជា ឯ ហើយ ផ្លាស់ ឯ ជា អយ ចុះ ឥ_អាគមផង ; ឧ. ជិ + ត្វា > ជិត្វា, ជេត្វា, ជិនិត្វា "ឈ្នះហើយ", សី + ត្វា > សយិត្វា "ដេកហើយ", ភី + ត្វា > ភាយិត្វា "ខ្លាចហើយ" ។

ធាតុមានស្រះ ឱ, ឪ ជាទីបំផុត ឱ្យផ្លាស់ ឱ, ឪ ជា ឱ ហើយផ្លាស់ ឱ ជា **អវ** ចុះ ឥ_អាគមផង ឧ. **ចុ** + **ត្វា** > **ចវិត្វា** "ឃ្លាត_ហើយ", **ភូ** + **ត្វា**> **ភវិត្វា** "កើត, មាន, ជាហើយ" ។

ចុះបច្ច័យសម្រាប់ពួកធាតុមកផងក៏មាន ; ឧ. **មុច** + **អ** + **ឥ** + **ត្វា** > **មុញ្ចិត្វា** "រួច, លែង, របូតហើយ" **សុ** + **ណា** + **ឥ** + **ត្វា** > **សុណិត្វា** "ឮ, ស្តាប់ហើយ", **ជិ** + **នា** + **ឥ** + **ត្វា** > **ជិនិត្វា** "ឈ្នះហើយ", **ចិន្ត** + **ណេ** + **ត្វា** > **ចិន្តេត្វា** "គិតហើយ" ។

បើមានឧបសគ្គជាបុព្វបទ ផ្លាស់ **ត្វាទិ**_បច្ច័យជា **យ** ក៏មាន ឧ. **អា** + **ទា** + **ត្វា** > **យ** > **អាទាយ** "កាន់យកហើយ", **ឧ** + **ឋា** + **ត្វា** > **យ** > **ឧដ្ឋាយ** "ក្រោកឡើងហើយ" មិនផ្លាស់ **ត្វាទិ**_បច្ច័យជា **យ** ក៏មាន ; ឧ. **និ** + **កម** + **ឥ** + **ត្វា** > **និក្ខមិត្វា** "ចេញទៅហើយ", **ឧប** + **សំ** + **កម** + **ឥ** + **ត្វា** > **ឧបសង្កមិត្វា** "ចូលទៅជិតហើយ" ។

ផ្លាស់ **ត្វានិ**-បច្ច័យជា **យ** ហើយផ្លាស់ **យ** និងទីបំផុតធាតុជាព្យញ្ជនៈផ្សេង ឧ. **អា** + **ភរ** + **ត្វា**, **ត្វា** > **យ** > **អាភរិត្វា** "ប្រារព្ធ, ប្រុងប្រៀប, តាំងផ្ដើមហើយ" ។ល។

ចំពោះ **ទិស**-ធាតុ ឱ្យផ្លាស់ **ត្វា** ជា **ស្វា**, **ត្វាន** ជា **ស្វាន** ហើយលុបទីបំផុតធាតុចេញ ឧ. **ទិស្វា**, **ទិស្វាន** "ឃើញហើយ, លុះឃើញ-ហើយ" ។

**ហេតុកត្តុវាចកៈ** ត្រូវចុះការិតប្បច្ច័យមកផង ចុះបច្ច័យសម្រាប់ពួកធាតុក៏មាន មិនបាច់ចុះក៏មានផង ត្រង់ **ណយ** និង **ណាបយ** ត្រូវចុះ **ឥ**-អាគមមកផង ឧ. **ឃាចេត្វា**, **ឃាចយិត្វា**, **ឃាចាបេត្វា**, **ឃាចាបយិត្វា** "ឱ្យចំអិនហើយ" ។ **ភុញ្ជេត្វា**, **ភុញ្ជយិត្វា**, **ភុញ្ជាបេត្វា** "ឱ្យបរិភោគហើយ" ។

# ការតែងវាចកៈ ៤

# ជា

# កិរិយាអាខ្យាត និង កិរិយាកិតកៈ

ដោយសព្ទ : ថេរ សាមណេរ ធម្ម សិក្ខ ជាគំរូ ។

អាខ្យាត កត្តុ. ថេរស្ស សាមណេរោ ធម្មំ សិក្ខតិ ។

កិតកៈ កត្តុ. ថេរស្ស សាមណេរោ ធម្មំ សិក្ខន្តោ (សិក្ខិត្វា) ។

អាខ្យាត កម្ម. ថេរស្ស សាមណេរេន ធម្មោ សិក្ខិយតេ ។

កិតកៈ កម្ម. ថេរស្ស សាមណេរេន ធម្មោ សិក្ខិតព្វោ (សិក្ខិតោ) ។

អាខ្យាត ហេតុកត្តុ. ថេរោ សាមណេរំ ធម្មំ សិក្ខាបេតិ ។

កិតកៈ ហេតុកត្តុ. ថេរោ សាមណេរំ ធម្មំ សិក្ខាបេន្តោ (សិក្ខាបេត្វា) ។

អាខ្យាត ហេតុកម្ម. ថេរេន សាមណេរំ ធម្មោ សិក្ខាបិយតេ ។

កិតកៈ ហេតុកម្ម. ថេរេន សាមណេរំ ធម្មោ សិក្ខាបេតព្វោ ( សិក្ខាបិតោ ) ។

## សន្ត សព្ទ ប្រែបាន ២ យ៉ាងគឺ :

១) សន្ត មកពី សម-ធាតុ ត-បច្ច័យ ប្រែថា "ស្ងប់រម្ងាប់ហើយ" ។

២) សន្ត មកពី អស-ធាតុ អន្ត-បច្ច័យ លុបដើមធាតុ ប្រែថា "កាលមាន" ។

**សន្ត** ទាំង ២ យ៉ាងនេះ បំបែកតាម **បុរិស** និង **វចន**, នឹងបំបែកតាម **វចន** ជាបុំ. ដូច្នេះ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. **សំ** | **សន្តា, សន្តោ** |
| ទុ. **សន្តំ** | **សន្តេ, សន្តោ** |
| ត. **សតា** | **សន្តេហិ, សន្តេភិ** |
| ច. **សតោ** | **សតំ, សន្តានំ** |
| បញ្ច. **សតា** | **សន្តេហិ, សន្តេភិ** |
| ឆ. **សតោ** | **សតំ, សន្តានំ** |
| ស. **សតិ, សន្តេ** | **សន្តេសុ** |
| អា. **សន្ត** | **សន្តា, សន្តោ** |

បច្ច័យ ៣ គឺ **ត, តវន្តុ, អនីយ** នៃកិរិយាកិតកៈអាចប្រើជាកិរិយាគ្រប់គ្រងប្រយោគបាន កាលបើប្រយោគនោះ ពុំមានកិរិយាអាខ្យាតគ្រប់គ្រងទេ ។

## លំហាត់ប្រែជាភាសាខ្មែរ

**១-ពុទ្ធោ លោកេ ឧប្បន្នោ ។**

**២-ធម្មោ សប្បុរិសានំ សន្តានេ ឋិតោ ។**

៣-ភិក្ខុសង្ឃោ អនុបុព្វេន ជេតវនំ គតោ ។

៤-ឥសយោ រញ្ញោ ឧយ្យានេ ទុដ្ឋា ។

៥-នីលំ ឧប្បលំ ឧទកេ ជាតំ ។

៦-សុក្ខា សាខា រុក្ខា បតិតា ។

៧-រាជា មហន្តេន បរិវារេន និក្ខន្តោ ។

៨-ចណ្ឌោ ហត្ថី នគរា គតោ ។

៩-ឥត្ថិយោ នាវាយ នទិយំ គតា ។

១០-សមណា នគរំ បិណ្ឌាយ បវិដ្ឋា ។

## លំហាត់ប្រែជាភាសាបាលី

១-ព្រះរតនៈទ. បី កើតឡើងហើយ ក្នុងលោក ។

២-ភិក្ខុទ. ទៅហើយ កាន់វត្តវេឡុវ័ន តាមលំដាប់ ។

៣-ព្រះពុទ្ធ គង់នៅហើយ ក្នុងអារាម របស់នាងវិសាខា ។

៤-ភិក្ខុទ. ប៉ែតសិបអង្គ ទៅហើយ កាន់វត្តជេតពន ។

៥-ផ្កាបទុមទ. បួន ដុះហើយ ក្នុងស្រះ របស់ខ្ញុំ ។

៦-ព្រះមហាថេរៈ ចេញទៅហើយ ដោយភិក្ខុ ច្រើនអង្គ ។

៧-ដំរី កាច ទៅហើយ កាន់ព្រៃ ធំ ។

៨-ភិក្ខុទ. គួរតែចូលទៅ កាន់នគរ ដើម្បីបិណ្ឌបាត ។

៩_ឧបាសកទ. គប្បីប្រគេន នូវបិណ្ឌបាត ដល់ភិក្ខុទ. ។

១០_បរិស័ទទ. បួនពួក គួរទៅ កាន់វត្ត ដើម្បីស្តាប់ នូវធម៌ ។

## លំហាត់ប្រែជាភាសាខ្មែរ

១_ឯកសដ្ឋី អរហន្តោ លោកេ ឧប្បន្នា ។

២_អសីតិ សាវកា ជាតា ។

៣_សត្ត រតនានិ ចក្កវត្តិនោ ជាតានិ ។

៤_មម អារាមំ គច្ឆន្តស្ស បញ្ចវីសតិ ទិវសា អតិក្កន្តា ។

៥_ទេវសិកំ សមណសិស្សា បាលិភាសំ ឧគ្គណ្ហាបិតា ។

៦_វត្ថូនិ រញ្ញោ អដ្ឋត្តឹសាយ ជនានំ ទិន្នានិ ។

៧_គហបតិនោ តិស្សោ ធីតរោ មហានទឹ គតា ។

៨_ឧបាសិកាយោ អារាមំ គតា ធម្មោ តាហិ សុណិតោ ។

៩_ទេវេ វស្សន្តេ ឧទកស្ស ពិន្ទូនិ ចាដិយំ បរិបុណ្ណានិ ។

១០_សិស្សា អាចរិយំ ឧបសង្កមិតា ឱវាទោ តេន តេសំ ទិន្នោ ។

## លំហាត់ប្រែជាភាសាបាលី

១_ព្រះអរហន្តទ. ៧៥ អង្គ គប្បីកើតឡើង ក្នុងលោក ។

២_សាវិកាទ. ៥០ អង្គ របស់ព្រះសាស្តា កើតហើយ ។

៣_រតនៈទ. ៧ ប្រការ គប្បីកើត ដល់ព្រះមហារាជ ។

៤_កាលដែលលោក កាលទៅ កាន់ខេត្ត, ថ្ងៃទ. ម្ភៃប្រាំបី កន្លង-ទៅហើយ ។

៥_សមណសិស្សទ. ក្នុងវត្ត គួរតែរៀន ភាសាបាលី ។

៦_ចីវរទ. គឺឧបាសក គួរប្រគេន ដល់ភិក្ខុទ. ក្នុងវត្ត ។

៧_កូនប្រុសទ. បួននាក់ ទៅហើយ កាន់ក្រុង ដោយយានទ. ។

៨_កាលមនុស្សទ. កំពុងស្តាប់ នូវធម៌ ចិត្តនៃមនុស្សទ. នោះរីករាយហើយ ។

៩_បុរសនេះ កាលបើប្រពន្ធនៃខ្លួន ស្លាប់ហើយ បានហើយនូវប្រពន្ធដទៃ ។

១០_នាកាលព្រះអាទិត្យ អស្តង្គតហើយ ព្រះចន្ទ រះឡើង ។

## សំរាប់ប្រែជាភាសាខ្មែរ

១_ថេរស្ស ធម្មំ កថេន្តស្ស អរុណោ ឧគ្គច្ឆិ ។

២_មនុស្សានំ ធម្មំ សុណន្តានំ តេសំ ចិត្តំ រតនេសុ បមោទតិ ។

៣_ឥន្ទគោបកា ទេវស្ស វុដ្ឋស្ស អត្តនោ ឋានា ឧដ្ឋហន្តិ ។

៤_អយំ បុរិសោ អត្តនោ ភរិយាយ មតាយ អញ្ញំ ភរិយំ លភតិ ។

៥_សីហស្ស អាគតស្ស មិគា តម្ហា ឋានា បលាយឹសុ ។

៦-មេឃេ អបគតេ ចន្ទោ ឱភាសំ វិស្សជ្ជេសិ ។

៧-សុរិយេ អដ្ឋង្គតេ ចន្ទោ អាកាសេ ឧគ្គច្ឆិ ។

៨-ជេដ្ឋកោ បុត្តោ បិតរិ មតេ តស្ស សម្បត្តឹ បដិលភតិ ។

៩-សិស្សា អត្តនោ អាចរិយេ អាគតេ សក្កច្ចំ អាសនា ឧដ្ឋហន្តិ ។

១០-អញ្ញតិត្ថិយា ពុទ្ធេ លោកេ ឧប្បន្នេ លាភសក្ការា បរិហាយឹសុ ។

## សំរាត់ប្រែជាភាសាបាលី

១-កាលដែលខ្ញុំ កំពុងស្តាប់ នូវធម៌, ព្រះចន្ទ រះឡើងហើយ ។

២-កាលដែលកូនទ. កំពុងរៀន នូវធម៌, ចិត្ត របស់វាទ. តែងត្រេកអរ ។

៣-កាលដែលភ្លៀង បង្អុរចុះហើយ មេភ្លៀងទ. ផុះឡើងហើយ ពីផែនដី ។

៤-នាកាលសីហៈ មកហើយ គោទ. បោលទៅហើយ ។

៥-ភរិយា នោះ នាកាលស្វាមី របស់ខ្លួន ស្លាប់ហើយ បានហើយ នូវស្វាមីដទៃ ។

៦-នាកាលព្រះអាទិត្យ អស្តង្គតហើយ យើងទ. គប្បីអុជ នូវប្រទីប ។

៧-កូន ច្បង កាលបើបិតា ស្លាប់ហើយ គួរតែបាន នូវសម្បត្តិ របស់គាត់ ។

៨_នាកាលអាចារ្យ របស់ខ្លួន មកហើយ សិស្សទ. គួរក្រោក ចាកអាសនៈ របស់ខ្លួន ។

៩_នាកាលភ្លៀង រាំងហើយ ព្រះចន្ទ ផ្សាយទៅហើយ នូវពន្លឺ ព្ធដ៏អាកាស ។

១០_កាលបើព្រះពុទ្ធ ទ្រង់កើតឡើងហើយ ក្នុងលោក, អន្យតិរ្ថិយ៍ទ. សាបសូន្យហើយ ចាកលាភ របស់ខ្លួនៗ ។

## ចប់បែបរៀនភាសាបាលី

## ភាគទី ១